# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ជិន រឿន ហៅសាមុិ ភេទស្រី (ក្រៅប្រវត្តិរូប)

## ជួបសម្ភាសន៍ជាមួយ ជិន រឿន អាយុ៥៧ឆ្នាំ

## រស់នៅភូមិពពែល ឃុំប្រទាលជ្រុំ ស្រុកត្រពាំងប្រសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦

## សម្ភាសន៍ដោយ ឡុង ដានី

ដានីៈ អញ្ជើញមីងដីបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអ៎ដែរ? ប្រសាត

រឿនៈ ខ្ញុំឈ្មោះជិន រឿន ។

ដានីៈ ជិន រឿន?

រឿនៈ ចា៎!

ដានីៈ ឈ្មោះកំណើត មីងឈ្មោះអីដែរ?

រឿនៈ ឈ្មោះកំណើតខ្ញុំឈ្មោះ ជិន សាមុិ ។

ដានីៈ ជិន សាមុិ?

រឿនៈ ចា៎!

ដានីៈ ដល់ពេលធ្វើបដិវត្តទៅប្រែដាក់ឈ្មោះជិន រឿនវិញទៅ?

រឿនៈ ចា៎!

ដានីៈ សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

រឿនៈ ខ្ញុំអាយុ៥០ ....មើលកើតឆ្នាំ១៩៤៩ ។

ដានីៈ ១៩៤៩?

រឿនៈ ចា៎!

ដានីៈ ៥៧ឆ្នាំ?

រឿនៈ ចា៎! ៥៧ ។

ដានីៈ មីងមានស្រុកកំណើកើតជានៅភូមិឃុំស្រុកអីដែរ?

រឿនៈ នៅភូមិឬស្សីកែវ ឃុំឬស្សីកែវ ស្រុកព្រែកប្រសប់ ខេត្តក្រចេះ ។

ដានីៈ បាទ! ចុះមីងមានគ្រួសាហើយ ឈ្មោះអីដែរគ្រួសាមីង?

វឿនៈ ឈ្មោះឌី ។

ដានីៈ ឈ្មោះអីឌី?

វឿនៈ ឈ្មោះឌិ ឌី ។

ដានីៈ ឌិ ឌី ។

វឿនៈ ចា៎! ស្លាប់ហើយ ។

ដានីៈ គាត់ស្លាប់ឆ្នាំណាទៅមីង?

វឿនៈ គាត់ស្លាប់ឆ្នាំកៅប៉ុន្មានទេ...? ៩២ ។

ដានីៈ ៩២?

វឿនៈ ចា៎! អហ៎! ឆ្នាំ២០០២ ។

ដានីៈ ២០០២ ។

វឿនៈ ចា៎!

ដានីៈ ទើបហ្នឹងស្លាប់៣ឆ្នាំហ្នឹង ៣ ៤ឆ្នាំហ្នឹងទេ?

វឿនៈ ទេមិនមែន២០០២ទេណា៎! ...ឆ្នាំដែលគេដាច់ អ! ឆ្នាំ២០០០ ។ ចា៎! ថ្ងៃមួយ ខែមួយ ។

ដានីៈ ចុះមីងមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

វឿនៈ មានតែ២ ។

ដានីៈ ឈ្មោះអីខ្លះទៅ?

វឿនៈ មួយឈ្មោះឌី ថុន ។

ដានីៈ លី ថុន?

វឿនៈ ឌី!

ដានីៈ ឌី ថុន ។

វឿនៈ ឌី ថុន ។

ដានីៈ ស្រី ប្រុស?

វឿនៈ ប្រុស ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

វឿនៈ អាយុ២៣ ។

ដានីៈ ចុះកូនទីពីរ?

វឿនៈ កូនទីពីរឈ្មោះឌី ស្រីនាំង ។

ដានីៈ ឌី ស្រីនាង ។

រឿនៈ ចាំ!

ដានីៈ ស្រីទេ?

រឿនៈ ចាំ! នៅរៀន។ តូចដែរអាយុ៧ឆ្នាំ ៨ឆ្នាំ។

ដានីៈ ៧ឆ្នាំ។ ចុះមីងសព្វថ្ងៃមីងប្រកបរបររកស៊ីធ្វើអីដែរ?

រឿនៈ ខ្ញុំអត់មានធ្វើទេ មានតែធ្វើអញ្ចឹង ធ្វើពពិស្សី ធ្វើអីអញ្ចឹង។

ដានីៈ អ! មីងធ្វើគ្រូ?

រឿនៈ ចាំ!

ដានីៈ គ្រូដូចថាខាង....?

រឿនៈ ទស្សទាយមើលរាសីអីអញ្ចឹង។

ដានីៈ អ! គ្រូទាយ។

រឿនៈ មិនដែលធ្វើស្រែទេ តាំងពីក្មេងមកមិនដែលធ្វើស្រែទេ។

ដានីៈ បាទ! ចុះមីងឪពុកម្តាយមីងគាត់ឈ្មោះអីខ្លះទៅ?

រឿនៈ ឈ្មោះតា ចៀម។ ពុក។

ដានីៈ ឪពុកឈ្មោះចៀម?

រឿនៈ ចាំ! ម្តាយឈ្មោះសឹម។

ដានីៈ ម្តាយឈ្មោះសឹម។ ចុះសព្វថ្ងៃគាត់នៅរស់ទេ?

រឿនៈ ស្លាប់អស់ហើយ។

ដានីៈ គាត់ស្លាប់អស់ហើយ។

រឿនៈ ស្លាប់ទាំងអស់។

ដានីៈ បាទ! ឪពុកម្តាយមីងនៅឬស្សីកែវហ្នឹង នៅភូមិឬស្សីកែវហ្នឹង?

រឿនៈ ចាំ! នៅភូមិឬស្សីកែវ ឃុំឬស្សីកែវ សង្កាត់ឬស្សីកែវ ភូមិឬស្សីកែវដែរ។ នៅជា មួយគ្នា

ដានីៈ មីងមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

រឿនៈ បងប្អូនទាំងអស់៦នាក់។

ដានីៈ បងប្អូន៦នាក់។

រឿនៈ ចាំ! តែស្លាប់អស់បីនៅសល់បី។ នៅសល់៤។ ស្លាប់អស់ពីរនៅសល់៤។

ដានីៈ ស្លាប់អស់២នាក់នៅសល់៤។ ៦នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រឿនៈ ប្រុសមួយ ស្រីបី។

ដានីៈ ចុះបងទីមួយឈ្មោះអីទៅមីង?

រឿនៈ បងទីមួយឈ្មោះបងស្រួន។

ដានីៈ ស្រួន?

រឿនៈ អ! បងយឿន ប៉ុន្តែយឿនស្លាប់ហើយរាប់ដែរ?

ដានីៈ រាប់ខ្ញុំចង់ដឹង។

រឿនៈ បងយឿន។

ដានីៈ យឿនស្រីឬប្រុស?

រឿនៈ ប្រុស។

ដានីៈ ប្រុសគាត់ស្លាប់ហើយ?

រឿនៈ ចា៎!

ដានីៈ គាត់ស្លាប់ឆ្នាំណាទៅ?

រឿនៈ ឆ្នាំប៉ុន្មាន....គេនេះបានគេដឹង ខ្ញុំអត់បានដឹងទេ។

ដានីៈ អ! គាត់ទើបហ្នឹងស្លាប់ក្រោយបែក៧៩ហើយ?

រឿនៈ ចា៎! ព្រោះគាត់ប្អូន ប្អូនថ្លៃ។

ដានីៈ ស្លាប់ដោយសាអីទៅ?

រឿនៈ ជម្ងឺ។

ដានីៈ ជម្ងឺ។ ចុះទីពីរឈ្មោះអីទៅ ទីពីរ?

រឿនៈ ទីពីរឈ្មោះ...ស្រួន។

ដានីៈ ស្រួន។ ស្លាប់ដែរ?

រឿនៈ ស្លាប់ដែរ។ ប្រុសនៅ..

ដានីៈ គាត់នៅ គាត់នៅណាទៅ?

រឿនៈ នៅឫស្សីកែវហ្នឹង។

ដានីៈ នៅភូមិឫស្សីកែវ។

រឿនៈ ចា៎!

ដានីៈ ទីបី?

រឿនៈ ទីបីឈ្មោះស្រេន។

ដានីៈ ស្រេន ស្រី?

រឿនៈ ចា៎! ស្លាប់ដែរ។

ដានីៈ គាត់ស្លាប់នៅជំនាន់ណាទៅ?

រឿនៈ មិនដឹង ខ្ញុំអត់ដឹង ខ្ញុំនៅខ្មែរក្រហមនោះអត់ដឹងគាត់ស្លាប់ពីអន្តាល ។

ដានីៈ បាទ!

អ្នកជិតខាងៈស្លាប់មុនលោកបងបាក់ទព័្វប្រឆាំង ។

ដានីៈ ចុះទីបួនមីង?

រឿនៈ ទីបួននៅ ឈ្មោះបែ ណយ ។

ដានីៈ បែ ណយ ។

រឿនៈ ចា៎!

ដានីៈ សព្វថ្ងៃគាត់នៅណា?

រឿនៈ នៅឬស្សីកែវ ។

ដានីៈ នៅឬស្សីកែវដែរ ។ ចុះទីប្រាំ?

រឿនៈ ទីប្រាំបែ អូន ។

ដានីៈ បែ អូន ។ គាត់ស្លាប់ឬនៅ?

រឿនៈ នៅ ។

ដានីៈ នៅណាទៅ?

រឿនៈ នៅបឹងរៃ ។

ដានីៈ នៅបឹងរៃ?

រឿនៈ ចា៎!

ដានីៈ បឹងរៃហ្នឹងនៅឃុំឬស្សីកែវដែរ ។

រឿនៈ ឃុំឬសីកែវជាមួយគ្នា សង្កាត់ឬស្សីកែវជាមួយគ្នា ។

ដានីៈ បាទ! ទីប្រាំមួយ?

រឿនៈ ទីប្រាំមួយខ្ញុំ ។

ដានីៈ អ! មីងពៅគេ ។

រឿនៈ ចា៎!

ដានីៈ អញ្ចឹងខ្ញុំចង់ដឹងពីប្រវត្តិរបស់មីងតាំងពីក្មេងៗមកមីងធ្លាប់បានរៀនសូត្រអីនៅសាលាណាដែររហូត?

រឿនៈ ខ្ញុំនៅសាលាវត្តឬស្សីកែវ ។

ដានីៈ បាទ! ដូចថា ខ្ញុំចង់ដឹងឲ្យមីងរៀបរាប់ពីជីវិតរបស់មីងណា៎! តាំពីមីងចូលរៀន រៀនហើយឈប់ ទៅធ្វើអីនៅកន្លែងណាៗរហូតដល់...បែក៧៩មក?

រឿនៈ	អញ្ចឹងយើងនិយាយតាំងពីយើងប្រវតយើងតាំងពីក្មេងដែលដឹងក្តីណា...។

ដានីៈ	បាទ! បាទ! ។

រឿនៈ	ប្រវត្តិតាំងពីដឹងក្តី ។ ទីមួយខ្ញុំសូមលើកពីបញ្ហាឆាកជីវិតរបស់ខ្ញុំតាំងពីនោះមករហូតដល់បច្ចុប្បន្ន អញ្ចឹងណាក្មួយ ។ ចាំ! ទីមួយខ្ញុំនៅរៀន ខ្ញុំដឹងក្តីឡើងខ្ញុំបានរៀន រៀនសូត្រនៅ ថ្នាក់ទី៩ ថ្នាក់ទី៩យើងពីដើមណា ។ ចាំ! រៀនថ្នាក់ទី៩ រៀន រៀនអញ្ចឹងទៅ...គ្មាន ប្រវត្តិអី ហ្នឹ ឲ្យបានដូរចត់ទេ ពីដើមមកណាក្មួយ ។ ចាំ! ខ្ញុំចង់សុំថា ក្មួយលើកពីរឿង បញ្ហាពីត្រឹមនេះទៅ ។

ដានីៈ	បាទ! បាទ! ខ្ញុំចង់ឲ្យមីងរៀបរាប់ត្រួសៗសិន ។

រឿនៈ	ចាំ! ក្នុងការរៀនសូត្ររួចហើយបានសម័យឆ្នាំ៧០ហ្នឹងគេធ្វើរដ្ឋប្រហារ ។ ចាំ ធ្វើរដ្ឋប្រ-ហារអត់ទាន់បានមួយឆ្នាំទេ អើ! ក្នុងមយឆ្នាំហើយព្រោះខ្ញុំចូលតស៊ូក្នុងឆ្នាំ៧១ ខែ៥ ថ្ងៃ ៥ អញ្ចឹងហើយ ថ្ងៃ៥ ខែអញ្ចឹងហើយចូល ចូលបដិវត្តន៍នោះ ចូលរួចហើយ ចូលទៅក្នុងសមាគមនារី ។ ចាំ! មេបញ្ជាការខ្ញុំឈ្មោះបងថេរ តែឈ្មោះដើមឈ្មោះអុន ។ ស្អីសុំ អុនហ្នឹងនោះ....សុំ អុននេះនៅជើងនោះ កែងហ្នឹងនោះ ដែលឃើញឈ្មោះពីម្សិលដែរ ។ ហ្នឹងជាមេបញ្ជារបស់ខ្ញុំ ។ ដល់ទៅរួចហើយបានខ្ញុំចូលទៅខាងសិលប្បៈចេញពីគាត់ទៅដកខ្ញុំទៅខាងសិលប្បៈកាលមុននៅខាងទទួលខុសត្រូវនៅខាងផ្នែកនារី នៅក្នុងភូមិបង្ហាត់សិល្បៈហ្នឹងដល់មេបញ្ជាការលោកតាចាន់ ថនហ្នឹងដឹងថា ខ្ញុំចេះក៏គាត់យកទៅកន្លែងស្រុក យកទៅកន្លែងស្រុកនោះ យកទៅធ្វើប្រធានមួយសម្រាប់ណែ៎! បង្ហាត់ពួកកងនារី រួច ហើយក៏ទៅរៀនពេទ្យទៀត រៀនពេទ្យបានជាងមួយឆ្នាំ បានរៀនពេទ្យហើយបានទៅរៀនពេទ្យពិសោធន៍ទៀតបន្តទៅទៀត ។

ដានីៈ	បាទ! តទៅទៀត ។

រឿនៈ	ចាំ!ហើយដល់ទៅពេលរួចអញ្ចឹងមកខ្ញុំទៅបង្ហាត់បង្រៀនកូនសិស្សនៅស្រែឆ្វាបបង្រៀន កូនសិស្សបានមួយឆ្នាំទៀត ។ រួចហើយបានគេបញ្ជូនខ្ញុំមកនៅមណ្ឌលគិរីនៅមណ្ឌលគិរីនេះចាប់ផ្តើមប្រវត្តដូចត់នៅត្រឹមមណ្ឌលគិរី ។ នៅមណ្ឌលគិរីនៅធ្វើខាងពេទ្យអញ្ចឹងថែមទៀត ពេទ្យផងសិល្បៈផង រួចហើយបានទៅពេទ្យហើយមួយជំនាន់ហ្នឹងឯងដែលច្របូកច្របល់ដែល គេយកវៃគ្នា វៃអីវៃមេៗ មេយកមេវៃចោលអីហ្នឹង ពូឈិនពូអីហ្នឹងគេយក វៃចោលហ្នឹង កាលម៉ាជំនាន់ហ្នឹង សុទ្ធតែមានប្រវត្តិហើយតាហ្នឹង មកនៅសុខសាន្តហ្នឹងនៅមណ្ឌលគិរីហ្នឹង ។ ចាំ! ដល់រួចហើយពួកខ្ញុំបានគេមេបញ្ជាការហ្នឹងគេផាស់តាឈិនហ្នឹងក៏ ផ្លាស់ទៅនៅកោះញែក ។ ទៅនៅកោះញែកអូច្បាហ្នឹង ។ ទៅនៅកោះញែកហើយបានខ្ញុំ ហ្នឹងគេ ដកចេញពី សិល្បៈ គេឲ្យទៅនៅខាង...រៀនពេទ្យឆ្មប ។ ចាំ! រៀនពេទ្យឆ្មបចេះតែ រៀនទៅអាគេតាម សម័យ

នោះ សម័យគេហៅថាសម័យកសាង សម័យកសាងគេកសាង ស្អាតស្អំណាស់សូម្បី តែមានការខុសឆ្គងអីបន្តិចបន្តួចក៏គេយកវ៉ៃចោលដែរនៅជំនាន់នោះតែខ្ញុំអត់មានអីហ្នឹងគេទមានបានវ៉ៃចោលវ៉ៃអីទេ ។ ក៏ខ្ញុំចាប់ផ្តើមគេរៀបចំគ្រួសានៅឆ្នាំ៧៥ ៧៦ថ្ងៃ៧ ខែ៧ ឆ្នាំ៧៦ ។ គេគ្រួសារ...និយាយម៉េចទៀត...

ដានី: បាទ!

រឿន: ចេះបន្តទៅ

ដានី: រៀបគ្រួសាហើយយ៉ាងម៉េចទៀតទៅ?

រឿន: រៀបគ្រួសាហើយបានកូនមួយក៏ឆ្នាំ៧៩ រៀបគ្រួសាហើយប្តីខ្ញុំមិនដែលនៅជាមួយទេគេទៅទ័ពហើយខ្ញុំនៅតែធ្វើពេទ្យនៅក្នុងមន្ទីរពេទ្យហ្នឹងប៉ុនអត់មានដូចថាគ្មានប្រវត្តិអីនៅក្នុងមន្ទីរពេទ្យ ទេវាគ្មានប្រវត្តអីដូចតប៉ុនគ្រាន់តែថាគេចម្រាញ់មនុស្សចាំ!សូម្បីតែខូចស្លាបព្រាមួយបាក់ស្លាបព្រាមួយក៏គេចោទថាយើងខ្នាំងដែរ ។ រួចហើយបានគេចម្រាញ...ខ្ញុំ និយាយនេះវាហួស រឿងគេរើសយកទៅដាក់អ! នារីកងមួយរយនោះ កាលនោះនៅសុខសាន្ត ។ វាយកទៅរើស ហ្នឹងនារីកងមួយរយហ្នឹងគេរើទាំងខ្ញុំទាំងអីហ្នឹងទៅដោយជាមួយគេ ហ្នឹងណាំ! តែគេថានារីកង មួយរយសម្រាប់យួន ហ្នឹងណាំ! ទុកសម្រាប់យួន ទុកសម្រាប់ យួនហ្នឹងមិន ដឹងទុករបៀបម៉េចទេអត់ដឹងដែរ ។ ហើយដល់អញ្ចឹងទៅខ្ញុំក៏មេប្រធានខ្ញុំហ្នឹងក៏ ដកខ្ញុំមកវិញថាកុំឲ្យទៅព្រោះឆ្ងបទូទៅមិនសូវប្រសប់ទេ បើខ្ញុំគេទុកចិត្ត មេគេទុកចិត្ត អញ្ចឹងបានថា ឲ្យខ្ញុំនៅក្រោយកុំឲ្យយកទៅជាមួយកងមួយរយហ្នឹងកុំឲ្យវាពិបាកព្រោះនារីកងមួយរយគេសម្រាប់តែ រឿងសំខាន់បំផុតគឺទុកឲ្យភ្ញៀវតែប៉ុណ្ណឹង ប៉ុណ្ណឹងវាយកឲ្យភ្ញៀវអី ខ្ញុំអត់សូវដឹងដែរកាលនោះ គេសម្រាប់ភ្ញៀវអីទេ មិនដឹងគេសម្រាប់យកទៅធ្វើបាយមិន ដឹងគេសម្រាប់យកទៅសប្បាយ មិនដឹងអត់ដឹង ។ ដល់រួចពីហ្នឹងហើយមកក៏ក្រវាត់នៅកោះញែកគេយក គេយកពីឈិនហ្នឹងកាលហ្នឹងមនដឹងរឿងយ៉ាងម៉េចទេគេយកពូឈិនហ្នឹងទៅភ្នំពេញខ្ញុំក៏ទៅឆ្លងទន្លេជិះយន្តហោះ ទៅជាមួយពូឈិននោះ គេដកពូឈិននោះចេញទៅ បានគេដាក់០៦មក ហើយខ្ញុំទៅជាមួយ ពួកក្បត់ហ្នឹងគេថា ពួកក្បត់ក៏ក្បត់ហ្នឹងគេទៅបើពូ ឈិន ឃើញខ្ញុំក៏មិត្តរឿនហើយ គ្នាទៅ ណោះមិនដឹងជាយ៉ាងណាយ៉ាងណីទេ មិនដឹងរឿង ហេតុអីទេ ព្រោះគេផ្លាស់កងពល យើងប៉ុណ្ណឹងហើយបែកគ្នាហើយក៏ទៅទាំងបងសយទៅទាំងបងឈិនអីទាំងអស់គ្នា ។ អាហ្នឹងជាមេបញ្ជាការពួកខ្ញុំដែរព្រោះពួកខ្ញុំសិល្បៈនៅជាមួយគាត់ ហ្នឹង ។ ចាំ! ទៅក្រោយមកបាន ជំនាន់បង០៦ហ្នឹង ។ ជំនាន់បង០៦ហ្នឹង បាន មកដល់ ជំនាន់បង០៦ហើយបានខ្ញុំរៀប គ្រួសាដល់តែពេលអញ្ចឹងទៅម៉ាជំនានបង០៦ហ្នឹងមហាច្របូក ច្របល់ហើយនិយាយពីច្របូកច្របលល់ណាស់ ។

ការសូម្បីតែពាក្យសម្ដីបន្តិចក៏គេដាក់សន្តិសុខ ដែរខ្ញុំចេះតែព្រឺរផាៗដូចគេ គ្រូនចាញ់អញ្ចឹងៗ ដល់ហើយអញ្ចឹងមកបាន យើងដែលគេថា យួនចូលនៅទីយូសាំងក៏នាំគ្នារត់រត់ហើយរត់ចេញពីកោះញែក ហើយ ចាំ! រត់ចេញ ពីកោះញែក រត់ចេញអញ្ចឹង មកក៏មកនៅគ្នាមកនៅតាមព្រៃតាមខ្សែ ជាមួយ ពួក១០៥ មួយរយអីហ្នឹងរស់នៅជាមួយ គ្នារហូតជាមួយពួកជនជាតិផ្នងហ្នឹងៗ ដល់ពេលរស់នៅជាមួយគ្នា អញ្ចឹងមកបាន....ហ្នឹងព្រាត់ ប្ដីព្រាត់ប្រពន្ធអស់ហើយហ្នឹងព្រាត់អស់ហើយហ្នឹង កូនក៏ ស្លាប់ ប្ដីក៏ព្រាត់ ដូចរឿងបណ្ដា ចារ្យអញ្ចឹងខ្ញុំប្រវត្តិខ្ញុំ ដល់រត់អញ្ចឹងមក...តែខ្ញុំចង់សួរពីរឿងបញ្ហាមួយដែលខ្ញុំ តស៊ូនៅក្នុងព្រៃដែលវេទនាពិបាកវេទនាហ្នឹងចង់ឲ្យលើករឿងហ្នឹងដែរ?

ដានី: ខ្ញុំចង់ឲ្យនិយាយតរហូតចាំខ្ញុំសួរបកវិញៗ

រឿន: អញ្ចឹងយើងនិយាយត្រឹមឆ្នាំ៧៩ហើយណាក្មួយ ដល់៧៩ហើយចាំ! ដល់៧៩ហ្នឹងត្រូវរត់ចេញពីកោះញែក ភូមិកោះញែក ស្រុកកោះញែកៗ ចាំ! នៅភូមិ...ឃុំស្រែល្អពាង ហើយ...ឃុំអីទេវិញ...គេហៅថា ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី គេហៅភូមិស្រែវង់ គេហៅភូមិស្រែវង់ៗ ទៅរត់ចេញមកក៏យួនធ្វើសកម្មភាព រត់បែកគ្នា បែកអីអញ្ចឹងទៅក៏កាលហ្នឹងរត់បែកគ្នាហើយបានមកចូលនៅ រស់នៅ ចេញពីមណ្ឌលគិរីមកនៅអូតូប ចេញពីអូតូបមក..ថាវេទនាស៊ីតែក្តួច៣ឆ្នាំ អត់អំបិល៣ឆ្នាំខ្ញុំៗ អត់ដែលមានអំបិលស៊ីទេ បាយក៏អត់មានអត់ដែលស្គាល់បាយ អត់ដែលស្គាល់ទឹកទេស្គាល់តែក្តួចហើយហ្នឹងដំឡូងប៉ុណ្ណឹងឯងទេ ប្រវត្តិពួកខ្ញុំរស់នៅពីមុន ទឹកក៏គ្មានផឹកដែរ ទឹកអត់ផឹកទេ ប្រវត្តិតស៊ូរបស់ខ្ញុំណែ៎! ថ្នាក់ខ្ញុំនិយាយឲ្យអស់កេរ្តិ៍អស់ខ្មាស់សូម្បីតែទឹកនៅក្នុងខ្លួនក៏គ្មានដែរក៏ត្រង់ផឹកដែរៗ បត់ដើតតូចមកផឹកទឹកហ្នឹងផឹក មិនអស់មិនហើយ មនុស្សស្រីនោះស្លាប់អាឡើង ហូ! ស្លាប់ច្រើនណាស់កាលនោះកាលរដ្ឋ៧៩ ចាំ! ស្លាប់ច្រើនណាស់ៗ

ដានី: ចុះពីអូតូមទៅណាទៀត?

រឿន: ពីអូតូមមក មកព្រៃស្អាក ចេញពីអូតូមមកព្រៃស្អាកយើងៗ មកពីស្អាកទៅ បានរស់នៅបាន៦ ៧ខែអញ្ចឹងទៅ ៧ខែបានឡើងឆ្នាំ៧៩ ៨០ ៨១ រស់នៅក្នុងអូតូមហ្នឹង ចាំ! ៨២បានចេញដំណើរមកនៅព្រៃស្អាក ៨២ ៨៣ ៨៤ខ្ញុំឡើងភ្នំណា៎ ឡើងហើយក៏យួនវៃត្រលប់មកវិញ ដាច់បាយដាច់ទឹកកូនខ្ញុំស្លាប់អស់ពីរដោយសាយួនវៃដាច់បាយដាច់ទឹក កូនរស់នៅសព្វថ្ងៃនេះដើរស៊ីតែស្លឹកឈើកុំអីមានទៅរស់ទេៗ

ដានី: បាទ! យ៉ាងម៉េចទៀតទៅ?

រឿនៈ	ដល់រួចអញ្ចឹងយើងឡើងភ្នំនៅឆ្នាំ៨៦ ៨៦ឡើងលើដីថៃហើយកាលហ្នឹង ឡើងលើដីថៃរស់នៅក្នុងតំបន់ឃុំស្រុករបស់ថៃ រស់នៅបានមើល ៨៦ ៨៧ ៨៨ ៨៩ ៩០ ៨៩ ៩០ រស់នៅបាន៦ ៧ឆ្នាំដែរ ។ ទៅក៏រស់នៅហ្នឹងទៅបានគេវៃដាច់អន្លង់វែងបានមករស់ នៅអន្លង់វែង ។ បានមករស់នៅក្នុងតំបន់ស្រុកអន្លង់វែងហ្នឹងទៅ ។

ដានីៈ	បាទ! យ៉ាំងម៉េចទៀត?

រឿនៈ	ចា៎! ដល់មករស់នៅក្នុងស្រុកអន្លង់វែងហ្នឹង ក៏ហ្នឹងរស់នៅបាន២ឆ្នាំក៏ប្ដីខ្ញុំស្លាប់ ប្ដីស្លាប់ទៅប្រវត្តិខ្ញុំវេទនាណាស់! ប្ដីស្លាប់ទៅសូម្បីតែដីមួយចង្អាមក៏អត់មានដែរ លក់មើលប្ដីខ្ញុំអស់ ៣ ៤ពាន់ដុល្លា មើលអត់ជាទៀតរហូតដល់ស្លាប់ អស់ផ្ទះអស់សម្បែងអាលីងឆិញហ្នឹងខ្ញុំ អត់មានសល់អីទេ ។ ទាល់រួចហើយបានខ្ញុំមកនេះគេព្រះអង្គទ្រង់កាន់ទៅក៏ឈឺមួយឆ្នាំទៀតឈឺមួយឆ្នាំមកបានព្រះអង្គកាន់ កាន់មកក៏ខ្ញុំមានប្រវត្តិថា ដូចមិនចង់ឲ្យនៅតាមស្រុកភូមិចង់ឲ្យដើរតាមព្រៃតាមផ្សែរអីអញ្ចឹងណាក្មួយ ។

ដានីៈ	អញ្ចឹងខ្ញុំចង់សួរមីងបកទៅក្រោយវិញ ។

រឿនៈ	ចា៎! បកទៅក្រោយវិញអាហ្នឹងជាប់បច្ចុប្បន្ន ។

ដានីៈ	ចុះមីងកាលពីក្មេងៗមីងចូលរៀននៅសាលាតាំងពីមីងអាយុប៉ុន្មានទៅ?

រឿនៈ	អាយុ៨ឆ្នាំ ។

ដានីៈ	អាយុ៨ឆ្នាំ?

រឿនៈ	ចា៎! អាយុ៨ឆ្នាំចូលរៀន ។

ដានីៈ	កាលហ្នឹងមីងចូលរៀននៅសាលាណាដែរ?

រឿនៈ	សាលានៅភូមិឬស្សី....នៅវត្តឬស្សីកែវ ។

ដានីៈ	នៅវត្តឬស្សីកែវ?

រឿនៈ	ចា៎!

ដានីៈ	មីងរៀនដល់ថ្នាក់ទី៩?

រឿនៈ	ទី៩ ។

ដានីៈ	កាលហ្នឹងមីងចេះអានចេះសរសេរអី..?

រឿនៈ	ចេះ!

ដានីៈ	ចេះដែរ?

រឿនៈ	ចេះមើលទាល់ដល់សព្វថ្ងៃ ថ្នាក់ទី៩បានរៀនបារាំងហើយហ្នឹងខ្ញុំ ។

ដានីៈ	កាលហ្នឹងមីងដូចថាថ្នាក់ទី៩ដែលមីងឈប់រៀននៅក្នុងឆ្នាំអីដែរ?

រឿនៈ ថ្នាក់ទី៩ខ្ញុំរៀនមិនដឹងជាឆ្នាំណាទេ? ភ្លេចរឿងឆ្នាំ ភ្លេចរឿងឆាំហើយមិនដឹងជាឆ្នាំណាទេ!

ដានីៈ បាទ! អត់អីទេអញ្ចឹង! អញ្ចឹងពេលដែលមីងឈប់រៀនហើយមីងមកធ្វើអីទៀតទៅ?

រឿនៈ ខ្ញុំឈប់រៀនមើលឆ្នាំ....៦៩ ។

ដានីៈ ៦៩?

រឿនៈ ចាំ! ៦៩ ។

ដានីៈ ពេលឈប់រៀនហើយមីងធ្វើអីទៀតទៅ?

រឿនៈ ខ្ញុំឈប់រៀនហើយក៏ឈប់រៀនហើយទៅនៅណាទេទៅនៅកំពង់ចាមទៅរៀនតកំពង់ចាមបាន៣ ឆ្នាំទៀត ។

ដានីៈ ទៅរៀនអីគេនៅកំពង់ចាម?

រឿនៈ ទៅរៀនចាក់រៀនម្ជុលអីហ្នឹង ។ ចាក់អាវ ចាក់អីអញ្ចឹង ។

ដានីៈ ទៅរៀនចាក់អាវចាក់ម្ជុល?

រឿនៈ ចាំ! ទៅនៅជាមួយគីមខ្ញុំនោះ គឹមខ្ញុំយកទៅនៅយកទៅលេងនោះ ចាំ! ទៅរៀននៅនោះ

ដានីៈ ទៅខាងកំពង់ចាមរៀនខាង ដូចថាខាងកាត់ដេរអញ្ចឹង?

រឿនៈ អត់ទេ! រៀនចាក់អាវហ្នឹង ចាក់អាវប៉ាក់កូនក្មេងនោះ ។

ដានីៈ បាទ! ទៅរៀននៅនោះបាន៣ឆ្នាំ?

រឿនៈ រៀន៣ឆ្នាំ ខ្ញុំទៅរៀនទៅលេងផងទេ ប៉ុនដល់ឃើញគេរៀន ចេះតែរៀនលេងហ្នឹងគេទៅ ។

ដានីៈ ទៅនៅហ្នឹងទៅនៅជាមួយបងប្អូនទៅផ្ទះគីម?

រឿនៈ ចាំ! គីមខ្ញុំ នៅមុខ មុខអីមុខអគ្គរទន្លេអនោះ ។

ដានីៈ អ! នៅខាងទន្លេអំនៅខាងព្រះអគ្គរហ្នឹង?

រឿនៈ ចាំ! ខ្ញុំនៅបន្ទាយសេះៗ

ដានីៈ បាទ! កន្លែងវាលវង់ប្រទាំងសេះ?

រឿនៈ ចាំ!

ដានីៈ អញ្ចឹងទៅនៅកំពង់ចាមបាន៣ឆ្នាំហើយមីងទៅនៅទៀត?

រឿនៈ ខ្ញុំរស់នៅកំពង់ចាមបាន៣ឆ្នាំខ្ញុំមកនៅផ្ទះ ។ ចាំ នៅផ្ទះទៀតឆ្នាំ៧១ហើយ ឆ្នាំ៧១ ៧២ ហ្នឹងខ្ញុំចូលទ័ហើយ ។ ឆ្នាំ៧១ហ្នឹងនៅកងនារីទេ នៅតាមភូមិឃុំកងចល័តអីអញ្ចឹងណាំ! ចាំ នៅ២ឆ្នាំ មួយឆ្នាំនៅកងចល័ត ។

ដានីៈ ចុះមីងកាលឆ្នាំ៧១មីងចូលកងនារីហ្នឹង ដូចថាកាលហ្នឹងមីងស្មគ្រ័ចិត្តចូលឬក៏យ៉ាងម៉េច?

រឿនៈ ខ្ញុំ?

ដានី៖ បាទ!

រឿន៖ ខ្ញុំដូចអត់មានស្មគ្រ័ចិត្តចូលទេបើអត់អត់ចង់ផង ។

ដានី៖ អត់ចង់ទេ!

រឿន៖ គេចុចចនុចឲ្យពប្រធានភូមិ ។

ដានី៖ អ! ប្រធានភូមិ?

រឿន៖ ចាំ! រើសចំនុចឲ្យប្រធានភូមិ ។

ដានី៖ កាលហ្នឹងប្រធានភូមិគេមកចុចហ្នឹងកាលហ្នឹងគេមកនិយាយប្រាប់មីងថាយ៉ាងម៉េចខ្លះ?

រឿន៖ គេមកធ្វើនយោបាយថា ឲ្យចូលនៅក្នុងទព័ព្រោះខ្ញុំនេះអ្នកចំរៀង ខ្ញុំណាំ! ចាំ! ឲ្យចូលក្នុងកងទព័នារីភូមិឲ្យខ្ញុំហ្នឹងទៅបង្ហាត់នៅតាមភូមិ តាមនារីៗតាមភូមិ ចាំ! នាតីយុទ្ធជនអីអញ្ចឹងទៅ ខាងសិល្បៈយប់ឡើងក៏បង្ហាត់ថ្ងៃឡើងក៏បង្ហាត់អញ្ចឹងទៅណា ។ ដល់ពេលគេយកទៅប្រលងឯណាឯណីគឺមានខ្ញុំហើយទៅកាលនោះ ។

ដានី៖ កាលនោះដោយសាមីងចេះច្រៀង?

រឿន៖ ចាំ!

ដានី៖ មីងដូចថា គេឲ្យមីងចូលទៅក្នុងកងនារីនោះដើម្បីបង្ហាត់យុវជនយុវនារីឲ្យច្រៀង...?

រឿន៖ ច្រៀង រាំរេកតាមភូមិនោះ ។

ដានី៖ កាលនោះដូចថា ប្រធានភូមិគេឈ្មោះអីទៅ?

រឿន៖ ឈ្មោះពូឈឹម...ឪពុកមិនដឹងឈ្មោះអីទេនោះ? ឈឹម ហើយថេរ ។

ដានី៖ ឈឹមហើយនិងថេរ?

រឿន៖ ចាំ! បងថេរ ដកសំអុនយើងនេះ នៅកែងសុទ្ធតែមេខ្ញុំហើយនោះ ។

ដានី៖ កាលហ្នឹងនៅខាងភូមិឬស្សីកែវហ្នឹងខាងកងទព័រំដោះគេគ្រប់គ្រងតាំងពីឆ្នាំណាទៅ?

រឿន៖ តាំងពីឆ្នាំ៧១មក ។

ដានី៖ តាំងពី៧១មក?

រឿន៖ ចាំ! ពួកតាអី ពួកតាខ្មៅតាខ្យងអីហ្នឹង ។ តាបែត តាអីហ្នឹង តាចាន់ថនតាអីហ្នឹង

ដានី៖ តាខ្មៅ តាបែត តាចាន់ថនអីហ្នឹងគាត់ធ្វើអីទៅតាហ្នឹង?

រឿន៖ សុទ្ធតែមេកម្មាភិបាលគេធំ ។

ដានី៖ កម្មាភិបាលគេ ។

រឿន៖ កម្មាភិបាលធំនៅស្រុកព្រែកប្រសប់ហ្នង ។

ដានី៖ នៅព្រែកប្រសប់?

វឿនៈ ចា៎!

ដានីៈ អញ្ចឹងកាលនោះគាត់ទៅដូចថាទៅចុចឈ្មោះមីងផមីងមកបង្ហាត់យុវជនយុវនារីកាលហ្នឹងមីងដូចអត់ចង់ចូលទេ?

វឿនៈ ខ្ញុំដូចថា មិនចង់ដែរហ្នឹងប៉ុនដល់ពេលគេធ្វើនយោបាយខ្ញុំទៅក៏ទៅទៅណាក្មេងណា៎! ដូចថាឲ្យស្មគ្រចិត្តប្តេជប្តូរតស៊ូដើម្បីយកឈ្នះយកយកទឹកអត់ទេ អត់មានទឹកឃើញអញ្ចឹងទេ ទៅម៉ាសប្បាយហ្មង ។

ដានីៈ កាលហ្នឹងមីងអាយុប៉ុន្មាន?

វឿនៈ ខ្ញុំអាយុប៉ុន្មានទេ....កាលនោះខ្ញុំអាយុ១៨ឆ្នាំ ។

ដានីៈ ១៨?

វឿនៈ ចា៎!

ដានីៈ ចុះឪពុកម្តាយមីងគាត់ថាម៉េចដែរពេលដែលគេចុចឈ្មោះមីងឲ្យចូលទៅបម្រើកន្លែងកងនារីនោះ?

វឿនៈ ម៉ែខ្ញុំមិនចង់ឲ្យទៅដែរប៉ុន្តែដល់ចំនុចគេត្រូវធ្វើអញ្ចឹងហើយយើងទៅទៅធ្វើម៉េច ទៅតាមដំណើរកូនអញ្ចឹងទៅណា ។

ដានីៈ កាលនោះមីងទៅតែម្នាក់ឯងឬក៏មានដូចថាមិត្តភក្តិអ្នកស្រុកអ្នកភូមិឬក៏អ្នកជិតខាងមីងទៅដែរ?

វឿនៈ អត់មានទេ ខ្ញុំតែម្នាក់ឯង ។

ដានីៈ តែម្នាក់ឯងទេ?

វឿនៈ ចា៎! អត់មានពួកអត់មានម៉ាកទេ គ្មាននរណានាំទៅទេទៅម្នាក់ឯង ។ តស៊ូ៣៥ ៣៦ឆ្នាំ ហើយតស៊ូនោះ ។

ដានីៈ អញ្ចឹងពេលដែលមីងចេញ ដូចថាចូលទៅក្នុងបម្រើបដិវត្តន៍ហ្នឹង មីងចូលដំបូងមីងនៅក្នុងភូមិឬស្សីកែវហ្នឹងឬក៏ទៅកន្លែងណា?

វឿនៈ ចូលដំបូងនៅឬស្សីកែវហ្នឹងនៅមួយឆ្នាំ ។

ដានីៈ នៅមួយឆ្នាំ?

វឿនៈ ចា៎!

ដានីៈ នៅមួយឆ្នាំហ្នឹងមីងបង្ហាត់បង្រៀនច្រៀងដល់យុវជនយុវនារីក្រៅពីហ្នឹងធ្វើអីទៀត?

វឿនៈ ពេទ្យ ។

ដានីៈ ធ្វើពេទ្យ?

វឿនៈ ចា៎!

ដានី៖ ធ្លើពេទ្យហ្នឹងមីងមានបានរៀនអីនៅកន្លែងណាដែរ?

រឿន៖ ខ្ញុំរៀន ខ្ញុំរៀននៅកន្លែងភូមិឃុំហ្នឹង ។

ដានី៖ នៅភូមិឃុំហ្នឹង?

រឿន៖ ចាំ! រៀនពេទ្យហ្នឹង ពេទ្យខាងស្លថ្នាំផង និងពេទ្យខាងចាក់ផង ។

ដានី៖ ក្នុងឆ្នាំ៧១ហ្នឹង?

រឿន៖ ចាំ! អត់ទេ! ឆ្នាំ៧២ ។

ដានី៖ ឆ្នាំ៧២ ។ កាលមីងចូល៧១ហ្នឹង មីងចូលខែ៥ ថ្ងៃ៥ ឆ្នាំ៧១?

រឿន៖ ចាំ! ថ្ងៃ៥ ខែ៥ ។ ប៉ុនទៅដំបូងគេឲ្យលេងតែសិល្បៈដើរបង្ហាត់ក្មេងតាម ក្មេងៗក្រមុំៗ ដូចគ្នា ដល់ឆ្នាំ៧២បានគេចូលនៅខាងពេទ្យផង ដល់ពេលគេមានហាតសិល្បៈឯណាបើគេយក យើងទៅព្រោះនៅក្នុងភូមិគេចេះហើយយើងបង្ហាត់មួយឆ្នាំជាងហើយ ។

ដានី៖ ចុះដំបូងមីងចេះសិល្បៈហ្នឹងមកពីណាបានមីងចូលទៅដំបូងមីងបង្ហាត់គេ?

រឿន៖ អត់ដឹងផង គេបបួលទៅប្រូតលេងក៏ទៅប្រូតគេមួយថ្ងៃទៅច្រៀងលេងជាមួយបងយូនហ្នឹងក៏គេ នេះចំនុចគេ ចុះសមាគមនោះ ខ្ញុំច្រៀងលេងដូចដុះមកហ្នួងខាងច្រៀងនោះ ។ ចាំ! តាំងពីក្មេង រហូតដល់ចាស់ល្មោនក៏ខ្ញុំលេងស្អីក៏ខ្ញុំលេងចេះម៉ាសព្វ ។

ដានី៖ ចុះពេលដែលមីងទៅបង្ហាត់សិល្បៈច្រៀងអីហ្នឹងកាលហ្នឹងមីងបង្ហាត់យ៉ាងម៉េចខ្លះទៅសិល្បៈ ច្រៀងអីហ្នឹង?

រឿន៖ សិល្បៈដូចថា ក្រុមកុមារឈានមុខកុមារាកុមារីពួកយើងជាពេទ្យបដិវត្តន៍សិល្បៈពួកខ្ញុំលេង ទ្រុឌ លេងរឿងអីអញ្ចឹងទៅណា ។

ដានី៖ លេងទ្រុឌលេងរឿងដូចថាលេងរបៀបយ៉ាងម៉េចដែរ?

រឿន៖ របាំទ្រុឌយើងនោះណា ។

ដានី៖ បាទ! ចុះចំរៀងអីមីងនៅចាំចំរៀងគេច្រៀង?

រឿន៖ ចាំ! តែគ្រាន់តែថាវែងៗពេកខ្ញុំអត់សូវចាំដែរដល់ឥឡូវ ។ ប៉ុនមួយកំណាត់ៗ ។

ដានី៖ បាទ! មីងចាំខ្លះមីងអាចជួយជំរាបប្រាប់ខ្ញុំ...ធ្លើបទបនចមីងចាំត្រឹមណា?

រឿន៖ ហ៎! មិនកើតទេ!

ដានី៖ បាទ! អត់ទេ គ្រាន់តែមីងនិយាយក៏បានដែរមើលមីងដូចថា ចំរៀងហ្នឹងគេច្រៀងថាម៉េច ៗ ខ្លះ? ដូមមួយបទមើលមីង ។ បើអញ្ចឹងភ្លេចអត់មានពីណាដឹងបទចំរៀងអីហ្នឹងទៀតទេ អស់ពី មីងទៅ?

រឿន៖ ខ្ញុំឈ្អិនហើយអារឿងសិល្បៈនោះ ។ ចាំ! ទើឈប់លេងភ្លេងកាលបង់ឆ្នាំនោះទេ ។

ដានី: មីងដូចថា ជួយបង្ហើបប្រាប់ពួកខ្ញុំបន្តិចមើល ។

វឿន: បង្ហើប្រាប់ម៉េចនោះ?

ដានី: ដូចថាច្រៀងចំរៀងកាលពេលនោះមីងបង្ហាត់នោះ ។

វឿន: ពីបទនោះ?

ដានី: បាទ! បទកាលមីងបង្ហាត់កុមារាកុមារីហ្នឹង ។

វឿន: គិតទៅមិនរួចម៉េចទេ!

ដានី: មីងរកនឹកមើលអាណាបទមីងចាំជាងគេ?

វឿន: ចាំតែទាំងអស់នោះណា ប៉ុនមិនបានចាំទាំងអស់ៗនោះណា ។

ដានី: បាទ! ចំខ្វះក៏បាន ។

វឿន: ចាំតែក្បាលបន្តិចៗហ្នឹង ។ ហឺ! ច្រៀងលេងកណ្តាលលើគោកម៉េចទេ ។

ដានី: អត់អីទេមីងជួយបន្តិចមើល?

វឿន: ជួយយាយៗដូចគ្នាទេសុទ្ធតែកំលោះៗ....ហើយយាយជីនោះ....

ដានី: អត់ទេដូចថាពួកខ្ញុំក្មេងសាក្រោយអត់ទាន់កាលពីចំរៀងហ្នឹងចង់ដឹងថាចំរៀងហ្នឹងវាច្រៀងថាម៉េចខ្វះ?

វឿន: មិនដឹងថាម៉េចទៅ? អស់សំណើចណាស់លោក...មិនកើតទេអីក្មួយ...

ដានី: អញ្ចឹងភ្លេចអស់ហើយមីង មីងច្រៀងទៅហ្នឹងអាងខ្ញុំយកទៅកត់ត្រាទុកអី បន្សល់ខ្វះឲ្យក្មេងៗបានដឹងបានឮផង សំណូមពរមីងបន្តិចទៅ...

វឿន: កាលនៅអន្លង់វែងបារាំងវាឲ្យខ្ញុំច្រៀងអញ្ចឹងដល់ទៅច្រៀងអញ្ចឹងវានាំគ្នាស្ទុះផ្ទេតក្រោកឡើងទះដៃព្រូ ខ្ញុំថាអ! ខ្ញុំឈប់ហើយចុះ ។ អត់ទេ! អត់ទេ! ម្តងទៀតៗ

ដានី: ឥឡូវមីងនិយាយចំណងជើងដែលគេបទចំរៀងដែលគេចំនងជើងបទស្អីខ្វះទៅដែលមីងធ្លាប់បង្រៀនពីមុនមកនោះ?

វឿន: អ! ច្រើនណាស់ក្មួយអើយ ច្រើន ។

ដានី: បាទ! ឥឡូវខ្វះក៏បាន?

វឿន: អត់អីទេ!...ច្រៀងយ៉ាងម៉េចទេហ៎!

ដានី: ឥឡូវចាំក្រោយក៏បាន ឥឡូវខ្ញុំសួរតទៅទៀតចាំ ចប់ចាំច្រៀងតក៏បាន ។ អញ្ចឹងបន្ទាប់មីងបង្ហាត់បង្រៀនអ! កុមារាកុមារីយុវជនយុវនារីហ្នឹង បង្ហាត់មួយឆ្នាំគេចាត់មីងឲ្យមករៀនខាងពេទ្យខាង...?

វឿន: ចា៎! ពេទ្យស្មប្ញ ។

ដានី៖ ស្លថ្នាំវិញ?

រឿន៖ ចាំ!

ដានី៖ ចុះពេទ្យដែលមីងទៅរៀនជាមួយគេកាស្លថ្នាំស្លអីហ្នឹងពេទ្យហ្នឹងមកពីណាមកកាលមក បង្រៀនហ្នឹង?

រឿន៖ គេនៅណាបង? ទីមួយបងស៊ូ ដល់ផ្លាស់ពីបងស៊ូទៅបានបងគា បងគា បងសៀននោះ ដល់មិត្តស៊ូនេះនៅហ្នឹងទេឥឡូវនឹង នៅណានៅកំពង់គោ

អ្នកជិតខាង៖ នៅកំពង់គោនៅគាម៉ៅ.

ដានី៖ នៅគាម៉ៅ?

រឿន៖ បងស៊ូហ្នឹងនៅគាម៉ៅទេឥឡូវហ្នឹង ។

ដានី៖ ស្រី?

រឿន៖ ចាំ! ស្រីទេមិត្តស៊ូហ្នឹង ។

ដានី៖ កាលមីងរៀនស្លថ្នាំរៀនពេទ្យហ្នឹងគ្នាប្រហែលជាប៉ុន្មាននាក់?

រឿន៖ គ្នាប៉ុន្មានទេ គ្នា១៩នាក់ ។

ដានី៖ ១៩?

រឿន៖ ចាំ! ១៩នាក់ ។

ដានី៖ ១៩អញ្ចឹងអ្នកសិល្បៈទាំងអស់ហ្នឹងគេឲ្យមករៀនពេទ្យទាំងអស់ហ្នឹងឬក៏គេជ្រើសរើសយ៉ាង ម៉េចដែរអ្នកមកហ្នឹង?

រឿន៖ អ្នកនៅសិល្បៈហ្នឹងបានតែ៦នាក់ទេចូលធ្វើពេទ្យហ្នឹង ក្រៅពីហ្នឹងគេនៅតាមភូមិមនុស្សរាប់រយ ណា ហាត់ម្តង១ ។

ដានី៖ កាលនោះមីងប្រាប់ខ្ញុំថាមាន ដូចជាមានជាសមាគមនារីអញ្ចឹង...?

រឿន៖ មាន!

ដានី៖ សមាគមនារីហ្នឹងដូចថាជាសមាគមនារីភូមិ ឬក៏ឃុំ?

រឿន៖ នារីយ សមាគមនារីឃុំដែលចិញ្ចឹមមាន់ និងធ្វើច្បាស្តី ច្បាអីហ្នឹងណា សមាគមគេធ្វើអញ្ចឹង ហ្នឹងសមាគមដើរតួរប្រជាជនដើរច្រូតស្រូវប្រជាជនអីហ្នឹង ជាមួយបងថេរ បងថេរសំអុន ហ្នឹង ។

ដានី៖ ឈ្មោះអុន ឈ្មោះថេរហ្នឹងស្រី ប្រុស?

រឿន៖ ស្រីទេ!

ដានី៖ ស្រី!

រឿនៈ ចាំ! ខ្ញុំឃើញឈ្មោះហ្នឹងពីម្សិលដែរ ។

ដានីៈ បាទ! ចុះថេរ អុនហ្នឹងគាត់នៅណាស្រុកកំណើតគាត់?

រឿនៈ ស្រុកកំណើតគាត់នៅកែងនេះ...នៅព្រែកដីក ។

ដានីៈ ព្រែកដីក ។ ចុះមីងរៀនពេទ្យហ្នឹងរៀនបានរយៈពេលប៉ុន្មាន?

រឿនៈ មួយឆ្នាំ ។

ដានីៈ រៀនមួយឆ្នាំ?

រឿនៈ ចាំ!

ដានីៈ រៀននៅកន្លែងតាម៉ៅហ្នឹង?

រឿនៈ អត់ទេ! នៅឬស្សីកែវហ្នឹង ។

ដានីៈ រៀននៅឬស្សីកែវហ្នឹង ។ ដល់ពេលរៀនពេទ្យចប់ហើយធ្វើអីទៀតទៅ?

រឿនៈ រៀនពេទ្យចប់ហើយបានគេបញ្ជូនទៅមណ្ឌលគិរី ។

ដានីៈ បានន័យថា មីងដូចថារៀន រៀនពេទ្យចប់ហើយ.... ។ ចុះបន្ទាប់ពីរៀន ដូចថារៀនពេទ្យចប់ទៅមីងដូចថានៅធ្វើនៅកន្លែងណា?

រឿនៈ រៀនពេទ្យចប់ទៅ អ! រៀនពេទ្យមិនទាន់បានចប់ស្រួលបួលផងគេបញ្ជូនទៅមណ្ឌលគិរី ។

ដានីៈ កាលនោះមីងគេបញ្ជូនមីងទៅមណ្ឌលគិរីហ្នឹងគេបញ្ជូនមីងទៅនៅក្នុងឆ្នាំណា?

រឿនៈ ឆ្នាំ៧៣ ។

ដានីៈ ៧៣បញ្ជូនទៅមណ្ឌលគិរី?

រឿនៈ ចាំ!

ដានីៈ បានន័យថា គេបញ្ជូនមីងទៅមុនបែកភ្នំពេញឆ្នាំ៧៥ទៀត?

រឿនៈ មុន មុន២ឆ្នាំទៅនេះ បញ្ជូនទៅ មើលឆ្នាំ៧៣ ហេ! ឆ្នាំ៧៤ទេ ទៅរស់នៅសខសាន្តបានមួយឆ្នាំ បានទៅនៅកោះញែកគេដាច់ ភ្នំពេញ ។

ដានីៈ បើតាមខ្ញុំដឹងតាឈិនហ្នឹងបន្ទាប់ពីបែកភ្នំពេញឆ្នាំ៧៥ហើយបានគេបញ្ជូនគាត់ទៅមណ្ឌលគិរីកងពល៩២០ ។

រឿនៈ ចាំមើលណាក្នុយប្រវត្តិខ្ញុំណាស់ គេបញ្ជូនមក មកនៅមណ្ឌលគិរី តែពួកខ្ញុំមកនៅក្រចេះ ចាំមកនៅក្រចេះបាន៦ខែពីដើមដំបូងដែលប្រវត្តិដែលខ្ញុំតស៊ូទៅនៅក្នុងគេធ្វើសង្គ្រាមចូលភ្នំពេញខ្ញុំអត់និយាយទេអាហ្នឹងវារយៈខ្លីខ្ញុំបញ្ជូនបាយជញ្ជូនទឹកជញ្ជូនទឹកធ្វើនីរសារអីទៅនៅតំបន់អ! ជិតទីក្រុងភ្នំពេញនៅតាខ្មៅខ្ញុំចូលភ្នំពេញដែរ ។ ដល់រួចមកខ្ញុំអត់និយាយទេ រឿងហ្នឹងព្រោះវារយៈខ្លីដែរណា ក៏ខ្ញុំគេបញ្ជូនមកក្រចេះ ដល់បញ្ជូនមកក្រចេះនៅប្រហែលបាន ៦

៧ខែហ្នឹងបានគេបញ្ជូនទៅមណ្ឌលគិរីតែអត់នៅកងពូឈិនហ្នឹងទេខ្ញុំអត់ទាន់នៅទេ   ខ្ញុំនៅភូមិភាគ ៣០៤ ។

ដានី: បាទ! ភូមិភាគ៣០៤ ។

រឿន: ចា៎!

ដានី: កាលហ្នឹងកាលដំបូងមីងធ្លាប់ដូចថា ពេលចូលវៃភ្នំពេញអីមីងធ្លាប់ទៅធ្វើជាអ្នក...?

រឿន: នីរសា ។

ដានី: នីរសា ។ នីរសាឲ្យពីណាគេ?

រឿន: នីរសាឲ្យពួកទ័ពដែលរស់នៅជាមួយគ្នានោះណា ។

ដានី: បានន័យថាកាលមីងធ្វើនីរសាកាលវៃចូលភ្នំពេញហ្នឹងនៅក្នុងកងអី កងធំ កងតូច វរៈ?

រឿន: កាលហ្នឹងវរៈសេនាធំ ប៉ុនគាវស្លាប់បាត់ហើយ ។

ដានី: បាទ! ឈ្មោះអីទៅ?

រឿន: ឈ្មោះពូសៀក ។

ដានី: ឈ្មោះសៀក?

រឿន: ចា៎! ឈ្មោះដើមគាត់ឈ្មោះសៀក ឈ្មោះបដិវត្តន៍មិនដឹងឈ្មោះអី?

ដានី: សៀកហ្នឹងអ្នកនៅណាដែរ?

រឿន: អ្នកព្រាំងដូង ។

ដានី: អ្នកព្រាំងដូងខាងស្រុកស្ទឹងត្រោង?

រឿន: ចា៎! ខាងព្រាំងដូងនោះ ខ្ញុំស្គាល់តែពូសៀកហ្នឹងមួយ ។

ដានី: វរៈសេនាធំលេខប៉ុន្មានដែរកាលនោះ?

រឿន: វរៈសេនាធំភូមិភាគ៣០៤ហ្នឹងឯង ។

ដានី: ចុះកងពល?

រឿន: អ! វរៈណាធំ...មនដឹងវរៈប៉ុន្មានទេ? វរៈលេខប៉ុន្មានទេខ្ញុំភ្លេចហើយនេះរឿងវរៈប៉ន្តែបើ កងពលភូមិភាគ៣០៤ ។

ដានី: នរណាគេប្រធានកងពល?

រឿន: គាចាន់ថន ។

ដានី: គាចាន់ថន ។

រឿន: ប្រធានសិល្បៈពួកខ្ញុំនោះ អានាំពួកតែកងទ័ពស្រីៗនោះទៅសមរភូមិនោះ ។ ចា៎!ពួកសិល្បៈហ្នឹងទេ ទៅលេង ដូចថាមហាសន្និបាតអីអញ្ចឹងតែគ្រាន់តែថាយកខ្ញុំកាលនោះវារហ័ស ចា៎!

យកធ្វើនីរសាកាលនោះបានប៉ុន្មានខែ៣ ៤ខែក៏ដកខ្ញុំពីកន្លែងកងទ័ពនោះមកវិញ មកចូលសិល្បៈវិញ ។

ដានី: អញ្ចឹងកាលទៅវៃនៅភ្នំពេញអីហ្នឹងគាចាន់ជនអ្នកនាំទៅ?

រឿន: ចា៎! នាំទៅត្រឹមស្អី នាំត្រឹមណាទេ បញ្ជូនទៅទៀតមិនសូវស្គាល់ភូមិស្រុកគេទេកាលនោះ ។ ចា៎! ប៉ុនខ្ញុំចូលនៅខាងបន្ទាយសេះពីមុនយើងមិនវៃកំពង់ចាមមុន ចូលវៃបន្ទាយសេះមុន ចា៎! ឡើងពន្ទ័នៅបន្ទាយសេះ នៅក្នុងនៅបន្ទាយសេះហ្នឹងក៏ខ្ញុំចូលបានចូលដែរ ចូលនៅក្នុងបន្ទាយសេះហ្នឹងទៅបានលង់ខ្លួន ទាហ៊ានវាកំពុងសប្បាយវាប្រុងរត់ទៅភ្នំពេញទៀត កំពុងសប្បាយចិត្តវាដុបលាងចូលទៅដល់ជិតបន្ទាយនោះក៏មានយាយម្នាក់ប្រហែលចែហ្នឹងទៅវៃខ្ញុំចេញពីបន្ទាយ កុំអីទាហ៊ានចាប់អាកបាត់ហើយ ។

ដានី: ខាងទាហ៊ានលន់ ណុល?

រឿន: ចា៎! ចូល ចូលលង់ខ្លួនណា ចូលក្នុងខ្មែរក្រៀមគេ កាលនោះស្លៀកខោខ្លីប៉ុណ្ណេះ កាត់អាវប៉ុណ្ណេះ កាត់សក់ដូចប្រុសអញ្ចឹង ។

ដានី: កាលហ្នឹងម៉េចបានមីងចូលទៅក្នុងកន្លែងបន្ទាយទាហ៊ានលន់ ណុលនោះ?

រឿន: ចេះតែដើរ គេឲ្យដើរស៊ើបតាមហ្នឹងអញ្ចឹងណា ស៊ើបវាមានទាហ៊ាន ឬក៏មានខ្មែរក្រៀម ឬក៏មានផែនការចេញក្រៅអញ្ចឹងណា យើងស៊ើបតាមប្រជាជនហ្នឹង ប៉ុនចេះតែដើរទៅមានទៅដឹងបន្ទាយឯណាមានទៅដឹងទេ ។

ដានី: កាលហ្នឹងដូចថាមីងនៅក្នុងកងស៊ើបការ បាបមីងដើរចូលទៅស៊ើបអញ្ចឹង?

រឿន: អត់ទេ! ផែងអញ្ចេះកាលនោះអ! ពួកខ្ញុំខាងជញ្ជូនបាយ ។ ជញ្ជូនបាយឲ្យទព្វតាមខ្មែរក្រៀមអីអញ្ចឹងណា ដល់ជញ្ជូនទៅ ទៅគេថា ស៊ើប១ផងក្រែងមានទាហ៊ានអីដូចថាវាមានវាប្រុងថាអត្តាមានចុះមានអីអញ្ចឹងណា រួចខ្ញុំចេះតែដើរ ដើរទៅក៏ចំបន្ទាយហ្នឹងហ្នុងទៅ ។

ដានី: បន្ទាយ បន្ទាយនៅកន្លែងណាទៅបន្ទាយ?

រឿន: បន្ទាយសេះ ។

ដានី: បន្ទាយនៅកន្លែងបន្ទាយធំហ្នឹង?

រឿន: អ! កន្លែងបន្ទាយសេះស្អីទន្លេអំហ្នឹង នៅពីក្រោយទន្លេអំហ្នឹង ។

ដានី: ក្រោយមកបានគេបញ្ជូនមីងទៅខ្មែរក្រៀមនៅភ្នំពេញទៀត?

រឿន: ទៅនៅភ្នំពេញបានប៉ុន្មានទេ បានមកខេត្តមិនទាន់បានមួយខែទេផង ។

ដានី: ទៅបានមួយខែទៅយ៉ាងម៉េចគេដាច់ភ្នំពេញ?

រឿនៈ ដាច់ទៅណា ដាច់ទៅបាននាំគ្នាទៅមណ្ឌលគិរីទៅ ។ គេបញ្ជូនមកក្រចេះវិញមក បានទៅមណ្ឌលគិរី ។

ដានីៈ អញ្ចឹងពេលដាច់ភ្នំពេញឆ្នាំ៧៥ ហ្នឹងគេបញ្ជូនមីងទៅមណ្ឌលគិរី?

រឿនៈ ចា៎!

ដានីៈ កាលហ្នឹងកាលគេបញ្ជូនមីងទៅមណ្ឌលគិរីហ្នឹង កាលហ្នឹងគេបញ្ជូនទៅរបៀបជានៅក្នុងបញ្ជូនទៅយ៉ាងម៉េចទៅ?

រឿនៈ បញ្ជូនទៅតាមឡានណាក្មួយ ។

ដានីៈ តាមឡាន ប៉ុន្តែកាលមីងទៅហ្នឹង ទៅជាមួយកងណាក្រុមណាអីដែរ?

រឿនៈ ទៅក្រុមណាទេណែ៎! ជាមួយ...មិនដឹងស្លាប់បាត់ហើយដឹងពួកបងណេនបងណេអី បងនាន បងណេ បងរី បងរីនៅចំបក់ហ្នឹងទេតឡូវហ្នឹង ។ បងរី ណាមួយទៀត...? មិត្តអាន មិត្ត អីច្រើនណាស់កងវរៈពួកខ្ញុំណា៎!

ដានីៈ សុទ្ធតែនារីៗគេបញ្ជូនទៅដំបូង?

រឿនៈ ចា៎! តែសុទ្ធតែនារីទេ អត់មានយុទ្ធជន សុទ្ធតែនារីហ្នុង ។

ដានីៈ នារីដែលគេបញ្ជូនទៅមណ្ឌលគិរីហ្នឹងគេ បញ្ជូនទៅជាវរៈឬកងធំឬក៏យ៉ាងម្ដេចដែរ?

រឿនៈ ម៉ាកងពលហ្នុង ។

ដានីៈ ម៉ាកងពលហ្នុង?

រឿនៈ ចា៎! ម៉ាកងពលបងឈិនហ្នឹងហ្នុង ។

ដានីៈ កាលហ្នឹងទៅជាមួយឈិនហ្នឹងដែរ?

រឿនៈ ចា៎! ប៉ុន្តែបងឈិនគាត់ទៅមុនៗ ពួកខ្ញុំគេបញ្ជូនមកក្រចេះ មកក្រចេះនៅមួយខែ អ!ដាច់ភ្នំពេញហើយគេបញ្ជូនមកនៅក្រចេះ ដល់បញ្ជូនមកនៅក្រចេះ បានគេបញ្ជូនពីក្រចេះមកនៅមណ្ឌលគិរីទៀត ប៉ុណ្ណឹង ។

ដានីៈ កាលហ្នឹងមីងដឹងថា ហេតុអីបានគេបញ្ជូនមីង ពីភ្នំពេញទៅមណ្ឌលគិរី?

រឿនៈ អត់ដឹងដែរ? រឿងគេបញ្ជូនទៅនោះដូចថា មិនដឹងសោះហ្នុងទៅតែតាមគេ ។

ដានីៈ បញ្ជូនកាល កាលក្រុមរបស់មីងដែលជានារីហ្នឹងគេអត់បញ្ជូនទៅជាមួយពួកបុរសៗទេ?

រឿនៈ បុរសគេទៅមុន គេបើកផ្លូវមុនៗ ពួកកងពិសេសគេទៅមុនហើយ ។ ប៉ុនកាលនោះអត់ទាន់មានឈ្មោះបង០៦ហ្នឹងអត់ស្គាល់អត់ទាន់អីទេណា! ខ្ញុំស្គាល់តែក្រុមបងឈិនទេ ទៅដល់មណ្ឌលគិរីនោះគេយកខ្ញុំទៅដាក់នៅសិល្បៈថែមវិញទៀត ។ ចេញមិនរួចទេ ពីរាំហើយនិងច្រៀងនោះ ។

ដានី៖ ចុះមីងកាលគេបញ្ជូនពីភ្នំពេញមក មកនៅក្រចេះសិន?

រឿន៖ ចាំ! មកនៅក្រចេះ ។ មកនៅក្រចេះ២ ៣ខែហ្នឹង ។

ដានី៖ កាលនៅក្រចេះហ្នឹងនៅកន្លែងណាទៅ?

រឿន៖ នៅកន្លែងស្អី កន្លែងកុនមហាកំពែងអីម៉េចនោះ អារោងកុនមហាកំពែង?

ដានី៖ រោងកុនមហាកំពែង ។

រឿន៖ ចាំ!

ដានី៖ នៅកន្លែងណាទៅរោងកុនមហាកំពែងនោះ?

រឿន៖ ដឹងអត់ស្គាល់នោះ ខ្ញុំទៅឥឡូវក៏អត់ស្គាល់ដែរ ។

ដានី៖ នៅទីរួមខេត្តហ្នឹងហ្នង ឬក៏ម៉េច?

រឿន៖ ចាំ! នៅក្រចេះហ្នឹងហ្នង ។

ដានី៖ ហេតុអីបានគេឲ្យមីងនៅក្រចេះហ្នឹងរយៈពេល៣ ៤ខែហ្នឹង?

រឿន៖ គេដាក់សិន ដូចថាគេ អ្នកកងទ័ពទៅហ្នឹងគេថា ត្រួសដ្ឋវមុនណា ត្រួសដ្ឋវមុនតើវាយ៉ាង ណាយ៉ាងណីហើយឲ្យយុទ្ធជនហ្នឹងទៅធ្វើផ្ទះធ្វើសំបែងមុន ទៅដល់នៅនោះគ្មានមានប្រលោះ អីមួយទេក្មួយ សុទ្ធព្រៃទៅនៅដេកកណ្តាលព្រៃសុទ្ធសាតហ្នងហើយណា ចាំ! នៅមណ្ឌល គីរីណា ។

ដានី៖ អញ្ចឹងកាលមីងមកនៅស្នាក់នៅកន្លែងក្រចេះហ្នឹង គ្នាប៉ុន្មាននាក់ទៅកន្លែងកងនារីរបស់មីង ហ្នឹង?

រឿន៖ ជាង១០០នាក់ ។

ដានី៖ ជាង១០០នាក់?

រឿន៖ ចាំ!

ដានី៖ កាលនោះប្រធានឈ្មោះអីទៅ?

រឿន៖ ប្រធានខ្ញុំឈ្មោះយាយអាន ហើយប្រធានធំមិនដឹងពីណាអត់ដឹងផង ។

ដានី៖ ១០០នាក់ដែលកងនារីរបស់មីងហ្នឹងឈ្មោះអីគេ?

រឿន៖ ឈ្មោះមិត្តអាន!

ដានី៖ មិត្តអាន?

រឿន៖ ចាំ! មិត្តអាន និងមិត្ត នឿន ។

ដានី៖ មិត្តអាន មិត្តនឿន?

រឿន៖ ចាំ!

ដានី៖ មិត្តអានមិត្តឿនហ្នឹងអ្នកនៅណាដែរ?

រឿន៖ អ្នកនៅសៀមរាប ។

ដានី៖ អ្នកនៅសៀមរាប បានន័យថាគាត់ជាប្រធាន ដូចថាប្រធានស្នឹទៅកង១០០នាក់ជាង ?

រឿន៖ ប្រធានធំមែនទែនខ្ញុំអត់សូវស្គាល់ទេអត់ស្គាល់គេទេ ខ្ញុំស្គាល់តែប្រធានតាមកងណា ។ ប្រធានតាមកងព្រោះខ្ញុំទើបចូលថ្មី ព្រោះខ្ញុំចេញពីភូមិនេះទៅចូលថ្មីមិនទាន់បានស្គាល់គេស្រួល បួលផងគេបញ្ជូនទៅ ស្គាល់តែប្រធានក្រុម និងប្រធានកងតែប៉ុណ្ណឹង ព្រោះវានៅដោយឡែក ពីគ្នាឈ្មោះ....ឈ្មោះបងអីនៅចំបក់នោះណា បងអីទេវៃ....

ដានី៖ មីងនិយាយថា ឈ្មោះបងអាន បងឿនហ្នឹងគាត់ប្រធានអីគេ?

រឿន៖ ប្រធានវរៈ ។

ដានី៖ ប្រធានវរៈ?

រឿន៖ ចា៎! កងវរៈ ។

ដានី៖ វរៈសេនាធំវរៈសេនាតូច?

រឿន៖ ហេ! មើលមិត្តឿនហ្នឹងប្រធានក្រុម អ! ឿនហ្នឹងប្រធានក្រុម បងអានហ្នឹងប្រធានវរៈ វរៈសេនាតូច ។

ដានី៖ វរៈសេនាតូច?

រឿន៖ ចា៎! ខាងនារី ខាងផ្នែកនារី ។

ដានី៖ វរៈសេនាតូចខាងផ្នែកនារី ។

រឿន៖ ចា៎!

ដានី៖ ក្នុងអញ្ចឹងម៉ាកងនារីស្នាក់នៅក្រចេះហ្នឹងមាវរៈសេនាតូច?

រឿន៖ វរៈសេនាធំ តែវានៅដាច់ដោយក្រុមៗ ក្រុមនេះ ក្រុមនោះគឺនៅនោះៗ...អញ្ចឹង ។

ដានី៖ ចុះវរៈសេនាតូចផ្សេងទៀតនៅណាទៅ?

រឿន៖ នៅកក្បែរគ្នា ។

ដានី៖ នៅក្រចេះហ្នឹងដែរ ។

រឿន៖ នៅក្រចេះដូចគ្នា ។

ដានី៖ ចុះប្រធានវរៈសេនាធំឈ្មោះអីទៅ?

រឿន៖ ប្រធានវរៈសេនាធំមិនដឹងឈ្មោះអីទេ? បងនាន..ម៉េចអញ្ចេះ បងណេន ។

ដានី៖ បាទ?

រឿន៖ ឈ្មោះបងណេនវរៈសេនាធំ ។

ដានី៖ ឈ្មោះណោន?

វឿន៖ ចាំ! ឈ្មោះណោនហ្នឹងនៅចំបក់ណា ។

ដានី៖ នៅចំបក់?

វឿន៖ ចាំ!មិនដឹងដីដូនដីតាគាត់ឈ្មោះអីទេ តែដឹងថា គាត់ឈ្មោះបងណោនអញ្ចឹងហ្មងវរៈសេនាធំ ។

ដានី៖ ចុះមីងកាលមីងស្នាក់នៅក្រចេះហ្នឹងគេឲ្យមីងធ្វើអីខ្លះទៅរយៈពេល២ ៣ខែហ្នឹង?

វឿន៖ អត់ធ្វើអីទេ ដេកតែស៊ី ។ អត់ឲ្យធ្វើអីផង ។

ដានី៖ គេអត់ឲ្យធ្វើអីទេ?

វឿន៖ ចាំ! គេត្រៀមដើងបណ្ដើអញ្ចឹងហ្មង ត្រៀមដេងតែទៅ, ដើរលេង ល្ងាចឡើង ថ្ងៃឡើង នាំគ្នាដើរលេងដើរអីអញ្ចឹង ។

ដានី៖ កាលហ្នឹងមីងកាលស្នាក់នៅក្រចេះហ្នឹងមីងដូចថា ធ្លាប់ដើរទៅជួបអីទៅធ្វើការអីជាមួយអ្នកដែល ដូចថានៅក្រចេះហ្នឹងទៅកន្លែងណាផ្សេងៗទៀត ដូចយើងទៅធ្វើការអីជាកងទព័ ទៅធ្វើការជាមួយ...?

វឿន៖ ប្រជាជន ។

ដានី៖ ឬជាមួយអ្នកធ្វើការអីផ្សេងទៀតដែរ?

វឿន៖ អត់ទេ គេអត់ឲ្យធ្វើអី ។

ដានី៖ គេអត់ឲ្យធ្វើអីហ្មង?

វឿន៖ ចាំ! អត់ឲ្យធ្វើអី ។ ស៊ីដេកៗ

ដានី៖ រយៈពេល?

វឿន៖ ៣ខែ ។

ដានី៖ ៣ខែ ។ ដល់ពេល៣ខែហ្នឹងគេបញ្ជូនទៅមណ្ឌលគិរីទៀត?

វឿន៖ ចាំ! មណ្ឌលគិរីទៅនៅភូមិ ទៅនៅកែវសីមា ។

ដានី៖ ដំបូងបំផុតទៅនៅកែវស៊ីម៉ា?

វឿន៖ ដំបូងបំផុតទៅនៅទីមួយ....គឺទៅនៅភូមិអបឃួន ។

ដានី៖ ទៅនៅអបឃួន?

វឿន៖ ចាំ! អបឃួនលើ ។

ដានី៖ មិនមែនសុខសាន្តទេ?

វឿន៖ សុខសាន្តហ្នឹងអបឃួនហើយ ។

ដានី៖ អបឃួនហ្នឹងគេហៅសុខសាន្ត?

រឿនៈ ឃុំសុខសាន្ត ។

ដានីៈ កន្លែងហ្នឹងដូចថា មីងទៅហ្នឹងទៅនៅកន្លែងកងពលរបស់តាឈិនហ្នឹងហ្នងឬក៏?

រឿនៈ របស់តាឈិនហ្នង ។

ដានីៈ កងពលហ្នឹងគេហៅកងពលអីទៅ?

រឿនៈ កងពលទីពីរ ។

ដានីៈ កងពលទីពីរ?

រឿនៈ ចាំ!

ដានីៈ ប៉ុនទៅមណ្ឌលគិរីគេមានដាក់កងពលទីពីរទៀតដដែលឬគេក៏ផ្លាស់ឈ្មោះ?

រឿនៈ ដដែល ដដែលទាល់តែឥឡូវផ្សាភ្ជាប់ដល់បង០៦អីកងពលទីពីរដែរដដែល ។

ដានីៈ កងពលទីពីរហ្នឹងតាឈិនគណៈកងពល លេខាកងពលអញ្ចឹងអី?

រឿនៈ ចាំ! កងពលធំ ។

ដានីៈ ចុះអនុ?

រឿនៈ អនុមិនបងសយ ។

ដានីៈ សយ?

រឿនៈ សយ ។

ដានីៈ ពីណាទៀត?

រឿនៈ តាសយមក តាយៀន ។

ដានីៈ តាសយ តាយៀន?

រឿនៈ ចាំ!

ដានីៈ អាហ្នឹងអនុកងពល?

រឿនៈ អនុ ដូចថា ប្រធានបានមកបានភស្តុភា បានមកបាននយោបាយអីអញ្ចឹងណា វាមានតាមថ្នាក់វាអញ្ចឹង ។

ដានីៈ បាទ! ប្រធានឈ្មោះ ឈិន ។

រឿនៈ ចាំ!

ដានីៈ ឈិនហ្នឹងគាត់នៅណា?

រឿនៈ ឈិនអត់ដឹងដែរ?

ដានីៈ បាទ! ចុះតាសយ?

រឿនៈ អត់ដឹងដែរអត់ស្គាល់ ស្គាល់តែ...មិនសូវបានទៅជិតទេពួកខ្ញុំ ។

ដានី៖ ចុះកាលមីងទៅនៅសុខសាន្តហ្នឹងមន្ទីរកងពលនៅកន្លែងណាទៅ?

រឿន៖ មន្ទីរកងពលនៅខាងលើអូចា្បា ។

ដានី៖ នៅលើអូចា្បា?

រឿន៖ ចា៎! ពួកខ្ញុំនៅក្រោម ។

ដានី៖ អញ្ចឹងក្រុមរបស់មីងនៅឆ្ងាយពីមន្ទីរកងពល?

រឿន៖ ឆ្ងាយ ឆ្ងាយដាច់ជិតមួយគីឡូដីនោះ ។

ដានី៖ បាទ! នៅអូចា្បា ។

រឿន៖ នៅអូចា្បា ។ខ្ញុំដល់ទៅពេលនៅមណ្ឌលគិរី នៅសុខសាន្តអញ្ចឹងទៅបានគេដកពីកងទ័ពមកនៅ មន្ទីរពិសោធន៍ នៅមន្ទីរពេទ្យនៅស្លថ្នាំ ។

ដានី៖ នៅស្លថ្នាំ?

រឿន៖ ចា៎! ស្លថ្នាំស្អីកយើង ថ្នាំដបយើងហ្នឹងណា! ចំហុយទឹក ចំហុយអីទៅ ។

ដានី៖ មីងអ្នកស្លថ្នាំចំហុយអីហ្នឹងនៅក្នុងពេទ្យហ្នឹងពេទ្យរបស់កងពលអីដែរ?

រឿន៖ ចា៎! របស់កងពលដែរ ។ ប្រធានពេទ្យមានតាសើ ប៉ុនឥឡូវគាត់ស្លាប់ហើយ ។

ដានី៖ ឈ្មោះសើ ប្រធានពេទ្យរបស់កងពលហ្នឹង?

រឿន៖ អនុ អនុប្រធានមាន តា ធួន ។

ដានី៖ តា ធួន អនុប្រធានពេទ្យហ្នុង?

រឿន៖ ចា៎! អនុប្រធាន ហ្នឹងហើយតាធួនហ្នឹង ។

ដានី៖ អញ្ចឹងមីងកាលមីងទៅធ្វើពេទ្យហ្នឹងមីងនៅសិល្បៈដដែលដែរ?

រឿន៖ នៅសិល្បៈដដែលដែរ ។

ដានី៖ បាទ! ចុះសិល្បៈនៅក្នុងកងពលហ្នឹងសម្រាប់ធ្វើអីដែរ?

រឿន៖ សម្រាប់ពេលដូចថាគេថ្ងៃ១០ ថ្ងៃ២០ ថ្ងៃដាច់ខែម្តងៗអីគេមកសន្និបាត យកសិល្បៈទៅលេង ។

ដានី៖ មហាសន្និបាតនៅណាទៅ?

រឿន៖ មហាសន្និបាតនៅសុខសាន្តហ្នឹងគេមានសាលានយោបាយគេមួយសម្រាប់... ។

ដានី៖ មហាសន្និបាតនៅក្នុងកងពលហ្នឹងហ្នុង?

រឿន៖ ចា៎! នៅក្នុងកងពលទូទៅ គេហៅត្រឹមប្រធានពួក និងប្រធានក្រុម និងវរៈសេនាធំ វរៈសេនាតូច រួម រួមម៉ាកងពលអញ្ចឹងហ្នុង ។

ដានី៖ រៀងរាល់ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០?

រឿនៈ ចាំ!

ដានីៈ ១០ ថ្ងៃមុន?

រឿនៈ ១០ ថ្ងៃមុនគេជុបលៀនៗ បើមិនធ្វើនំបញ្ចុកទេ ធ្វើបាញ់ឆែវអញ្ចឹងទៅ បើមិនបាញ់ទេ ធ្វើស្ពឺ ចំនីចំនុបអីអញ្ចឹងទៅ ។

ដានីៈ ចុះក្នុងកន្លែងពេលសន្និបាតហ្នឹងគេនិយាយពីស្អីខ្លះទៅមីង?

រឿនៈ ទេនិយាយពីជម្រុញស្មារតីយើងក្នុងការអនុវត្តមាគ៌ា និយាយរួមគឺអនុវត្តច្បាប់ហ្នុង ។

ដានីៈ ច្បាប់ម៉េចខ្លះទៅ?

រឿនៈ គេអនុវត្តច្បាប់ដូចថាយើងត្រូវធ្វើដូចថា យើងធ្វើពលកម្មដូចស្ទូងដកអញ្ចឹងចេះជម្រុញ ស្មារតីឲ្យយើងខិតខំធ្វើការងារអីអញ្ចឹងណាំ!ខាងផ្នែកនយោបាយមានផ្នែកនយោបាយអប់រំ ។

ដានីៈ ចុះដូចថាពេលនៅក្នុងសន្និបាតអីហ្នឹងដូចថាមានអ្នកខាងណាខ្លះគេមកចូលរមដូចជាគណៈអធិបតី ?

រឿនៈ គណៈអធិបតី គណៈកងពលអញ្ចឹង?

ដានីៈ បាទ! ដូចថា អ្នកដែលចូលរួមមាន...?

រឿនៈ តាឈិន ។

ដានីៈ ឈិន! ចុះមានអ្នកផ្សេងទៀតមកពីណាដូចថាមកពីមជ្ឈឹមមកពីភ្នំពេញមកពី...?

រឿនៈ អត់មានទេ! អត់មានទេ!

ដានីៈ តែកងពលហ្នឹង ។

រឿនៈ កងពល ចាំ! ប្រធានអនុប្រធានសមាជិករបស់កងពលហ្នឹងមកចូលរួម ។

ដានីៈ ចុះដូចថាពេលដែលមីងទៅនៅក្នុងកងពលហ្នឹងដូចថាមាន ដូចថាខាងគណៈតំបន់ គណៈភូមិភាគ អីគេមានមកទាក់ទងចូលរួមអីទៀតទេ?

រឿនៈ អត់ទេ! អត់មានទេ! ខាងតំបន់គេផ្សេង ខាងតំបន់ដូចថា ខាងតំបន់មណ្ឌលគីរីដូចមានតា ធុច តាអីដូចពួកក្រុមតាធុចតាអីហ្នឹងក៏អត់មានដែរអត់មានទេតែមួយកងពលហ្នឹងហ្នុងអប់រំប្រជាជន ...ដែលកងទ័ពនៅក្នុងវរៈសេនាធំមួយៗគឺប្រមូលគ្នាមកក្នុងរយៈថ្ងៃ១០ ថ្ងៃ២០ថ្ងៃ៣០ ថ្ងៃ១ អីអញ្ចឹងគេមកអប់រំដូចថាជួយរំឭកស្មារតីឲ្យមានស្ម័យប្រវត្តិនៅក្នុង អារម្មណ៍យើងមួយៗ ចាំ! ឲ្យធ្វើការងារអីកុំឲ្យមានការធុញទ្រាំ ហើយកុមឲ្យមានការចាក់ សិលធម៌ចំពោះស្ត្រីបុរស អត់ឲ្យមានចាក់សិលធម៌ទេ និយាយជាមួយគ្នាក៏អត់បានដែរ ខ្ញុំ បងប្អូនខ្ញុំជីដូនមួយនិយាយជាមួយគ្នាគេកសាងចង់ងាប់ហើយ អត់បានទេមួយជំនាន់នោះ ។

ដានី៖ ចុះមីងកាល ដូចថាពេលគេធ្វើសន្និបាតគេប្រជុំអីរួចទៅគេមានបាញ់ឆេវ ទំបញ្ចុក រួចទៅមានសិល្បៈលេង?

រឿន៖ ចាំ!

ដានី៖ សិល្បៈហ្នឹងគេលេងពីស្អីទៅ?

រឿន៖ លេងពីដែកនយោបាយដែរ ។

ដានី៖ លេងពីសម្ដែងយ៉ាងម៉េចខ្លះទៅ?

រឿន៖ សម្ដែងរឿងឲ្យទាហរណ៍និយាយពីរឿងបញ្ហាដូចថា វាមានអ្នកជនក្រីក្រម្នាក់អត់លុយ អត់អង្ករអត់ផ្ទះអត់នៅគ្មានខោអាវស្លៀកពាក់ហ្នឹង ហ្នឹងគេលេងរឿងហ្នឹងអញ្ចឹងណា! កំសត់អីអញ្ចឹងទៅណា ចាំ! ដូចរឿងដីកត្រពាំងដីកអីអញ្ចឹងទៅណាំ!

ដានី៖ ជីកត្រពាំងយ៉ាងម៉េចទៅ?

រឿន៖ រឿងដីកត្រពាំង រឿងប្រវត្តិក្រណាស់ ក្រគ្មានអីស៊ីអញ្ចឹងណា ចាំ! ប្រវត្តិជីកត្រពាំងហ្នឹងដូចថាមានទាហ៊ានអាកាលនោះយើងនិយាយឲ្យអស់ទៅណា!ព្រោះវារួចទៅហើយគេលេងរឿងលេងអីហ្នឹងអាហ្នឹងបង១ទេអ្នកឆ្នៃប្រឌិតនោះពួកខ្ញុំចាំតែលេងតាមតែក្រោយគេទេ ។ គេដូចថាមានទាហ៊ានមានអំអញ្ចឹង គេមកតាមវែអង្កៀសតាមប្រជាជនសូម្បីតែមាន់ មួយក៏មិនឲ្យនៅក្នុងទ្រុងដែរ គេមកវាយអង្កៀសមាន់ឆ្កែជ្រូក មាន់ទាមានឃួនមានអី អញ្ចឹង គេមកវាយអស់ទាល់គ្មានអីស៊ីចែកកូនស៊ីទៅជីកត្រពាំងមកឲ្យកូនស៊ីអញ្ចឹងណា! យកមកស្ងោឲ្យកូនស៊ី ។ ប្រវត្តិហ្នឹងរឿងហ្នឹងអញ្ចឹង ។

ដានី៖ ចុះមីងថា បង១គាត់អ្នកតែង អ្នកដឹកនាំរឿងបងណាទៅអ្នកដឹកនាំអ្នកតែង?

រឿន៖ គេអ្នកតែងហ្នឹងដូចថាឈ្មោះអីទេ ខ្ញុំភ្លេចហើយនេះ ភ្លេចរឿងអ្នកតែងហ្នឹងវាមិនសូវស្គាល់គេទៀតណាក្មួយ ព្រោះពួកខ្ញុំនៅខាងសិល្បៈហ្នឹង ដឹងតែខាងសិល្បៈអញ្ចឹងបើគេហុចសៀវភៅអីមួយអញ្ចឹងយើងមើលសម្ដែងរឿងតាមតែហ្នឹងដដែល តែឲ្យស្គាល់មុខគេខ្ញុំអត់ស្គាល់ទេ ។

ដានី៖ ខាងណាគេអ្នកហុចសៀវភៅឲ្យមក?

រឿន៖ ដូចខាងនីរសាអីអញ្ចឹងនេះ?

ដានី៖ នីរសាមកពីណាមក?

រឿន៖ នីរសាតាឈិនអីអញ្ចឹងណា ។

ដានី៖ សៀវសំដែងហ្នឹងដូចមនមែនខាងសិល្បៈហ្នឹងអ្នករៀបចំដឹកនាំរឿងនិពន្ធរឿងខ្លួនឯងនោះ ទេ?

រឿនៈ ចាំ! អត់ទេ! មានអ្នកនិពន្ធទៀតចំរៀងក៏មានអ្នកនិពន្ធផ្សេងទៀត មនមែនយើងចេះដោយយើង ។

ដានីៈ ចុះពេលកាលនៅក្នុងកងពលអីចំរៀងគេច្រើនច្រៀងបទអីទៅ?

រឿនៈ ច្រៀងតែពីរឿងវ៉ៃហ្នឹងហើយ ។ រឿងទៅវ៉ៃលន់ ណុល វ៉ៃអាមេរិក ចក្រពត្រ័អាមេរិក ចក្រពត្រ័លន់ ណុលអីអញ្ចឹងទៅ ។

ដានីៈ កាលនោះប្រធានសិល្បៈរបស់មីងឈ្មោះអីទៅ?

រឿនៈ អត់ស្គាល់ទេបើពីនៅកាលលោកតាចាន់ផនខ្ញុំស្គាល់ដល់ទៅនៅកោះញែកខ្ញុំលេងបានប៉ុន្មានខែក៏ឈប់ទៅណា យើងអត់សូវស្គាល់គេ ប៉ុនស្គាល់មែនទែនមានតាយៀន បងយាត បងយាតប្រពន្ធបងឈិននោះ ។

ដានីៈ យាតហ្នឹងគាត់ធ្វើអីយ៉ាត? យ៉ាតប្រពន្ធឈិនហ្នឹងគាត់ធ្វើគេ?

រឿនៈ គាត់ខាងផ្នែកនារី ទទួលខុសត្រូវខាងនារី ។

ដានីៈ ទទួលខុសត្រូវនារីហ្នឹង ដូចទទលខុសត្រូវ ដូចទទួលនារីកងពលឬក៏យ៉ាងម៉េច?

រឿនៈ នារីកងពលហ្នឹង ។ ទទួលខុសត្រូវខាងផ្នែកនារី ហើយបងយ៉ាតប្រពន្ធបងសយ បងយៀន បងអីហ្នឹងសុទ្ធតែសិល្បៈដូចគ្នាប្រពន្ធកងពលសុទ្ធតែសិល្បៈដូចគ្នាហ្នឹង ។

ដានីៈ ប្រពន្ធឈិនឈ្មោះយ៉ាត?

រឿនៈ ចាំ!

ដានីៈ ចុះប្រពន្ធសយ?

រឿនៈ ឈ្មោះបងយៀន ។

ដានីៈ ឈ្មោះយៀន ។

រឿនៈ ចាំ!

ដានីៈ ចុះប្រពន្ធ....មីងប្រាប់ខ្ញុំមិញថា ឈិនប្រធានកងពល សយអនុ យៀនសមាជិក ។

រឿនៈ សមាជិក ។

ដានីៈ សមាជិក ។ ចុះប្រពន្ធរបស់យៀនឈ្មោះអីដែរ?

រឿនៈ ទេ! ប្រពន្ធពូយៀន?

ដានីៈ បាទ!

រឿនៈ ប្រពន្ធបងយៀន...អ! ប្រទ្បំបងយៀនហើយសមាជីក មើលប្រពន្ធបងយៀនឈ្មោះអីទេ វ៉ៃឈ្មោះ....ចេះអស់រលីង..ភ្លេចអស់ហើយមិនដឹងឈ្មោះអីទេ ។

ដានីៈ ចុះប្រពន្ធ ប្រពន្ធសយឈ្មោះអីដែរ?

រឿនៈ ប្រពន្ធសយឈ្មោះ...ឈ្មោះអីទេ នៅចុងៗមាត់ខ្ញុំ...មិនបានចាំវាយូរពេកទៅ....

ដានីៈ បាទ! អត់អីទេអញ្ចឹង ។ ចុះកាលមីងនិយាយថា ធ្វើសិល្បៈផងធ្វើពេទ្យផង?

រឿនៈ ចា៎!

ដានីៈ ចុះក្រៅពីសំដែងសិល្បៈ លេងសិល្បៈមីង..?

រឿនៈ ចូលធ្វើពេទ្យ ពេទ្យឆ្មប ។ ពេទ្យជម្ងឺទូទៅផង ឆ្មបផងខ្ញុំ ។

ដានីៈ ចុះមីងថាមានសូថ្នាំអីនោះ?

រឿនៈ សូថ្នាំអាហ្នឹងចេញពីសូថ្នាំហើយនោះ ។ ចេញពីសូថ្នាំគេបញ្ជូនឲ្យទៅនៅពេទ្យ ។ ចា៎!ខ្ញុំរៀនពេទ្យបាន៦ខែ បានខ្ញុំឆ្លងទន្លេទៅបានឈប់រៀនទៅ ។

ដានីៈ ចុះកាលដូចថាកាលមុនមីងនិយាយប្រាប់ខ្ញុំថាកាលនៅឬស្សីកែវមីងរៀនសូថ្នាំដែរ?

រឿនៈ ចា៎! សូថ្នាំ អាហ្នឹងមកពិឬសឈើ ។

ដានីៈ ឈ្មោះសូ ឈ្មោះអីហ្នឹងអ្នកបង្រៀន?

រឿនៈ ចា៎! បង្រៀន ។

ដានីៈ អញ្ចឹងដល់ពេលទៅកន្លែងកងពលនៅរៀនសូថ្នាំដដែល?

រឿនៈ ដដែល ។

ដានីៈ សូថ្នាំខុសគ្នាយ៉ាងម៉េចទៅពេលដែលទៅកន្លែងកងពលហើយនិងនៅនេះ?

រឿនៈ ដេរបើយើងនៅឬស្សីកែវនេះយើងដើររកថ្នាំដោយខ្លួនឯងអញ្ចឹងម្តង ។យើងមកចំរាញ់យកទឹកវាស្ងោហើយចំរាញ់យកទឹកវាទៅ ធ្វើទៅ ដល់ទៅពេលទៅនៅកោះញែកគេមានថ្នាំ គេលាយមេគេលាយហ្នុង ។ ដាក់អំពូលដាក់អីអញ្ចឹង ប៉ុន្តែប្រធានហ្នឹងមានតាស៊ុនអ្នកបេះ ផ្សារអំពូលផ្សារអីហ្នឹងមិនពូស៊ុននៅនេះ នៅអន្លង់វែង ។

ដានីៈ ស៊ុន ។ ស៊ុនហ្នឹងខ្មែរយើងទេ?

រឿនៈ ខ្មែរ ។

ដានីៈ គាត់អ្នកប្រធានសូថ្នាំហ្នឹងហ្នុង?

រឿនៈ ចា៎! គាត់ហ្នឹងរៀនមកពីតាជួនជឿន ។

ដានីៈ គាត់រៀនមកពីជួនជឿន?

រឿនៈ ចា៎! សិស្សតាជួនជឿន

ដានីៈ អត់មានបរទេសអីមកបង្រៀនទេ?

រឿនៈ អត់ទេ! គ្មានទេ សុទ្ធតែខ្មែរយើង ។

ដានីៈ ឈ្មោះតាស៊ុនហ្នឹងកូនសិស្សរបស់តាជួនជឿនហ្នឹងគាត់ប្រធានគាត់បង្រៀន?

រឿនៈ ចា៎!

ដានីៈ គ្នាប៉ុន្មាននាក់ទៅដែលសួថ្នាំដំបូង?

រឿនៈ សួថ្នាំដំបូងពួកខ្ញុំមានគ្នា៩នាក់ មើលរិននៅឬស្សីកែវហ្នឹង រិន រាប សូ ណាទៀតទេមិត្តផាន រ៉ា ខ្ញុំ ណាទៀតទេ...មិត្តលាន មិត្តលានហើយមិត្តអីទេមួយទៀតភ្លេចគ្នា៣នាក់ បាន៩នាក់ ....៩នាក់ស្រី ។

ដានីៈ ៩នាក់ស្រីៗ?

រឿនៈ ចា៎! ស្រីៗ ទាំងស្រី ទាំងប្រុស៩នាក់សួថ្នាំ ។

ដានីៈ បាទ!អញ្ចឹងនៅក្នុងកងពលហ្នឹងថ្នាំដែលព្យាបាលយុទ្ធជនកម្មាភិបាលនៅក្នុងកងពលហ្នឹងសុទ្ធតែថ្នាំដែលយើងសួទេ ឬក៏មានថ្នាំពេទ្យថ្នាំអីគេយកទៅដែរ?

រឿនៈ អត់មានទេ មានគេជំនួយមកពីចិន ។

ដានីៈ មានថ្នាំជំនួយមកពីចិនដែរ?

រឿនៈ ចា៎! ថ្នាំគេប្រអប់ៗប៉ុណ្ណេះៗខៀវៗ ។

ដានីៈ ចុះម៉េចបានមីងដឹងថាថ្នាំហ្នឹងគេជំនួយមកពីចិន?

រឿនៈ បើចិនយកមក! ជិះយន្តហោះយកមកនៅកោះញែកនោះ ។

ដានីៈ មានចិនមកដែរ?

រឿនៈ ចា៎! មានតើ ។ ចិនមកមុនៗម៉ាយន្តហោះ ពួកខ្ញុំទៅធ្វើព្រលានយន្តហោះ យកទ័ពនារីទៅធ្វើព្រលាននៅកោះញែក ។

ដានីៈ ចិនហ្នឹង គេមកហ្នឹង គេមកយកតែថ្នាំមកឲ្យឬគេមកធ្វើអីទៀត?

រឿនៈ គេជំនួយតាំងពីស្បែកជើងតាំងពីខោអាវ តាំងពីសារូមតាំងពី និយាយរួមសម្ភារៈម៉ាសព្វ ។

ដានីៈ ចិនមកខ្លួនឯងហ្មង?

រឿនៈ ចា៎!

ដានីៈ បើតាមមីងចាំហ្នឹងដូចថា កាលចិនមកហ្នឹងមកឆ្នាំណាខ្លះទៅ?

រឿនៈ កាលចិនមក មកឆ្នាំណាខ្លះទេ? ខ្ញុំរកនឹកសិន មកហ្នឹងពួកខ្ញុំនៅលីវដែរទេ អត់ទាន់មានគ្រួសារផង អត់ទាន់មានគ្រួសារទេ ប្រហែលអាចឆ្នាំ៧០ពាក់កណ្ដាលឆ្នាំ៧៥អីហ្នឹង ។

ដានីៈ បែកភ្នំពេញ១៧ មេសា ឆ្នាំ៧៥?

រឿនៈ ចា៎! អាចពាក់កណ្ដាលខែ៧ ខែ៨អីហ្នឹងមកដល់ពួកចិនណា ព្រោះខ្ញុំទៅដល់ ពួកខ្ញុំទៅដល់កោះញែកហើយនោះ ឲ្យទៅដល់សុខសាន្តហើយបានចិនមក ចិនមកដែលខ្ញុំនៅសុខសាន្តហើយចិនមក ។

ដានី:  ចិនមកប៉ុន្មាននាក់?

វឿន:  ចិនមកគ្នា៧នាក់ ប្រុស៤ ស្រី៤ ៨នាក់ ។ ស្អាតៗណាស់ចិនៗ ។

ដានី:  មានខ្មែរមកជាមួយដែរអត់?

វឿន:  ខ្មែរមាន ខ្មែរស្រីៗ ២នាក់ ។

ដានី:  ២នាក់ហ្នឹង អ្នកស្អីគេអ្នកមកជាមួយហ្នឹង?

វឿន:  អ្នកបក ។

ដានី:  អ្នកបកប្រែ?

វឿន:  ចា៎! បកប្រែ២នាក់ ។ ចិនមកហ្នឹងមានសម្ភារៈមានថ្នាំ មានស្អីមានខោអាវ ដូចថា ខោអាវចិន
អីអញ្ចឹងណាអាខោអាវចិនយើងខាវអាវពួកខ្មែរក្រហមស្លៀកពាក់ហ្នឹងខោវអាវ
ហ្នឹងស្បែកជើង ថ្នាំពេទ្យ មានតែប៉ុណ្ណឹងសារូមអីហ្នឹងគេជំនួយ ។

ដានី:  ចិនមកប៉ុន្មានថ្ងៃដែរ?

វឿន:  ចិនមកម៉ាយប់មួយថ្ងៃទៅវិញ ។

ដានី:  ពេលដែលចិនមកហ្នឹងគេមានប្រជុមានអីជាមួយចិនដែរអត់?

វឿន:  ដឹងម៉េចទេ! ខ្ញុំនៅឆ្ងាយពីមន្ទីរកងពល ។ កាលនោះមិនមែនជំនាន់តា០៦ទេជំនាន់ពូឈិនណា៎!
សុខសាន្ត ។

ដានី:  ប៉ុនដូចថា....កាលនោះដូចថា ពេលដែលចិនជំនួយខោអាវស្អីមកហ្នឹងខោអាវដែលគេចិនជំនួយ
ហ្នឹងដូខថា ស្លៀកហ្នឹងដូចថាកងពន្ធ័ហ្នឹងស្លៀកពាក់ពណ៌ខោអាវពណ៌យ៉ាំងម៉េច?

វឿន:  ពណ៌ស្លឹកឈើ ។

ដានី:  ពណ៌ស្លឹកឈើមិនមែនពណ៌ខ្មៅទេ?

វឿន:  អត់ទេ! ពណ៌ដូចស្លឹកចេកអីអញ្ចឹង ។

ដានី:  ពណ៌ស្លឹកចេក

វឿន:  ចា៎! ពណ៌ស្លឹកចេកចាស់អីអញ្ចឹង ។

ដានី:  បាទ! ចុះមួក ពាក់មួកយ៉ាំងម៉េចទៅ?

វឿន:  មួកអញ្ចឹងដូចគ្នា ។

ដានី:  មួកកាតបេ មួកកូរ៉េដូច?

វឿន:  មួកអាកាតឹបមុខបន្តិចៗអញ្ចេះ ។

ដានី៖ ចុះមីងយន្តហោះអាចិនចុះហ្នឹងយន្តហោះប្រភេទយ៉ាងម៉េចទៅ? ដែលយន្តហោះចិនដឹកសម្ភារៈអីមកហ្នឹង?

រឿន៖ ខ្ញុំអត់បានឃើញដែរនៅព្រលាននោះ ។ ព្រលានពីមន្ទីពេទ្យមកឆ្ងាយរាប់គីឡូដីពាគីឡូដីនោះមិននៅជិតផង ។

ដានី៖ ចុះមីងថាព្រលានហ្នឹងពួកមីងអ្នកធ្វើ?

រឿន៖ ចាំ! ពួកខ្ញុំកងទ័ពនារីហ្នឹងធ្វើពួកពេទ្យពួកអីហ្នឹងទៅធ្វើព្រលាន ។ ដល់ធ្វើរួចហើយស្រេចតែហ្នឹងគេទៅអត់ដែលទៅជិតគេ ។

ដានី៖ ព្រលាននៅកន្លែងណាទៅ?

រឿន៖ ព្រលាននៅខាង មើលខាងលិចភ្នំត្រោល ។

ដានី៖ ខាងលិចភ្នំត្រោល?

រឿន៖ ចាំ!

ដានី៖ ខាងលិចភ្នំត្រោលបានន័យ ព្រលានហ្នឹងគេហៅកន្លែងអីគេទៅ កន្លែងហ្នឹងឈ្មោះអីទៅ?

រឿន៖ ទៅពីស្រែវង់នេះទៅ ស្រែល្អនេះទៅភ្នំត្រោល ពីភ្នំត្រោលនេះទៅ ពីភ្នំត្រោលនេះទៅអត់ដឹងគេហៅអីទេប៉ុន្តែពួកខ្ញុំហៅតែភូមិព្រលាន ។

ដានី៖ ហៅតែភូមិព្រលាន?

រឿន៖ ចាំ!

ដានី៖ ហៅភូមិព្រលានអញ្ចឹងហ្នង ។ មីងបើតាមមីងចាំខែ៧ ខែ៨ហ្នឹងចិនទៅ? អញ្ចឹងមីង មីងទៅពីក្រចេះបានបន្តិចទៅហ្នឹង ចិនទៅហង?

រឿន៖ ចិនទៅ ។ មើលទៅពីចិនទៅខ្ញុំរស់នៅសុខសាន្តមិនទាន់បានប៉ុន្មានផង ទាល់ខែ៧ ខែ៨យើង
មិនភ្លៀងមិនផ្គរ! ទៅដល់ពួកខ្ញុំនាំគ្នាដកស្ទូង ជំនួយដកស្ទូងប្រជាជនហ្នឹង ទៅដល់នោះណា
ហើយយកទៅភ្លៀងសស្រិកសស្រាក់ពួកខ្ញុំ...ចិនវាមុចទឹកស្បូវឃើញក្រហមៗ វាមានមុចឯណា ។

ដានី៖ អត់មុខទេ?

រឿន៖ ចាំ! ទឹកស្បូវក្រហមនោះចាំ! ប៉ុននាំគ្នារត់ទៅអូប្រវ៉ា ។ ខ្ញុំចាំតែរឿងភ្លៀងទេ ខែភ្លៀងចិនមកហ្នឹង ។

ដានី ៖ កាលហ្នឹងពេលដែលមីងទៅ...មីងទៅបានដូចថាទៅជួបបានទៅនិយាយអីជាមួយចិនអីដែរអត់?

រឿន៖ អត់បាននិយាយជាមួយស្រីៗខ្មែរ ។

ដានី៖ ស្រីៗខ្មែរ?

រឿនៈ ចិនហ្នឹងមិនទៅនិយាយជាមួយវាកើតទេ បើវាចននោះ ហើយយើងខ្មែរនោះ ។
ដានីៈ ចុះមីង កាលចិនចុះទៅនោះពួកមីងអីមានបានទៅទទួលចិនអីដែរអត់?
រឿនៈ ទទួលនៅព្រលានពួកកងទ័ពគេទៅទទួលពួកខ្ញុំអត់បានទៅទេ ។ ពួកទ័ពស្រួចគេកងពិសេសគេទៅទទួល ខ្ញុំអត់បានទៅទេ ។
ដានីៈ ចុះដូចថា ខាងគណៈកងពលអីគេទៅទទួលអីដែរអត់?
រឿនៈ ទៅ ។
ដានីៈ ពីណាខ្លះទៅទទួលហ្នឹង?
រឿនៈ ពួកពូលិនអីហ្នឹង ពួកអីហ្នឹង ពួកសយពួកអីហ្នឹង យើងមកនៅកន្លែងគេ កន្លែងនយោបាយ គេចាញ់ក្រុឡានយោបាយគេ ។
ដានីៈ ចុះខាងដូចថា អ្នកខាងពីមជ្ឈិមទៅហ្នឹងមានអ្នកដែលទៅជាមួយចិនអីដែរអត់? ទៅដូចថាចុះទៅពេលចិនចុះទៅនោះ ។
រឿនៈ ដូចអត់មានទេ មានតែអ្នកទីក្រុងភ្នំពេញប៉ុនមិនដឹងខាងស្អីគេ ឃើញគេទៅ៤ ៣នាក់ដែរ ។ ហើយទៅស្គាល់តែតាកុងយន្តហោះឈ្មោះតាពារមួយហ្នឹង ។
ដានីៈ ឈ្មោះពារ?
រឿនៈ ចាំ! ពារហ្នឹងតាកុងយន្តហោះ ។
ដានីៈ ចុះអ្នកផ្សេងទៀតអ្នកមីងនិយាយថា អ្នកភ្នំពេញទៅហ្នឹងមីងអត់ដឹងថាគេធ្វើអីទេ?
រឿនៈ ចាំ! អត់ដឹង ឃើញតែកាំភ្លើងខ្លី ឃើញតែអីអញ្ចឹង ។
ដានីៈ ឃើញកាំភ្លើងខ្លី?
រឿនៈ ចាំ! មិនដឹងគេធ្វើអី?
ដានីៈ យន្តហោះហ្នឹង យន្តហោះមីងនិយាយថាតាកុងយន្តហោះខ្មែរទេ ឈ្មោះពារហ្នឹង?
រឿនៈ ខ្មែរ ។ ខ្មែរព្រោះគាត់ទៅសុខសាន្តហ្នឹងទៅហូបបាយនៅមន្ទីរស្នូថ្មាំហ្នឹង ។ ហើយសួរទៅពូ ហួនពូហួនសួរថាឈ្មោះអីហ្នឹង? ថាគាត់ឈ្មោះពារ ។
ដានីៈ ឈ្មោះពារ ។ ចុះមីងទៅ កាលនោះចិនទៅតែម្តងហ្នឹង ឬថ្នាក់ក្រោយទៀតចិនទៅទៀត?
រឿនៈ អត់មានទេ តែម្តងទេ ។
ដានីៈ អញ្ចឹងកាលពីមុនកាលមីងនៅក្រសុកភូមិកាលនៅតូចៗហ្នឹងក៏មីងស្គាល់គាត់ដែរតាយ៉ម?
រឿនៈ ចាំ! ស្គាល់លេងចូលឆ្នាំលេងចូលអីជាមួយគ្នា កាលនោះគាត់នៅរៀន ។
ដានីៈ បាទ! ចុះបើចំពោះនៅមណ្ឌលគីរហ្នឹងគេមិនដែលស្គាល់ឈ្មោះគាត់តាយ៉មទេ?
រឿនៈ អត់ទេ! អត់មាននរណាស្គាល់ទេ ។

ដានី៖ បើក្រៅពីមីងដូចថា មីងអ្នកធ្លាប់នៅជាមួយគ្នាដឹងថាគាត់ឈ្មោះតាយ៉ម?

វឿន៖ ចាំ!

ដានី៖ ប៉ុន្តែទៅដល់មណ្ឌលគិរីនោះគាត់មិនដែលប្រើឈ្មោះតាយ៉ម...?

វឿន៖ អត់ទេ! អត់ដែលទេ ។

ដានី៖ អញ្ចឹងពេលដែលតាឈិន សយ យៀនអីទៅបាត់ហ្នឹងគេផ្លាស់តា០៦មកតែម្នាក់ឬក៏ម្នាក់ឬក៏មានអ្នកផ្សេងមកផ្សេងៗទៀតដែរ?

វឿន៖ មាន! មានតែបង០៦ និងបង០៦..មានតែបង០៦និងបង៨០ ។

ដានី៖ បង៨០?

វឿន៖ ចាំ! អាហ្នឹងតាឈន ។

ដានី៖ បង៨០តាឈន?

វឿន៖ ចាំ!

ដានី៖ ហ្នឹងផ្លាស់មកពី មកជាមួយ...?

វឿន៖ មកជាមួយខ្សែរយៈបង០៦មកតាហ្នឹង ។ ខ្សែរយៈគាត់ ។

ដានី៖ បង៨០?

វឿន៖ ចាំ! បងខេមរាក៏អត់ដែលស្គាល់ដែរ?

ដានី៖ ខេមរា មួយទៀតដែរ?

វឿន៖ ចាំ! ខេមរា អត់ទេ ខេមរានៅក្រោយទេ!

ដានី៖ នៅក្រោយទៀត?

វឿន៖ ចាំ! បើទៅជាមួយបងខ្ញុំប្រាប់ អាហ្នឹងខ្ញុំនិយាយក្នុងការយល់ដឹងរបស់ខ្ញុំណាំ! វរៈសេនាធំ វរៈសេនាធំ វរៈសេនាតូច យើងរាប់តែវរៈសេនាធបានហើយ ។ ចាំ! ទីមួយកងពលមានបង០៦ អនុប្រធានបង៨០ សមាជិកមានតាឈួន... ។

ដានី៖ តាឈួន?

វឿន៖ ចាំ!

ដានី៖ តាឈួន ឬតាឈន?

វឿន៖ តាឈួន ។ តាឈួនយាយនី ។

ដានី៖ បង៨០ហ្នឹងគាត់ឈ្មោះអី?

វឿន៖ បង៨០ឈ្មោះម៉េចទេ...បង៨០ឈ្មោះម៉េចទេ..សាវឿន..ដឿនម៉េចទេភ្លេចឈ្មោះអស់ហើយ ...សាវឿនអញ្ចេះទេ...ខ្ញុំភ្លេចឈ្មោះគាត់បាត់ហើយ ។

ដានី: ចុះមីងកាលគេតាឈិនអីហ្នឹងពេលដែលគេចាប់តាឈិន សយ យៀនអីហ្នឹងពេលចាប់ទៅហ្នឹង ចាប់ ទាំងប្រពន្ធទាំងកូនគាត់ទៅដែរឬក៏ចាប់តែ ចាប់តែឈិនហ្នឹងទៅទេ?

រឿន: អត់ទេ! គេឲ្យតែបងឈិនហ្នឹងទៅជាមួយនីរសាសោះ អត់មាននរណាទៅទៀតទេ ។

ដានី: ចុះប្រពន្ធគាត់ឈ្មោះយ៉ាតនៅ....មណ្ឌលគិរីដែរ?

រឿន: នៅមណ្ឌលគិរីដូចគ្នា ។

ដានី: នោរហូតដល់នេះឬក៏យ៉ាងម៉េច?

រឿន: ទាល់តែយូរបានគេយកទៅនោះ យូរបានគេហៅទៅនោះ យូរបានគេហៅទៅនោះ យូរបានគេហៅយកដាក់ទៅកន្លែងស្អីទេកន្លែងអ៊ីបួន..គេយកទៅដាក់នៅកន្លែងអីទេ...កន្លែងភូមិអីទេ ស្រែវង់នោះមិនដឹងភូមិអី? អ! គេយកទៅដាក់ គេត្រលប់យកមកដាក់នៅសុខសាន្តវិញ ។

ដានី: យកត្រលប់...?

រឿន: យកត្រលប់មកដាក់សុខសាន្តវិញ ពួកហ្នឹងមកនៅសុខសាន្ត ពួកមានប្រវត្តិអត់ល្អ ។ ប្រវត្តិប្ដីក្បត់អាហ្នឹងគេថាប្រវត្តិប្ដីក្បត់អាហ្នឹង គេថា ប្រវត្តិប្ដីក្បត់ ។ ហើយប្រធាន មេប្រធានដែលទទួលខុសត្រូវ ដែលអ្នកមានប្រវត្តិអ! មានការដូចថា ប្រវត្តិប្ដីក្បត់ប្ដីអីអញ្ចឹងមានកាវិន័យ ថាខុសវិន័យខុសអី ខុសសិលធម៌អីគឺមានតាឆិល ។

ដានី: តាឆិលហ្នឹងគាត់អ្នកគ្រប់គ្រង?

រឿន: កន្លែងសន្តិសុខ ។

ដានី: ស្រីៗដែលដូចថាមានអ្នកក្បត់អី ប្ដីក្បត់អីហ្នឹងអាហ្នឹងកន្លែងសន្តិសុខហ្នឹងនៅនៅអ៊ែ៨?

រឿន: ចា៎!

ដានី: ឈ្មោះតាឆិល?

រឿន: នៅ នៅសុខសាន្ត ។

ដានី: នៅសុខសាន្ត?

រឿន: ចា៎! ឥឡូវហ្នឹងតាឆិលហ្នឹងក៏នៅដែរ ។

ដានី: តាឆិលហ្នឹងនៅដែរ?

រឿន: នៅអន្លង់វែង ។

ដានី: តាឆិលហ្នឹងនៅអន្លង់វែង?

រឿន: ចា៎! តាឈួនក៏នៅអន្លង់វែង តាឆិលក៏នៅអន្លង់វែងផ្ទះទាល់គ្នាហ្នឹង ។

ដានី: នៅអន្លងវែងគេហៅភូមិអីទៅ? តាឆិល តាឈួន?

រឿន: ភូមិ...គេហៅភូមិទំកដុំ ។

ដានី៖ ភូមិទឹកជុំ?

រឿន៖ ចា៎!

ដានី៖ ឃុំអីដែរនៅនោះ?

រឿន៖ ឃុំ...ឃុំឃ្លាំងកណ្ដាល ។

ដានី៖ ឃុំ...នៅភូមិទឹកជុំ ឃុំឃ្លាំងកណ្ដាល?

រឿន៖ ចា៎! គេហៅឃ្លាំងកណ្ដាលកាលនោះ ។

ដានី៖ តាឆិលហ្នឹងគាត់នៅឈ្មោះតាឆិលដដែល នេះគាត់មានដូរឈ្មោះទៀតដែរអត់?

រឿន៖ នៅដដែល តាឆិលនោះ ។

ដានី៖ តាឆិល ។ ប្រពន្ធគាត់ឈ្មោះអីតាឆិលនោះ?

រឿន៖ ប្រពន្ធឈ្មោះយាយស្រី ។

ដានី៖ យាយស្រី?

រឿន៖ ចា៎!

ដានី៖ នៅដែរ?

រឿន៖ នៅ ។

ដានី៖ នៅទាំងប្ដីទាំងប្រពន្ធហ្នឹង ។

រឿន៖ តាឈួនហ្នឹងប្រពន្ធគាត់ឈ្មោះយាយនី ។ វរៈសេនាធំខាងផ្នែកនារី ។ វរៈសេនាធំពួកខ្ញុំ ។

ដានី៖ អញ្ចឹងប្រពន្ធឈិន ប្រពន្ធសយ ប្រពន្ធយៀនហ្នឹងពេលដែលគេចាប់ទៅអស់ហ្នឹងគេយកទៅដាក់ក្នុងស្រុកកន្លែងសុខសាន្តទាំងអស់?

រឿន៖ ចា៎! អ! ក្មួយគេយកទៅដាក់នៅសុខសាន្ត និងគេបញ្ជូលទៅខាងតំបន់ ។ ពួកតំបន់ជនជាតិណា៎! នៅសុខសាន្តណា៎!

ដានី៖ អញ្ចឹងបានន័យថា ប្រពន្ធៗគេយកទៅដាក់សន្តិសុខរបស់តំបន់?

រឿន៖ ចា៎! តំបន់ ។

ដានី៖ ចុះមីងតាតាឆិលដែលជាប្រធានសន្តិសុខនៅកន្លែងសុខសាន្ត ភូមិសុខសាន្តហ្នឹងគេសន្តិសុខរបស់កងពល ឬក៏សន្តិសុខរបស់តំបន់?

រឿន៖ របស់កងពល៩២០ហ្នឹង កងពលទីពីរហ្នឹង ។

ដានី៖ របស់កងពល៩២០ហ្នឹង កងពលទីពីរហ្នឹង?

រឿន៖ ចា៎!

ដានី៖ ចុះមីងម៉េចថាហ្នឹងជារបស់តំបន់វិញបើតាឆិលគាត់សន្តិសុខរបស់កងពល?

រឿនៈ យើង យើងនៅកន្លែងចាស់យើងពីដើម ។ ចា៎! យើងនៅកន្លែងចាស់មន្ទីរពេទ្យយើងពីដើម

ដានីៈ គ្រាន់តែថាកន្លែងនោះដីរបស់តំបន់?

រឿនៈ ចា៎! ដីរបស់តំបន់ ។

ដានីៈ ច្រើនដែរអត់ដូចថាអ្នកដែលប្ដីក្បត់អីដែលគេយកទៅដាក់កន្លែង?

រឿនៈ ចា៎! ច្រើន ពួកបងណោន ពួកបងរីនៅឬស្សីកែវហ្នឹង ហើយពួកបងណោនពួកមិត្តជាតិ ពួកមិត្តសូ ពួកមិត្តម៉ា មិត្តនៀនពួកមិត្តណាន ពួកច្រើនណាស់មិនដឹងនរណានរណើទេច្រើនណាស់ ។

ដានីៈ ចុះកន្លែងសន្តិសុខ កន្លែងសន្តិសុខហ្នឹងមានតែនារីៗ ឬក៏មានបុរសដែរ?

រឿនៈ មានដែរ មានបុរសមានតិចវាមិនសូវមានដូចថាខុសខូចសិលធម៌ជាមួយស្រីញីអីអញ្ចឹង អាហ្នឹងវាមានតែតិចណាស់ ឬក៏ជាពាក្យសម្ដីដែលមិនសមរម្យគ្មានសិលធម៌ គេថាដូចគ្មានសិលធម៌១២យ៉ាងចំពោះខ្លួន ។ គេថាគ្មានសិលធម៌ចំពោះញាតិមិត្តអីអញ្ចឹង ច្រើនប្រើពាក្យសម្ដីទោសៈ មោហៈចំពោះខ្លួនអីអញ្ចឹងណា ។ ហ្នឹងធ្វើការផាវខ្លិលប្រអូសខ្លិលធុញទ្រាំអីអញ្ចឹងទៅនៅកន្លែងនោះហើយ ។

ដានីៈ ទៅនៅកន្លែង...?

រឿនៈ កន្លែងសន្តិសុខហ៎យ ។

ដានីៈ បាទ! នៅកន្លែងសន្តិសុខហ្នឹងមានរួចមកវិញដែរ ឬក៏នៅហ្នឹងជាប់សន្តិសុខហ្នឹងរហូត?

រឿនៈ មានទេ! គេបង្កើតស្រូវបង្កើតអង្ករ បង្កើតស៊ី ដំនាំដាំដុះគេប៉ុណ្ណឹងឯងគេសប្បាយជាងពួកកងទ័ព្វ សម្បូរស៊ីទៀត ។ គេប្រើអញ្ចឹងណា គេមានយកទៅអីទេ ។

ដានីៈ ចុះមីង មីងគិតមើលមីងមានចាំឆ្នាំពិតច្បាស់ដែរអត់ដែលគេផ្លាស់ប្តូរកងពលដូចថាតាឈិនហ្នឹងចាប់បាត់ទៅហើយឡើង០៦ជាប្រធានកងពលហ្នឹងឆ្នាំណាមីងចាំច្បាស់ដែរអត់?

រឿនៈ ហ្នឹងដូចថា ខ្ញុំអត់ច្បាស់មិនដឹង...វាដូចថាឆ្នាំ៧៦ ។

ដានីៈ ៧៦មីងរៀបការហើយ ។

រឿនៈ ចា៎!

ដានីៈ មីងរៀបការបានរយៈពេលប៉ុន្មាន?

រឿនៈ រៀបការហើយដែលបង០៦រៀបការខ្ញុំហើយបានប៉ុន្មានខែគេចាប់ពូឈិនហ្នឹងឡើងយន្តហោះទៅនោះ ដូចខ្ញុំនិយាយពីដើមដំបូងអញ្ចឹង ។

ដានីៈ ប៉ុន្តែការចុងឆ្នាំដើមឆ្នាំ?

រឿនៈ ចា៎! អាចដើមឆ្នាំអីហ្នឹងហើយ អូ! ចុងឆ្នាំ ។

ដានីៈ មីងការដូចថាមីងនិយាយមិញដូចថាខែភ្លៀង ឬក៏ខែ...?

រឿនៈ ខែ៧ ។

ដានីៈ កាលមីងទៅពីក្រចេះមីងថាខែ៧? ខែភៀង? ដល់ពេលការ?

រឿនៈ ទេ! អាហ្នឹងមិនមែនឆ្នាំ៧១ទេ!

ដានីៈ អាហ្នឹង៧៥ ប៉ុន្តែអាពេលការ ការខែ៧ដូចគ្នា?

រឿនៈ ខែ៧ ៧៦ ។

ដានីៈ ខែ៧ ៧៦ដែរ?

រឿនៈ ចា៎! ខែ៧ ៧៦ថ្ងៃប៉ុន្មានទេ គេធ្វើ ដូចគេធ្វើថៃ១០ ថ្ងៃ២០ គេជុបលៀងនំបញ្ចុក គេជុបលៀងអីកាប់គោកាប់អី កាលនោះ ។

ដានីៈ មីងការបានរយៈពេលបន្ទាន់បានគេចាប់គាឈិនទៅហើយឡើង០៦ជាគណៈដូចថាកងពល?

រឿនៈ គេចាប់ទៅបានប្រហែលជា៣ ៤ខែ ខ្ញុំទំនេរពោះបាន២ ៣ខែដែរហ្នឹងណា អាច២ខែអី ៣ខែមិនដឹង ។ យើងមិនបានគិតគូររឿង ។

ដានីៈ ចុះ០៦ប្រពន្ធគាត់ទៅជាមួយដែរអត់?

រឿនៈ ទៅ! យាយវីនទៅដែរ ។

ដានីៈ យាយវីន?

រឿនៈ ចា៎! កាលនោះគាត់ទើបបានកូន២ ។

ដានីៈ អ! ប្រពន្ធគាត់ឈ្មោះយាយវីន?

រឿនៈ ចា៎! យាយវីន ។

ដានីៈ ប្រពន្ធ០៦ឈ្មោះយាយវីន យាយវីនហ្នឹងគាត់ធ្វើអីពេលដែលគាត់ទៅនោះ?

រឿនៈ គាត់ទៅគេដាក់ខាងផ្នែកនារី ក្តាប់រឿងខាងផ្នែកនារីពេទ្យហ្នឹង ។

ដានីៈ ក្តាប់ជំនួសឈ្មោះយាយយ៉ាបហ្នឹង ឬក៏យ៉ាងមេច?

រឿនៈ អាចជំនួសអញ្ចឹងហើយមើលទៅប្រពន្ធកងពលព្រោះគាត់វរៈសេនាធំយាយវីនហ្នឹង ។

ដានីៈ វរៈសេនាធំនៅណា?

រឿនៈ ពីមុនមកកងទ័ព្វគាត់វរៈសេនាធំគាត់ធ្លាប់កាន់វរៈសេនាធំ ។

ដានីៈ កាលកងទ័ព្វគាត់មុននៅណា?

រឿនៈ អត់ដឹង! ខ្ញុំអត់ស្គាល់ផង ។

ដានីៈ ចុះមីងម៉េចដឹងថាគាត់វរៈសេនាធំពីមុនមក? មុនគាត់ទៅមណ្ឌលគីរីហ្នឹង?

រឿនៈ ខ្ញុំឮតែពួកមិត្តនិយាយថាយាយហ្នឹងវរៈសេនាធំថាអញ្ចេះ ធ្លាប់ឮពួកមិត្តនិយាយទៅហ្នឹងណា ។

ដានីៈ យាយវីនហ្នឹងអ្នកស្រុកកំណើតមកពីណាមក?

រឿនៈ អ្នកម៉េចទេណា? អ្នកកំពង់ឆ្នាំអី? យាយវិនទោះ ។

ដានីៈ យាយវិនអ្នកកំពង់ឆ្នាំ?

រឿនៈ ចា៎!

ដានីៈ បាទ! គាត់និយាយទូវ នូវ...

រឿនៈ ទូវ នូវ...?

ដានីៈ ចា៎! និយាយរខ្មើន ។

រឿនៈ រខ្មើនមិនមែនពួកតាកែវទេអញ្ចឹង? ទេគាត់ពាងនិយាយរខ្មើនៗដែរហ្នឹងណា? និយាយសំនំថាពួកភូមិភាគពីសេសណា៎!

ដានីៈ ភូមិភាគពិសេស?

រឿនៈ ចា៎! និយាយដូចភូមិភាគពិសេសអញ្ចឹងណា៎! ដូចភូមិភាគកណ្ដាល ភូមិភាគពិសេសគាត់និយាយ ។

ដានីៈ ចុះមីងកងពល៩២០ហ្នឹងដូចថាមានទាក់ទងនៅមណ្ឌលគិរី ចុះនៅខាងរតនៈគិរី?

រឿនៈ អត់ដឹង អត់ស្គាល់ ។

ដានីៈ ចុះមីងមានដែលឮកងពល៨០១ដែរអត់?

រឿនៈ ដែល ។

ដានីៈ កងពល៨០១នៅណា?

រឿនៈ នៅរតនៈគិរីហ្នឹង ។

ដានីៈ ចុះមិញមីងថាអត់ដឹងអត់ស្គាល់?

រឿនៈ ស្គាល់តែអញ្ចឹងតែអត់ស្គាល់ប្រធានមេកងគេ គ្រាន់តែឮ ។

ដានីៈ ប៉ុន្តែមីងធ្លាប់ទាក់ទងគ្នាដែរអត់?

រឿនៈ អត់! ខ្ញុំអត់ដែលទេ ។ ក្រែងមេៗមិនដឹង ។

ដានីៈ បាទ! ដូចថាកងពល៨០១ កងពល៩២០ហ្នឹងមានដែលទៅទាក់ទងធ្លាប់និយាយគ្នាធ្លាប់ដឹងសាច់រឿងគ្នាខ្លះដែរអត់?

រឿនៈ អត់ទេ! អត់ដឹងទេខ្ញុំ អត់ដឹង!

ដានីៈ ចុះមីងកាលជំនាន់នោះយើងឮ០៦ ០៥អី ០៥នៅណាដែរ ០៥នៅណាមានដែលដឹងដែរអត់?

រឿនៈ អត់! ទើបទៅនៅអន្លង់វែងបានស្គាល់តា០៥នោះ ។

ដានីៈ ទាល់ទៅដល់អន្លង់វែងបានមីងស្គាល់តា០៥?

រឿនៈ ចាំ! ទាល់មើលខ្ញុំដឹងប្រហែលស្គាល់បង០៥ហ្នឹងថ្ងៃការ វុធ ស្គាល់តែប៉ុណ្ណឹងត្រឹមហ្នឹងមក បែកខ្វែកគ្នាគេយកទៅវៃចោលទៅណា ។

ដានីៈ ការវុធណា?

រឿនៈ ការអា វុធកូនតា០៦នោះ ។ កូនទីមួយនោះ ។ អាហ្នឹងមិនកូនតា០៦ ប្រុសនោះ មីស្រី មិនកូនតា០៥ ចាំ!

ដានីៈ គាត់ជន្លៀសគ្នា០៥ ០៦?

រឿនៈ ចាំ! ជន្លៀសគ្នា ។

ដានីៈ ពេលដល់ទៅអន្លង់វែង?

រឿនៈ ចាំ! គាត់ជន្លៀសគ្នាទេ ២នាក់ហ្នឹងនោះ ។

ដានីៈ តា០៦កូនគាត់ឈ្មោះវុធ?

រឿនៈ ចាំ!

ដានីៈ ប្រុស? យកកូនតា០៥?

រឿនៈ ស្រី ។

ដានីៈ ស្រីឈ្មោះអីទៅ?

រឿនៈ អត់ស្គាល់ទេ ។

ដានីៈ បាទ! ការនៅអន្លង់វែង ។កាឆ្នាំណាទៅ?

រឿនៈ ការ...មិនដឹងឆ្នាំទេ មិនបានគិតគូរ ប៉ុន្តែឆ្នាំគេរដ្ឋប្រហារ ឆ្នាំហ្នឹងគេរដ្ឋប្រហារ រកសិនខ្ញុំ ។

ដានីៈ រដ្ឋប្រហានៅភ្នំពេញមីង ?

រឿនៈ អត់ទេរដ្ឋប្រហារនៅ...

ដានីៈ អន្លង់វែង?

រឿនៈ មើលឆ្នាំ?

ដានីៈ កាលពេលគេចាប់ប៉ុល ពតចាប់អីកាត់ទោសប៉ុល ពតអីនៅអន្លង់វែងនោះមិនមែនទេ?

រឿនៈ ឆ្នាំខាល នៅឆ្នាំខាលមិនដឹងឆ្នាំប៉ុន្មាន...ខាល ថោស រោង ម្សាញ់ មមី មមែ វក រកា ៨ឆ្នាំហើយ ។

ដានីៈ កាល៩៧ ៩៨?

រឿនៈ ចាំ!

ដានីៈ អ! កាលរឹកគេកាត់ទោសទេក្រោយមកមានសម្លាប់ សុន សេន គ្រួសាគាត់?

រឿនៈ ចាំ! ហ្នឹង!ៗ ការហ្នឹងវាការមុន ការមុនសម្លាប់សុន សេន ហ្នឹងហើយការមុន ។

ដានី:	អញ្ចឹងខ្ញុំចង់បកទៅកន្លែងមណ្ឌលគីរីវិញបន្តិច ។ អញ្ចឹងពេលដែលដូចថាពេលដែលគេផ្លាស់គា០៦ទៅកាន់នៅមណ្ឌលគីរីហើយ អញ្ចឹងការគ្រប់គ្រងកាលពីតាឈិន កាលតាឈិនហើយគា០៦គ្រប់គ្រងកងពលហ្នឹងវាខុសគ្នាយ៉ាងមេចដែរ កាលពីមុនមក?

រឿន:	កាលពីមុន! ហ្នឹងខ្ញុំនិយាយតាមតែផ្នែកខ្ញុំមើលឃើញនោះណា ក្នុងការរស់នៅរបស់ខ្ញុំ ខ្ញុំធ្លាប់ឃើញធ្លាប់ដឹងរស់នៅម៉ាជំនាន់ពូឈិនហ្នឹងពីបាកស៊ី ។

ដានី:	ឈិនពិបាកស៊ី?

រឿន:	ពីបាកណាស់ ចា៎! បរបរ បរបរលាយត្រពាំងបរបរលាយត្រពាំងហើយហូបតែទឹកប្របហុកបើថាប្រហុកមួយចានអញ្ចឹងផ្ទះគ្នោតប៉ុណ្ណណី ដល់បង០៦អត់អញ្ចឹងទេ ។ ចា៎! ហូបវាមានដូចថាបង០៦ ក្នុងការហូបចុកវាមានប្រសិទ្ធភាពជាងកាលជំនាន់ពូឈិនហ្នឹង ចា៎! វាមានជាតិ វាមានបិចេងអីបង០៦ តែពូឈិនហ្នឹងអត់ទេ ។ អញ្ចឹងបានថា ប្រវត្តិកងពលរស់នៅមានកងពលនេះល្អ មានកងពលនោះអាក្រក់អីអញ្ចឹង ។

ដានី:	ចុះក្រៅពីហូបចុក ដូចថា ការងារការវៃអីខុសគ្នាយ៉ាងមេចដែរ ដូចថាកាលពីជំនាន់តាឈិនហើយហ្នឹងកាលពីជំនាន់០៦?

រឿន:	រឿងវៃគុបរស់នៅនោះ?

ដានី:	បាទ!

រឿន:	អត់មានទៅវៃទៅអីទេ កាលរស់នៅមួយជំនាន់នោះ ទៅនៅកោះញែកមានតែវៃខាងផ្នែកពលកម្ម ។

ដានី:	ធ្វើការងារ?

រឿន:	ធ្វើការងារ ។

ដានី:	ហ្នឹងកាលជំនាន់?

រឿន:	ជំនាន់តាឈិន ។ អត់មានគិតយប់គិតថ្ងៃទេធ្វើ ។ រួចគេថាដាំៗមិនឲ្យសល់ដីនោះណា សូម្បីកណ្តាលចង្ក្រានកឲ្យដាំដែរ ។ អានោះគេយកវៃចោលអស់មួយហើយ ។

ដានី:	គេថាអញ្ចឹង?

រឿន:	ចា៎! ថាអញ្ចឹងគេយកទៅវៃចោល ។

ដានី:	ឈ្មោះអីទៅ?

រឿន:	ឈ្មោះពូសំ ។

ដានី:	សំហ្នឹងគាត់និយាយថាម៉េច?

រឿនៈ គាត់ថា គាត់ដើរស្រែកនៅមន្ទីរពេទ្យកន្លែងរោងបាយ ដាំៗពួកយើងមិត្តយើងដាំ ដាំៗកុំឲ្យសល់ដីសូម្បីតែដីកណ្ដាលចង្ក្រានក៏ដាំដែរ ។

ដានីៈ ដល់ពេលអញ្ចឹង...?

រឿនៈ គេយកទៅវ៉ៃចោលទៅ ចា៎! យកទៅវ៉ៃគ្នាចោលទៅណា ។

ដានីៈ ឆ្នាំណាគេវ៉ៃឈ្មោះស៊ុំហ្នឹងចោល?

រឿនៈ ឆ្នាំប៉ុន្មានទេ? ឆ្នាំ៧៥មិនដឹង? យើងដាច់ភ្នំពេញហើយនោះ ។ ទៅមណ្ឌលគីរីហើយនោះ

ដានីៈ ពីណាគេអ្នកចាប់គាត់យកទៅវ៉ៃចោលហ្នឹង?

រឿនៈ ពួកពិសេស កងពិសេស ។

ដានីៈ កងពិសេស?

រឿនៈ ពិសេសតាឈិននោះ ។ ខ្ញុំអត់ស្គាល់ ។

ដានីៈ ដល់ពេលប្រជុំគេមានលើកអីពីរឿងសំហ្នឹងទេ?

រឿនៈ អត់ទេ! តែចាប់ហើយនោះ...គេលើកតើមហាសន្និបាត ។

ដានីៈ គេលើកថាម៉េច?

រឿនៈ កុំឲ្យយកតម្រាប់តាមពូសំហ្នឹងទៀត កុំឲ្យអាហ្នឹង...គេហៅពាក្យបញ្ឈឺ ដាំៗមិនឲ្យសល់ដីសូម្បីតែដីកណ្ដាលចង្ក្រានក៏ដាំដែរ ។ ដីកណ្ដាលចង្ក្រានបានអីស៊ី បានអីដាំស៊ីបើដាំកណ្ដាលចង្ក្រានហើយ មានអីដុតអីទៀត វាអញ្ចឹង!

ដានីៈ គេថាអញ្ចឹង?

រឿនៈ ចា៎!

ដានីៈ ចុះកាលជំនាន់ឈិនហ្នឹងដូចថាមានចាប់ ដូចថា យុទ្ធជន យុទ្ធនារី កម្មាភិបាលអី គេមានចាប់ទៅច្រើនទេ ចាប់យកទៅវ៉ៃចោលច្រើនដែរ?

រឿនៈ នៅជំនាន់ពូឈិន?

ដានីៈ បាទ!

រឿនៈ ខ្ញុំម៉ាជំនាន់ពូឈិនហ្នឹងមិនថាម៉េចទេ ដូចថាមានដែរ គ្រាន់តែថាវារង្វើល ដាងមុនអាចុងឆ្នាំដែលមុនបង០៦ទៅ អាហ្នឹងសាហាវណាស់ហ្នឹង ។

ដានីៈ ដល់ពេល០៦ទៅសាហាវហ្មង?

រឿនៈ ចា៎!

ដានីៈ កាល០៦ទៅគេចាប់យ៉ាងមេចខ្លះទៅមីង?

រឿនៈ បង០៦ទៅ មិនមែនថា មាំជំនាន់បង០៦ មាំជំនាន់ពូឈិនហ្នឹងគិតទៅអាដើមឆ្នាំហ្នឹងអាចុងឆ្នាំហ្នឹងវាប៉ះគ្នាត្រូវវៃ ត្រូវសម្លាប់ចោល សម្លាប់ចោល ។

ដានីៈ ពួកសម្លាប់ចោលពួកកងទ័ពហ្នឹង? ...ចុះមីងកាលគេសម្លាប់ កាលគេចាប់ហ្នឹងដូចថាចាប់កងទ័ពហ្នឹង?

រឿនៈ ចាំ! ចាប់ជួរកងទ័ពហ្នុង ។ រស់នៅកងកងទ័ពអាធំចាប់ៗ

ដានីៈ ចាប់ហ្នឹងគេចាប់បញ្ជូនទៅភ្នំពេញឬគេចាប់ទៅដាក់កន្លែងសន្តិសុខដែលមីងនិយាយថា ឈ្មោះ?

រឿនៈ អត់! តែចាប់ហើយគឺអត់មានដឹងថាទៅខាងណា ។

ដានីៈ តាឆិលហ្នឹង?

រឿនៈ មិនដឹងទៅខាងណាទេ? ទៅខាងតាឆិលក៏មិនដឹង ទៅខាងណាក៏មិនដឹង តែបាត់ពីកន្លែងអង្គភាពទៅហើយ ។ មិនដឹងទៅខាងណា ទៅរៀនសូត្រ ដូនកាលរៀនទៅបាត់មួងទៅ ។

ដានីៈ បាទ! ចុះដូចថាសំហ្នឹងមីងថាគេចាប់យកទៅវៃចោល?

រឿនៈ ចាំ!

ដានីៈ គេវៃចោលនៅណាទៅ?

រឿនៈ មិនដឹងគេយកទៅវៃចោលនៅណា បើបាត់មនុស្ស ជ្រាបបណ្ដោយ គេយកទៅវៃចោលមួយជំនាន់នោះ បើនៅនោះមកវិញហើយ ។

ដានីៈ បាត់! ឈងទៅ មីងថាគេយកទៅវៃចោលបណ្ដោយ?

រឿនៈ ចាំ! យកទៅវៃចោលហើយ តាចាប់អញ្ចឹងយកទៅវៃចោលហើយ តែគេចាប់ហើយគឺដឹងថាវៃចោលហើយ ។

ដានីៈ ចុះនៅជិតកន្លែងកងពលអីហ្នឹងមានកន្លែងគេវៃមនុស្សគេវៃអីចោលអីដែរអត់?

រឿនៈ អត់! មានតែឆ្ងាយ ។

ដានីៈ ចុះមីងពេលដែល០៦ទៅ មានការចាប់កងទ័ពចាប់អីច្រើនអីអញ្ចឹងមានគេយកកងទ័ពថ្មីៗទៅបញ្ចូលថ្មីទៀតដែរអត់?

រឿនៈ ហ្នឹងអត់មានទេ! មានតែទ័ពចាស់ហ្នឹង ។

ដានីៈ នៅតែទ័ពចាស់ទេអញ្ចឹង?

រឿនៈ ចាំ!

ដានីៈ ដល់ចាប់អញ្ចឹងវាមិនអស់កងទ័ព? បើគេអត់បញ្ចូលថ្មីអញ្ចឹង ។

រឿនៈ មិនសាយអស់ឯណា បើកងទ័ពមាគគោកនោះរាប់ម៉ឺននោះ ។

ដានី៖ ដូចថាយើងក្នុងកងពល ក្នុងវរៈក្នុងកងធំអីអញ្ចឹងវាមានចំនួនវា ដល់ពេលគេចាប់ទៅវាមិនខ្វះ? ខ្វះដូចថា ខ្វះមនុស្ស ខ្វះអីដើម្បីបង្គ្រប់ជាលក្ខណៈជាកងធំកងតូច កងវរៈអី?

រឿន៖ ចា៎!

ដានី៖ តែអញ្ចឹងគេអត់បញ្ចូលថែមទេ?

រឿន៖ អត់មានទេ! កងទ័ពយើងច្រើន មានតែបញ្ជូនខាង ដូចថាខាង១០៥អីអញ្ចឹងគេ...យើងយកកងទ័ពយកប្រជាជន១០៥ យកប្រជាជនជនជាតិហ្នឹងយកទៅវៃនៅសមរភូមិ ។ ចា៎! ដល់យកទៅវៃនៅសមរភូមិហ្នឹង កាលមុនដាច់ភ្នំពេញហ្នឹងគេយកទៅវៃនៅសមរភូមិដល់ទៅពេលនេះមានការស្លាប់នូវយុទ្ធជនខាង១០៥ហ្នឹងគេឲ្យសងមនុស្ស១០០នាក់ សងហើយណា៎!ៗ ស្រី៥០ ប្រុស៥០យកទៅឲ្យនៅជាមួយតំបន់ ។

ដានី៖ អ! បានន័យថា គេយក...កងទ័ពហ្នឹងយកប្រជាជន យកយុទ្ធជនយុវនារីនៅតំបន់ពួកជនជាតិនៅខាង១០៥ឲ្យទៅវៃខ្មាំង អញ្ចឹងកងពល៩២០អត់ទៅវៃខ្មាំងទេអញ្ចឹង?

រឿន៖ ទៅ! តែគេសម្រុកចូលដើម្បីឲ្យឆាប់នោះណា ។

ដានី៖ គេយកយុទ្ធជន យុវនារីហ្នឹងទៅវៃជាមួយគ្នាដែរ?

រឿន៖ ចា៎! ទៅវៃ! ពួកនារីវៃសុទ្ធតែវៃខ្មាំងហើយនារីនោះ ម៉ាជំនាន់មិនបានទេ ។

ដានី៖ គេយកទៅចូលជាមួយដែរ ឬក៏គេកងទ័ពពួកយុទ្ធជន យុវនារី១០៥នោះកងទ័ពគេផ្សេង?

រឿន៖ ដោយឡែកពីគ្នា ។

ដានី៖ ដោយឡែក?

រឿន៖ ចា៎!

ដានី៖ ចុះមេចបានគេឲ្យសង បើឲ្យដោយឡែកគ្នា?

រឿន៖ ចុះបើក្រែងពួកយើងសន្យាជាមួយគេ ដឹងសន្យាថាម៉េចបើសិនណាជាមានការស្លាប់រស់គេនឹងសងកងទ័ពទៅវិញអីអញ្ចឹងអី មិនស្រួលអញ្ចឹងហើយបានគេពួក១០៥គេទាមទារយើងយក កងទ័ពគេ...យកមនុស្ស១០០នាក់នោះ ។

ដានី៖ ចុះមិញខ្ញុំភ្លេចសួរមីងទាក់ទងអាកន្លែង...នារីកង១០០! កាលហ្នឹងកើតតាំងពីជំនាន់ឈិន?

រឿន៖ ចា៎!

ដានី៖ កាលហ្នឹងគេជ្រើសរើសនារីកង១០០ហ្នឹងគេជ្រើសរើសយ៉ាងម៉េចខ្លះទៅមីង?

រឿន៖ គេជ្រើសរើសនារីក្មេងៗ យកទៅតំកល់នៅកន្លែង១០០ហ្នឹង ប៉ុន្តែខ្ញុំគ្រាន់តែឮគេថាអារឿងកង១០០ហ្នឹងបើសួរដូចសួរថាបងម៉ោងហ្នឹងបានដឹងថាវាក្បោះក្បាយល្អ ។មីម៉ោងនៅនេះ! ព្រោះគាត់មេពួកហ្នឹង មេពួកកង១០០ហ្នឹង ។

ដានី៖ មីម៉ោងនៅណា?

រឿន៖ មីម៉ោងនៅស្ពឺរកាធំនោះ ម៉ម៉ោងនោះ អត់ស្គាល់ទេ ប៉ុនពួកភូមិពួកមូលដ្ឋានមេច ដូចពួកកងទ័ព ពួកហ្នឹងនោះពួកកងទ័ព។

ដានី៖ បាទ! គេជ្រើសរើសយ៉ាងមេចអានារីកងមួយរយនោះ ជ្រើសរើសនៅក្នុងយុទ្ធនារីនៅក្នុងកងពលហ្នឹងឬក៏រើសមកពីកន្លែងណាមក?

រឿន៖ រើសពីក្រចេះហ្នឹងទៅ នៅស្រុកព្រែកប្រសប់។

ដានី៖ នៅស្រុកព្រែកប្រសប់?

រឿន៖ ចា៎!

ដានី៖ រើសប្រជាជនទៅ?

រឿន៖ ចា៎! រើសកូនប្រជាជនទៅ។

ដានី៖ អ! រើស១០០នាក់?

រឿន៖ រើស១០០នាក់។

ដានី៖ ១០០នាក់។ រើសដូចថាលក្ខណៈយ៉ាងម៉េចសម្បូរស្អាត់បាត់ ឬក៏យ៉ាងមេច?

រឿន៖ អត់មានទេ! ធ្វើម៉េចឲ្យតែបាននារីលីវ។

ដានី៖ នៅលីវ១០០នាក់?

រឿន៖ ចា៎! ១០០នាក់។

ដានី៖ តួនាទី បើតាមមីង...ដូចថាមីងដឹងដូចថាតួនាទីរបស់នារីកង១០០ហ្នឹងសម្រាប់ធ្វើអីទៅ?

រឿន៖ នារីកងមួយរយហ្នឹងដូចសម្រាប់ដូចថា...មិនមែនយកឲ្យកងទ័ពខ្មែរទេ ដូចថាតាមការយល់ដឹងរបស់ខ្ញុំដែលខ្ញុំតាមឮពាក្យ តាមឮសំដីរបស់គេទេណា អញ្ចឹងខ្ញុំមិនបានឮផ្ទាល់ដូចចេះតែនិយាយទេណា...ប៉ុន្តែខ្ញុំឮតាមបទញ្ញាគេថា សម្រាប់អ្នកធំអ្នកតូច សម្រាប់យួនសម្រាប់អីមកសប្បាយខាងយើងអីអញ្ចឹង ដូចយើងទៅខាងវាអញ្ចឹងណា អាហ្នឹងរឿងហ្នឹងអញ្ចឹង។ សម្រាប់សប្បាយរបស់វាហ្នឹងណា។

ដានី៖ សម្រាប់សប្បាយម៉េចទៅ?

រឿន៖ មិនដឹងទេស្រីប្រុស សប្បាយស្រីប្រុសនោះ។

ដានី៖ សប្បាយស្រីប្រុស?

រឿន៖ ចា៎! មិនដឹងសប្បាយយ៉ាងមេច យ៉ាងម៉ាខះទេណា....

ដានី៖ ប៉ុនក្នុងសមាសភាពដូចថានារីកង១០០ហ្នឹង មីងស្គាល់ពីណាម្នាក់ដែរអត់?

រឿន៖ ស្គាល់តើ!

ដានី៖ ពីណាគេឈ្មោះអីទៅ?

រឿន៖ ឈ្មោះបងម៉ៅន ឈ្មោះបងមាន ឈ្មោះណាណី ។

ដានី៖ ឈ្មោះម៉ៅន ឈ្មោះមានសព្វថ្ងៃគាត់នៅរស់ដែរអត់?

រឿន៖ នេះនៅនេះ!

ដានី៖ នៅណាទៅ?

រឿន៖ រកាធំ ។

ដានី៖ នៅភូមិរកាធំយើងនេះ ។

រឿន៖ ចាំ!

ដានី៖ ឈ្មោះម៉ៅន?

រឿន៖ ឈ្មោះម៉ៅន ។ ទៅសួរគេឈ្មោះយាយម៉ៅនស្គាល់ហើយ ។

ដានី៖ យាយម៉ៅននៅភូមិរកាធំ?

រឿន៖ ចាំ!

ដានី៖ ឃុំជ្រោយបន្ទាយយើងដែរ?

រឿន៖ ចាំ!

ដានី៖ ស្រុកព្រែកប្រសប់?

រឿន៖ ចាំ! ឈ្មោះបដិវត្តន៍ឈ្មោះបងមាន ឈ្មោះយាយមាន ។

ដានី៖ ម៉ៅនហ្នឹងឈ្មោះបដិវត្តន៍ឈ្មោះមាន?

រឿន៖ ចាំ!

ដានី៖ ចុះមីងបើយើងទៅ ទៅរកគាត់សួរថាយាយម៉ៅនអញ្ចឹងគេស្គាល់ហើយ?

រឿន៖ ហឺ! ពីណាក៏ស្គាល់ដែរមួយស្រុកនេះនោះ ។

ដានី៖ បាទ! យាយម៉ៅន ។ គាត់ធ្វើអីគេយាយម៉ៅននោះ?

រឿន៖ យាយម៉ៅននោះធ្វើប្រធានគេ ។

ដានី៖ ប្រធានកងមួយរយហ្នឹង?

រឿន៖ ប្រធានកងមួយរយ ។

ដានី៖ ប្ដីគាត់ឈ្មោះអីទៅឥឡូវ?

រឿន៖ អត់! ខ្ញុំអត់ស្គាល់ផងប្ដីគាត់ ព្រោះគាត់យកប្ដីពីរហើយ ។

ដានី៖ អ! ប្ដីពីរ? អញ្ចឹងកង១០០ដល់ពេល០៦ទៅក្រោយហ្នឹង នារីកង១០០ហ្នឹងនៅតែកង ១០០ដដែលឬក៏គេមាន...?

រឿនៈ អត់ទេ! គេបំបែកអស់ហើយ ។

ដានីៈ គេបំបែកចេញ?

រឿនៈ ចាំ! អានារីកង១០០ហ្នឹងនៅសុខសាន្តទេ ។ អត់មានម៉ាជំនាន់បង០៦ទេអត់មានឡ១០០ អត់មានអីៗទេ ។

ដានីៈ កាលជំនាន់នោះ០៦ ០៥មិនដែលទាក់ទងគ្នាទេមីង មីងអត់ដែលដឹងថា០៥ ០៦ទាក់ទងគ្នាទេ?

រឿនៈ អត់! អត់ដឹងផង ខ្ញុំមិនដែលដឹង ខ្ញុំស្មានថាតាយ៉មហ្នឹងគាត់ទៅរៀនទៅសូត្ររួចខ្ញុំមានដឹងថាតាយ៉មហ្នឹងចូលខ្មែរក្រហមឯណាអត់ដឹងទេ ។ ចាំ! ខ្ញុំមិនដឹងទេដល់ទៅជួបគ្នានៅមណ្ឌលគិរីទៅបានខ្ញុំមកជួបគេ...សំណុំតាយ៉មដល់ហើយសួរគ្នាឯងអញ្ចឹង សួរអានីប្រពន្ធគាត់ធួនថា ណែ! ដូចសម្ប សម្បបងប្អូនថៃយាងដល់ហើយនេះ ខ្ញុំថាអញ្ចេះ រួចនីគេថា បងមើលមីរឿនគេអត់ស្គាល់ទេ អត់ស្គាល់បងឯងទេ! ហឺ!មិនស្គាល់លេងចូលឆ្នាំវៃអញប្រលាក់អាវអស់រលីង ។ ហើយខ្ញុំសួរថា អញ្ចឹងបងឈ្មោះអី? មិនដឹងឈ្មោះអីសួរមិត្តនីមើល! ដល់ខ្ញុំសួរនីថា ឈ្មោះតាយ៉ម....អឺ! បានធ្វើមេធ្វើប្រធានម៉េចមាំកុំយកខ្ញុំវៃចោល ខ្ញុំថា ។ ដល់ស្គាល់គ្នាលេងឈូងជាមួយគ្នា ។

ដានីៈ ចុះ០៥ ០៦ហ្នឹងមីងដែលដឹងពីដូចថាហេតុអីបានគេដាក់០៥ ដាក់០៦អញ្ចឹង?

រឿនៈ លេខមូលគេណាក្មួយ!

ដានីៈ លេខមូលគេ?

រឿនៈ លេខ លេខគេអូណា ។

ដានីៈ លេខគេអូ?

រឿនៈ ចាំ! លេខគេអូ ឬលេខកងវរៈ ឬក៏លេខកងវរៈសេនា...តាមវរៈសេនាធំអីអញ្ចឹងណា ។ គេដាក់អញ្ចឹងឯងទេ ។

ដានីៈ ចុះ០៥ ០៦ដែល ដែលឃើញជួបទាក់ទងគ្នាដែរអត់កាលមីងនៅមណ្ឌលគិរី?

រឿនៈ អត់! អត់ដែលឃើញ?

ដានីៈ អត់ដែលឃើញ?

រឿនៈ ចាំ! អត់! ដល់មកនៅអន្លង់វែងនេះទេ បានឃើញគាត់ទាក់ទងគ្នា ។ ទាក់ទងគ្នាក៏ត្រឹមអាជែងស្តី ត្រឹមជណ្តើងកូន ជណ្តើងអី ។

ដានីៈ ០៥ឈ្មោះអីទៅ០៥?

រឿនៈ តាសារឿន ។

ដានី: ឈ្មោះតាសារឿន។ ស្អីសារឿន?

រឿន: ដឹងឈ្មោះអីទេ....ដីតា? ដឹងឈ្មោះតាសារឿន។

ដានី: តាសារឿន?

រឿន: ចា៎! មិនដឹងដាកែវ សារឿន ឬស្អីសារឿន...។

ដានី: ចុះអ! តា៨០ឈ្មោះនៅ...សព្វថ្ងៃហ្នឹងគាត់នៅអន្លង់វែងដែរ ឬក៏អត់ទេ?

រឿន: នៅរមួលនេះ ប៉ុនព្វថាស្លាប់ហើយឥឡូវនេះ ស្លាប់បានប៉ុន្មានខែមួយខែ ពីរខែហើយ ។

ដានី: ៨០ឈ្មោះអីមីងអត់ចាំទេ?

រឿន: អត់ចាំទេ! ចាំតែប្រពន្ធឈ្មោះយាយគឿន។

ដានី: ប្រពន្ធឈ្មោះសុ គឿន។

រឿន: ចា៎!

ដានី: នៅណា នៅរមួល?

រឿន: នៅរមួល ។

ដានី: រមួលនៅណានៅមួល?

រឿន: រមួលអត់ដឹងនៅណាទេ អត់ស្គាល់ទេ។ ណែ៎! រមួលនៅណា? នៅណាទេ ហៅរមួលៗ មិនដឹងណារមួល ។

ដានី: ចុះមីងកាលនៅ កាលនៅ កាលតា០៦គាត់កាន់កាប់នោះ ដូចថាមានវៃជាមួយខាងវៀត ណាមអីដែរអត់?

រឿន: មាន! កាលនៅកោះញែក។

ដានី: កាលនៅកោះញែក?

រឿន: ចា៎! មាន!

ដានី: វៃនៅកន្លែងណាទៅ វៃជាមួយវៀតណាម?

រឿន: វៃជាមួយវៀតណាម ទីមួយនៅទុយោសាំ ទីពីរនៅកោះរំយោល នៅស្រែពួកនោះ។

ដានី: វៃនៅទុយោសាំង ហើយនិងកោះរំយោល ។

រឿន: ចា៎!

ដានី: កាលហ្នឹងមីងមានបានចូលវៃជាមួយគេដែរអត់?

រឿន: ខ្ញុំអតទេ! ខ្ញុំមានកូនហើយនោះ។

ដានី: ចុះគ្រួសារមីងមានបានចូលទៅវៃដែរអត់?

រឿន: គ្រួសារខ្ញុំទៅតើ តែមិនដឹងជាបានវៃ មិនបានអត់ដឹងដែរ ។

ដានី៖ វ៉ៃតែ២ដងតើអី វ៉ៃនៅទុយោសាំង ហើយនិងកោះរំយោល?

រឿន៖ ចា៎!

ដានី៖ វ៉ៃទុយោសាំងមីងចាំឆ្នាំដែរ វ៉ៃនៅឆ្នាំណា?

រឿន៖ ទុយោសាំងមិនដឹងវ៉ៃនៅឆាំណា? ដូច....ឆ្នាំ៧៨? ៧៨ហើយ៧៩ចេញពីកោះញែក ។

ដានី៖ ទុយោសាំងហ្នឹងនៅក្នុងដីយើងទេតើអី?

រឿន៖ នៅក្នុងដីយើង នៅទន្លេស្រែពួក ។

ដានី៖ បានន័យថា វៀតណាមគេចូលដីយើងវ៉ៃជាមួយយើងឬក៏ម៉េច?

រឿន៖ វៀតណាមចូលមកដីយើងណា!

ដានី៖ បាទ! ដល់ពេលវ៉ៃហ្នឹងយ៉ាងមេចខាងណាឈ្នះចាញ់?

រឿន៖ ខាងយើងចាញ់!

ដានី៖ ខាងយើងចាញ់យ៉ាងម៉េច? ដល់ពេលចាញ់រត់?

រឿន៖ ចា៎! រត់ចេញពីកោះញែកមក ។ យើងចាញ់យើងរត់ចេញពីស្រុកភូមិអីវ៉ាន់ប្រដាប់ប្រដា នៅនោះ ទាំងអស់នោះណា!

ដានី៖ រត់ចេញពីកោះញែក?

រឿន៖ ចា៎!

ដានី៖ រត់ចេញពីកោះញែកទៅនៅណាវិញទៅបើគេចាញ់នៅទុយោសាំង?

រឿន៖ នៅតាមព្រៃ នៅតាមតែព្រៃ ។

ដានី៖ តាមព្រៃណាទៅ?

រឿន៖ តាមព្រៃមណ្ឌលគិរីហ្នឹង តាមព្រៃហ្នឹង ។

ដានី៖ ចុះវ៉ៃនៅទុយោសាំង ហើយនៅរំយោលហ្នឹងវ៉ៃពេលណាមុន?

រឿន៖ វ៉ៃទុយោសាំងមុន ។

ដានី៖ វ៉ៃទុយោសាំង?

រឿន៖ ចា៎! ផ្ទុះនៅទុយោសាំងមុនបានទៅវ៉ៃនៅកោះរំយោល ។ មានគមាកងដូចថា គេម្នាកនោះ ទៅវ៉ៃខាងស្ទឺ កោះរំយោលទៅ អានេះខាងទុយោសាំងទៅ ឯនោះខាងពេជ្រចិន្តាទៅ ខាង នោះបាក់ផ្កាទៅ ខាងផ្នែកពេជ្រចិន្តាកែវសីមា គេវាយខ្សែត្រៀមរហូតតាមទន្លេស្រែពក ហ្នឹងគេវាយខ្សែត្រៀមរហូតគេការពារទ័ព្វនោះ ។

ដានី៖ ដល់ពេលដែលវ៉ៃនៅទុយោសាំងនោះ ហើយនៅកោះរំយោលនោះវ៉ៃដឹណាលគ្នាហ្នឹងដែរឬ ក៏អត់ទេ?

រឿនៈ  មុនក្រោយ ។

ដានីៈ  មុនក្រោយ?

រឿនៈ  ចា៎! មើលវ៉ៃកោះរំយោលហើយបានឃើញវត់ ។

ដានីៈ  អញ្ចឹងវ៉ៃទុំយោសាំងដឹបូងអត់ទាន់វត់ទេ?

រឿនៈ  នៅទេ! ទើបរៀបចំ ។

ដានីៈ  ដល់ពេលពេលវ៉ៃក្រោយនៅកោះរំយោលវ៉ៃចាញ់ទៀត វត់បណ្ដោយ?

រឿនៈ  វត់ដាច់បាយបណ្ដោយ ដាច់បាយដាច់ទឹក មិនដែលមានបាយស៊ី ពាឆ្នាំអត់អំបិលខ្ញុំ ។ អត់មានអំបិលស៊ីទេ អត់អំបិលពាឆ្នាំ ។

ដានីៈ  កោះរំយោលនៅកោះញែកហ្នឹងអី?

រឿនៈ  ចា៎! កោះរំយោលនៅកោះញែកហ្នឹងហើយ ។

ដានីៈ  បាទ! អញ្ចឹងវ៉ៃពេលវ៉ៃកោះរំយោលហ្នឹង វ៉ៃហ្នឹងពេលហ្នឹងបែកបែកឆ្នាំ៧៩ហើយ?

រឿនៈ  ចា៎ ឆ្នាំ៧៩ ។

ដានីៈ  ពេលហ្នឹងដល់ពេលវ៉ៃបែកនៅកោះរំយោល វត់ទៅតាម តាមព្រៃហើយ?

រឿនៈ  នៅតាមព្រៃ ហ្នឹងហើយដាច់បាយដាច់ម្ហូបដាច់អីស៊ី ។

ដានីៈ  ហ្នឹងដែលមីងនិយាយថា ដាច់បាយ ដាច់អំបិល?

រឿនៈ  ចា៎! ដាច់អំបិលពាឆ្នាំ ។

ដានីៈ  អត់ទឹកអត់អីហ្នឹង?

រឿនៈ  អត់ទឹកអត់អីហ្នឹងហើយ ។ វត់អាពត់អាពាយដូចកូនឆ្កែ ។

ដានីៈ  កាលនោះប្ដីរបស់មីងមានឡើងឋានៈមានអីទៀតដែរអត់? ពេលដល់ពេលវ៉ៃអី?

រឿនៈ  អត់ទេ! គាត់នៅដដែល គាត់ទទួលខុសត្រូវអ្នកពិការ ដើរជញ្ជូនតែអ្នកពិការហ្នឹង ។

ដានីៈ  គាត់មានឋានៈអីដែរ?

រឿនៈ  កងធំ ។

ដានីៈ  គាត់កងធំដដែល?

រឿនៈ  ចា៎! នៅដដែល ។

ដានីៈ  ប្រធានកងធំ?

រឿនៈ  ប្រធានកងធំក្ដាប់រួមពួកអ្នកពិការណា៎!

ដានីៈ  អ! អញ្ចឹងពេលនៅតាមព្រៃរហូតដល់ពាឆ្នាំបានជួបក្រុមធំប៉ុក៏យ៉ាំងមេច?

រឿនៈ ហ៎! ដូចបង០៦អីគាត់មកនៅស្រុកថៃអស់ហើយហ្នឹង គេឡើងមកនៅលើ ដូចថា កងទ័ព ប្រពន្ធកូនបង០៦ ឬក៏បង៨០អីគេនាំប្រពន្ធកូនគេឡើងលើភ្នំអស់ហើយហ្នឹង តែពួកខ្ញុំទេ! ពួកខ្ញុំកាច់នៅក្រោយទេដែលរស់នៅមកមិនទាន់គេ ខ្ញុំមានកូនមានចៅមកមិនរួចនោះណា! យើងគេត្រូវឡើងភ្នំ យើងជិតឆ្លងទន្លេអីអញ្ចឹងណា! គេរត់ចោលខ្ញុំឆ្លងទន្លេម្នាក់ឯងក៏ឃើញដែរ ។

ដានីៈ កាលហ្នឹងកាលមីងនិយាយថា ដល់ពេលមីងនៅអត់ទាន់គេ នៅអត់អីហ្នឹង ដូចថា នៅក្នុងក្រុមប៉ុន្មាននាក់ទៅ?

រឿនៈ នៅក្នុងក្រុមហ្នឹងមួយកង មួយកងតូច៣០នាក់ ។

ដានីៈ ម៉ា! ៣០នាក់កងតូចនោះ?

រឿនៈ ចា៎! ៣០នាក់ ។

ដានីៈ នៅម្តុំណាទៅ ម្តុំ?

រឿនៈ កាលនោះនោអូតូបបែកគ្នាបែកជាក្រុមពួក ពួកពេទ្យផ្សេង ពួកកងទ័ពផ្សេងនៅបែកៗគ្នា ។

ដានីៈ នៅអូតូប?

រឿនៈ ចា៎!

ដានីៈ អូតូបហ្នឹងភ្នំ?

រឿនៈ ភ្នំចេះតែមានហើយប៉ុនមានតូចៗ មានអូរវ៉ាអូរ ។

ដានីៈ អញ្ចឹងនៅអូតូបប្រហែលជា៥ ៦ខែមីងទៅណាទៀត?

រឿនៈ ដែលមកនៅអូតូបរួចហើយទៅនៅខាងម៉ាដូវកែបសីមា ។

ដានីៈ ទៅនៅខាងកែបសីមា?

រឿនៈ ចា៎! ត្រលប់ទៅនៅខាងកែបសីមាវិញ ។

ដានីៈ នៅកែបសីមាបានរយៈពេលប៉ុន្មានទៅ?

រឿនៈ នៅកែបសីមារយៈពេលប្រហែលជាប២ខែ ៣ខែដែរ ។

ដានីៈ នៅក្នុងព្រៃដែរនៅកែបសីមាហ្នឹង?

រឿនៈ ក្នុងព្រៃពីសុទ្ធហ្នឹងណា ។

ដានីៈ ម៉ាកងតូចរបស់មីងដដែលហ្នឹង?

រឿនៈ ចា៎! ម៉ាកងតូច ម៉ាកងធំម៉ាវរៈសេនាធំ បង៧៩ ខ្ញុំរស់នៅជាមួយ ។

ដានីៈ មានឈ្មោះវរៈសេនាធំ៧៩ទៀត?

រឿនៈ ចា៎! តា៧៩តានួននោះ ។

ដានី៖ គាត់នួននោះឈ្មោះតា៧៩?

រឿន៖ ចាំ!

ដានី៖ ចុះតា៧៩ គាត់នួនកាលនោះមណ្ឌលគីរីគាត់ធ្វើអី?

រឿន៖ គាត់វរៈសេនាធំ ។

ដានី៖ ប្រធានវរៈសេនាធំដែរ?

រឿន៖ ចាំ!

ដានី៖ ឈ្មោះគាត់នួនប្រធានវរៈសេនាធំ?

រឿន៖ ចាំ!

ដានី៖ អញ្ចឹងចេញពីកែបសីមាទៅណាទៀត?

រឿន៖ ចេញពីកែបសីមាមកនៅព្រៃស្អាក់ ។

ដានី៖ នៅព្រៃស្អាត?

រឿន៖ ព្រៃស្អាក់ ។

ដានី៖ ព្រៃស្អាក់ ។ ព្រៃស្អាក់នៅណាទៅ?

រឿន៖ ព្រៃស្អាក់នៅយើងហ្នឹង ។ ចេញពីកែបសីមាមក ។

ដានី៖ នៅយើង នៅក្រោយយើង នៅភូមិយើងហ្នឹង?

រឿន៖ ចាំ! ខ្ញុំរស់នៅព្រៃស្អាក់ ។

ដានី៖ ព្រៃស្អាក់ហ្នឹងរយៈពេលប៉ុនាន?

រឿន៖ រយៈ...ជា២ខែចុះ ។

ដានី៖ ជាមួយវរៈសេនាធំតា៧៩អីហ្នឹង?

រឿន៖ ចាំ! ជាមួយតា៧៩អីហ្នឹង ។

ដានី៖ ព្រៃស្អាកនៅក្រោយភូមិយើងហ្នឹង?

រឿន៖ ចាំ! ព្រៃស្អាក់ហ្នឹង ព្រៃធំគេហៅថាព្រៃកែបសីមាណា ព្រៃធំណា ព្រៃធំ ។

ដានី៖ ចុះកែបសីមានៅខាងនោះទេតើ មិនមែននៅខាងក្រោយភូមិយើងឯណាអី?

រឿន៖ កែបសីមានៅមណ្ឌលគីរីនោះ ។

ដានី៖ បាទ! ប៉ុន្តែមីងថាព្រៃស្អាក់ហ្នឹង ព្រៃស្អាក់នៅណាទៅ?

រឿន៖ ព្រៃស្អាក់នៅកែបសីមាហ្នឹង ។

ដានី៖ នៅខាងកែបសីមាទេ?

រឿនៈ ចា៎!ខាងកែបសីមាទេ ។ព្រៃស្អាក់វាមាន២ ព្រៃស្អាក់មួយព្រៃស្អាក់នៅជិតត្រពាំងប្រសាត ព្រៃស្អាក់មួយទៀតនៅមណ្ឌលគិរី ។ វាមាន២ ចា៎! ព្រៃ ។

ដានី: ត្រពាំងប្រសាតនៅណា?

រឿនៈ ត្រពាំងប្រសាតនៅខាងនោះអណ្ដូងវែង ។

ដានី: អ! នៅខាងអន្លង់វែងវិញ ។

រឿនៈ ចា៎!

ដានី: អញ្ចឹងមីងនៅព្រៃស្អាក់រយៈពេលប៉ុន្មានបានផ្លាស់ពីហ្នឹងទៅទៀត?

រឿនៈ នៅ២ថ្ងៃ ក៏ទៅទៀតអញ្ចឹងទៅអស់ក្លួចអស់អីក៏ទៅទៀតអញ្ចឹងទៅ ។

ដានី: ទៅណាទៀតទៅ?

រឿនៈ ចេះតែដើរមកៗឡើងភ្នំមកដល់ដំបូងមកដល់អីនេះមកដល់ដាបូយើងនេះ ។

ដានី: ឡើងភ្នំណាទៅ?

រឿនៈ ឡើងភ្នំដងរែក ។

ដានី: ឡើងភ្នំដងរែកចាក់មកដាបូ?

រឿនៈ អត់ទេ! ចាក់មកខាងដាបូបានយើងចេះតែទៅៗ...បានមកដល់ព្រៃស្អាក់ អើត្រពាំងប្រា-សាទ ទៅដល់នៅអត់ហ៊ានចូលត្រពាំងប្រសាតទេ យើងមកនៅព្រៃស្អាក់ហ្នឹងរាប់ជិតមួយ ឆ្នាំ ៤ ៥ ៦ខែនោះណា បានយើងមកនៅហ្នឹងខាងឆ្លងផ្លូវឆ្លងអីទៅយើងឡើងភ្នំ ។ ឡើងភ្នំនោះ ឡើងមិនរួច អីក៏មិនរួចក៏យួនវៃបែកខ្ញែកគ្នាទៅក៏នៅត្រឡប់មកនៅព្រៃស្អាក់ហ្នឹង វិញទៀត ។ ដល់ទៅពេលដល់ខែដល់ថ្ងៃគេគេមកពីលើគេឲ្យទៅទៀតក៏ឡើងទៅដល់លើភ្នំ ឆ្នាំ៨៦ ។ ចុះមកវិញឆ្នាំ៩១ ។

ដានី: ភ្នំណា?

រឿនៈ ភ្នំ ភ្នំដងរែក ។

ដានី: នៅក្នុងកន្លែងណាដែរដែលទៅនោះ?

រឿនៈ ថៃ ។

ដានី: ដីថៃ?

រឿនៈ ចា៎!

ដានី: នៅខេត្តអីកាលនោះនៅជាប់ហ្នឹងខេត្តអី?

រឿនៈ ជាប់ខេត្តអីមានតែអូរសបចងក ។ មិនដឹងខេត្តអី? សាន់តែ!

ដានី: ដីខ្មែរយើង?

រឿន: ចាំ! កន្ទួតសាន់តែហ្នឹង គង១ គង៧ គង់អីហ្នឹង...

ដានី: ឧត្ដរមានជ័យ ខាងអន្លង់វែងអាហ្នឹង?

រឿន: ចាំ! ខាងអន្លង់វែង ។

ដានី: នៅឆ្នាំណាដែលមីងចូលមកនៅអន្លង់វែង?

រឿន: ខ្ញុំមកចុះអន្លង់វែង ខ្ញុំចុះមកនៅអន្លង់វែងឆ្នាំ៩៩ហើយ ។ ៩៨ ៩៩ហើយ ៩៨ហើយបើមិន៩៧ ៩៨ ៩៩ប៉ុណ្ណឹងឯងទេ ។

ដានី: អ! មុនដំបូងកងទ័ពនៅលើភ្នំនៅឡើយទេមិននៅក្នុងអន្លង់វែងទេ ដល់ក្រោយមកបានវៃបានអន្លង់វែងឆ្នាំកោ?

រឿន: ៩៦ ៩៧ ។

ដានី: ចុះកាលការកូនតា០៥ ០៦ការនៅក្នុងព្រៃ?

រឿន: ការនៅអន្លង់វែងហ្នឹង ចុះមកដីខ្មែរហើយ ។ ចុះមកដីខ្មែរការរួចហើយបានគេធ្វើមហាបាតុកម្មតា០៥ តាសុន សឿន អញ្ចេះដូចថា ការអាវុធអញ្ចឹងបាបប៉ុន្មាន បានតែមួយព្រឹកការអាវុធថ្ងៃហ្នឹងមានសកម្មភាពព្រឹកហ្នឹងហ្នង ។ ការមិនទាន់រួចផងរត់ឯងពេញវាលពេញកាលគេដុតអាប៉ុស្ដិ៍វិទ្យុតាមុកអីហ្នឹងណា ។

ដានី: គេបាតុកម្មពីណាគេ?

រឿន: បាតុកម្មពួកកងទ័ពតាមុកហ្នឹងបាតុកម្ម ។

ដានី: កងទ័ពតាមុកបាតុកម្មកងទ័ពពីណា?

រឿន: ខាងបង០៦ ។

ដានី: ប្រឆាំងជាមួយបង០៦?

រឿន: ចាំ! ចាំមើលណា តាមុខ ហើយបង០៦ហ្នឹងដូចថាភូមិភាគ...កងតែមួយ...ប្រធានកងពលតែមួយ ប៉ុន្ដែថា តាមុកហ្នឹងប្រធានផ្សេង បង០៦ហ្នឹងប្រធានផ្សេងកងពលផ្សេងអញ្ចឹង ណាដូចថា ដាច់ដោយឡែកពីគ្នាណា ។ ខ្ញុំដូចជាមិនសូវចាំច្បាស់ដែរកន្លែងហ្នឹង ប៉ុនដូចថាការរៀនសូត្រអីយើងមករៀននៅតែកន្លែងតាមុកហ្នឹងណា ។ ចាំ! ដូចពួកខ្ញុំមករៀននៅកន្លែងតាមុកហ្នឹង កន្លែងសាលាតាមុកហ្នឹង ។ ដល់ហើយអញ្ចឹងទៅដល់រៀននៅកន្លែងតាមុកហ្នឹងដល់ទៅពេលគេមហាបាតុកម្ម មហាបាតុកម្មវៃតាសុន សែនចោលហ្នឹង ហ្នឹងហើយវៃតាសុន សេនចោលហ្នឹងអាហ្នឹងមុននឹងមួយថ្ងៃហ្នឹងវាមានកម្មវិធីការកូនបង០៦អញ្ចឹងណាដល់ទៅពេលហ្នឹងវាដុតអីដុតកន្លែងប៉ុស្ដិ៍វិទ្យុតាមុកហ្នឹងដុតចោលអស់រលីង ។ ដុតចោលឆ្នាំ

៩៧ ៩៨ ៩៨ហើយយើងរស់នៅនោះអត់បានមួយឆ្នាំផងយើងត្រូវរត់ៗ ដុតផ្ទះលំនៅ ថាហូដល់ហើយនេះ....ចុះមកបានប៉ុន្មានខែនេះហ្នឹងៗ

ដានី៖ មីងខ្ញុំចង់បកទៅបន្តិចសរទាក់ទងហ្នឹងនេះកាលមីងមណ្ឌលគិរីអីហ្នឹង មីងដែលឃើញពីខាងមជ្ឈិម ពួកមជ្ឈិមអីចុះទៅ ឬក៏មីងធ្លាប់ឡើងទៅមជ្ឈិមអីមកប្រជុំមកអីដែរអត់?

វឿន៖ អត់! អត់ដែលឃើញ មិនដឹងមជ្ឈិមម៉េចផងអត់ដែលស្គាល់,

ដានី៖ ពួកអ្នកធំៗ អ្នកដឹកនាំប្រទេសមីងដែលស្គាល់ដែរអត់កាលជំនាន់នោះ?

វឿន៖ អត់! ក្មួយ ខ្ញុំអត់សូវដើរទៅណាទេព្រោះខ្ញុំ ដូចថា ខ្ញុំនៅកន្លែងពេទ្យនៅកន្លែងពេទ្យហើយ មិនត្រឹមនៅតែមួយពេទ្យទេ ខ្ញុំនៅកន្លែងគេអូ ខ្ញុំនៅចាំប្រចាំគេអូហ្នងៗ ចា៎! ខ្ញុំសម្រាប់ ទាក់ទង ទាក់ទងគេអូ ពេទ្យផងទាក់ទងផង ឆ្លបផងខ្ញុំម្នាក់ឯងនោះវាច្រើនជំពូកៗ

ដានី៖ ចុះមីងដែលឮប៉ុល ពតទេកាលជំនាន់មីងនៅមណ្ឌលគិរីអី?

វឿន៖ អត់! ព ឮតាប៉ុល ពតឮតើ តែទាន់អត់ដែលឃើញ ទើបមកបច្ចុប្បន្នទេគេចាប់គាត់ហើយ បានទៅឃើញនៅកន្លែងមហាសន្និបាតៗ គេចាប់គាត់ៗ

ដានី៖ គេចាប់កាត់ទោសគាត់ហ្នឹង?

វឿន៖ ចា៎! គេកាត់ទោសៗ តាប៉ុល ពតស្លាប់ដោយវេទនា ស្លាប់ដោយសាគេផ្តាច់អុកស៊ីសែន ចុះបើនេះប៉ុស្តន៍វិទ្យុអស់ហើយ ទៅឯណាបើមិននេះៗ

ដានី៖ អញ្ចឹងកាលមីង កាលជំនាន់នោះ កាលកងពលនៅមណ្ឌលគិរីអីមិនដែលគេហៅឡើងមក ភ្នំពេញឡើងមកប្រជុំ ឬមកធ្វើអីនៅទីក្រុងភ្នំពេញទេអញ្ចឹង?

វឿន៖ អត់ទេខ្ញុំអត់មានភារកិច្ចអីត្រូវមកប្រជុំមកអីទេ ព្រោះពួកខ្ញុំខាងពេទ្យ ខាងជញ្ជូនអ្នកជម្ងឺ យកមកព្យាបាលៗ

ដានី៖ ចុះខាងសេនាធិការអីគេមានដែលចុះទៅខាងនោះដែរអត់?

វឿន៖ ខ្ញុំមិនសូវដឹងទេ ព្រោះកន្លែងកងពលនៅឆ្ងាយពីខ្ញុំកន្លែងមន្ទីរពេទ្យណាៗ កន្លែងកងពលនៅ ឆ្ងាយ នៅឆ្ងាយពីគ្នា ព្រោះអត់ដឹងអ្នកធំអ្នកតូចចេញចូលពីស្នាណាម៉ោងណា ពេលណាគឺ អត់ដឹង ខ្ញុំដឹងខ្ញុំថាដឹងរាប់រៀបទៅ បើថាខ្ញុំមិនដឹងខ្ញុំ..មិនដឹងៗ មានតែទាក់ទងគេអូដូចថា នរណាមកអញ្ចឹងគេអូឲ្យប្រាប់ ដូចថា សុំស្នើវរៈសេនាតូច វរៈសេនាធំទៅធ្វើការនិងយើង ស្នើទៅតាមកងអញ្ចឹងណាៗ ចា៎! គេទាក់ទងដូចថា បង០៦ ទាក់ទងមកខ្ញុំអញ្ចឹងអាទូរសព្ទ យើងមានដៃប្រវេងប្រវាងពីមុននោះ ទូរសព្ទក្រវីគ្រវាសអីពេអញ្ចឹង ប្រើអាហ្នឹងពីមុន ណាស់ ហើយនឹងយើងចុចអក្ខលីលេខអីអញ្ចឹងទៅៗ ខ្ញុំរៀន សិល្បៈក៏រៀន ពេទ្យក៏រៀន ចុចអក្ខលីលេខអាអក្ខលីលេខយើង..មានវូលីមគ្រប់កន្លែងនោះៗ អាហ្នឹងខ្ញុំរៀនដែរៗ

ដានី: ចុះមីងពេលដូចថា តេលេក្រាម ឬក៏គេអូអីទាក់ទងពីមជ្ឈឹម ពីភ្នំពេញមក កងពល ឬក៏បញ្ជូនមន្ទីកងពលទៅមជ្ឈឹមអីកន្លែងមីងហ្នឹងដែរឬក៏កន្លែងគេផ្សេង?

រឿន: កន្លែងផ្សេងគ្នា ។ ខ្ញុំរួមមន្ទីកងពល ។ ខ្ញុំតែមន្ទីកងពលទេដូចបង០៦មានការអីអញ្ចឹងដូចថាត្រូវការមិត្តនេះមិត្តនោះទៅមានការងារត្រូវទៅយកស្អីយកខោអាវ ៤ទៅយកសម្ភារៈវិលឬទៅយកថ្នាំពេទ្យថ្នាំអីយកមកចែកជូរមិត្តយើងនៅក្នុងអង្គភាព អាហ្នឹងត្រឹមខ្ញុំ ។ ចេញទៅណាឆ្ងាយអត់បានទេ ព្រោះអាស្អីនេះ អាគេកាន់ទូរសព្ទអាគេកាន់អាឡូៗប្រវែងនេះហ្នឹង អាហ្នឹង ។ អាហ្នឹងគេហៅតេលេហ្វនម៉េចនោះ ។

ដានី: ចុះខាងដែលគេបញ្ជូនរបាយការណ៍ដូចខាងតេលេក្រាមខាងអី ខាងណាទៅនៅកន្លែងណា ទៅ?

រឿន: ខាងក្មួយខ្ញុំ ខាងអាថាននោះទេ ខាងមិត្តសែម ខាងអាថាននោះទេ ។

ដានី: ខាងមិត្តសែម ថាន?

រឿន: ចា៎!

ដានី: មិត្តសេម ហើយថាន ហ្នឹងនៅណាឥឡូវហ្នឹង?

រឿន: អាថាននៅអន្លង់វែង ។

ដានី: ហ្នឹងគាត់កាន់ខាងស្អីគេអាហ្នឹងគេហៅស្អី?

រឿន: ខាងតេអូ ហ្នឹងខាងទូរលេខ ។

ដានី: ខាងទូរលេខ?

រឿន: ចា៎! គាត់ដូចថា គេចុចអីចេញជាភាសាសត្វអីអញ្ចឹងទៅណា ។ ឧទាហរណថា ដូចពាក្យដូចឆ្លើយនៅទូរលេខ ឆ្លើយដូចតេតៗ...តេត អញ្ចឹងមើលថាអក្សរន អក្សរព អក្សរយ អីអញ្ចឹងណា ។ ចា៎! អាហ្នឹងគេហៅថា ភាសាសត្វ ។ ដចទូរលេខអញ្ចឹង ភាសាសំស្រ្កឹត មិនដឹង ។

ដានី: អញ្ចឹងដល់ពេលមីងមកនៅអន្លង់វែងហ្នឹងរស់នៅពីឆ្នាំណាដល់ឆ្នាំណា?

រឿន: រស់នៅអន្លង់វែងពីឆ្នាំ៩៨ ។

ដានី: ពី៩៨?

រឿន: ចា៎!

ដានី: ៩៨ដល់ឥឡូវហ្នឹង?

រឿន: ចា៎! ៩៨ ដល់បច្ចុប្បន្ន ។

ដានី: បាទ! ដល់ពេលនៅអន្លង់វែងមីងធ្វើអីដែរ?

រឿន: ខ្ញុំអត់មានធ្វើអីទេ ដូចឃើញអញ្ចឹង ។

ដានី៖ ចុះគ្រួសារមីង?

រឿន៖ គ្រួសារខ្ញុំធ្វើទាហ៊ាន ។

ដានី៖ ធ្វើទាហ៊ាន?

រឿន៖ ចា៎!

ដានី៖ គាត់មានតួនាទីអីដែរ?

រឿន៖ គាត់...គាត់ធ្វើខាងអីទេ...ប៉ុនគេថា សក្ក័មួយ ។

ដានី៖ សក្ក័មួយ?

រឿន៖ ចា៎! អនុសេនិយទោអញ្ចឹង!

ដានី៖ សក្ក័មួយអនុសេនិយត្រីយ សក្កពីរអនុសេនិយទោ ។

រឿន៖ អញ្ចឹង! អនុសេនិយត្រីយហ្នឹងហើយអញ្ចឹងនោះ ។

ដានី៖ បាទ! ចុះមីងទៅនៅអន្លង់វែងនោះអត់មានទៅនៅធ្វើពេទ្យអីទៀតទេ?

រឿន៖ ខ្ញុំអត់ទេ! អត់មានធ្វើអីទៀតទេចប់ ។

ដានី៖ ចុះមីងចេះគ្រូចេះអីហ្នឹងចេះមកពីណាមក?

រឿន៖ ចេះដូចថា ព្រះអង្គមកសន្និតប្រាប់យើងអញ្ចឹងណា ខ្ញុំឈឺមួយឆ្នាំណា ។

ដានី៖ ឈឺមួយឆ្នាំ?

រឿន៖ ចា៎! ឈឺមួយឆ្នាំបានគេមកសន្និតរូប ។ ហើយខ្ញុំបានលុយធ្វើតែបុណ្យនោះកសាងតាមវត្ត តាមអារាមនោះ ។ បើកុំតែថា វវល់ដើរតែកសាងវត្តនោះបានផ្ទះថ្មសរសរឥដ្ឋប៉ុនណាណី ដល់នេះគ្មានទេ ដើរតែកសាង ។ ទិញស៊ីមង់ ទិញឈើ ទិញខ្សាច់ ទិញអីហ្នឹងមកកសាងវត្ត ទៅ កសាងតាមដើមពោធន៍ សិលាអីអញ្ចឹងទៅ ។

ដានី៖ ចុះមីងម៉េចបានមីងអត់ធ្វើពេទ្យទៀត? ក្រែងមីងថាចេះច្រើនធ្លាប់រៀននៅភ្នំពេញរៀន នៅឬស្សី កែវ រៀននៅមណ្ឌលគីរី ហើយមីងថាធ្លាប់រៀននៅណា២ឆ្នាំទៀត?

រឿន៖ ខ្ញុំរៀនពីនាក់សច្ចុំ....ខ្ញុំធ្វើដែរប៉ុន....តែយូរៗដូចថាមានពេទ្យក្របខណ្ឌខ្ញុំខ្ជិលយូរៗទៅវាថាយើង អញ្ចឹងៗដើរទៅចាក់ថ្នាំគេ វាអត់ត្រូវ ។

ដានី៖ មីងថារៀនជាមួយអ្នកសច្ចុំរៀននៅណា?

រឿន៖ ខ្ញុំរៀននៅមណ្ឌលគីរីដែរ ។

ដានី៖ រៀននៅ?

រឿន៖ នៅអូគូប ។

ដានី៖ អ្នកសច្ចុំ?

រឿនៈ ចា៎! ខ្ញុំកាន់អ្នកសច្ចំដែរហ្នឹង អ្នកបង្រៀនខ្ញុំៗ ថ្ងៃ៧កើតបង្រៀន ថ្ងៃ៧រោចបង្រៀន បង្រៀនឆ្លងទន្លេដូចថា ពេលប្រសូត្របុត្រមកឲ្យដៃ ឬក៏ឲ្យជើង ឬក៏ឲ្យកំបេះគូថ ឬក៏ឲ្យដៃម្ខាងអីអញ្ចឹង ឬក៏ឲ្យទទឹងខ្លួនអីអញ្ចឹងខ្ញុំធ្វើបានៗ

ដានីៈ អ្នកសច្ចំបង្រៀន?

រឿនៈ ចា៎! អ្នកសច្ចំបង្រៀនចាស់នោះៗ

ដានីៈ បង្រៀនម៉េចទៅ?

រឿនៈ បង្រៀនគេហៅថា បង្រៀអញ្ចឹងទៅណា ដូចថាមានម្នាក់ហ្នឹងស្រី ស្រីហ្នឹងដូចថាចំណាស់ក្មេងអាយុ៣០ជាងអញ្ចឹងដល់ពេលថ្ងៃសិលមានម្នាកហ្នឹងមកហើយ ពោះធំស្ពញមកហើយ គ្រប់ខែមកហើយ នាងហ្នឹងមកអញ្ចឹងទៅគេថាអូឈឺពោះៗអញ្ចឹងទៅ ដូចថាម្នាក់ហ្នឹងឈឺពោះកូនឲ្យដៃអញ្ចឹង ហ្នឹងមនុស្សហ្នឹងមកហើយ ចា៎! អ្នកសច្ចំហ្នឹងមក ដល់ពេលកើតមកនាងហ្នឹងកើតឲ្យដៃមុន ចា៎! ហុចដៃឲ្យមុនៗ ចា៎! ដល់ពេលនាងហ្នឹងឆ្លងទន្លេហុចដៃឲ្យអញ្ចឹងទៅសួរថា តើធ្វេម៉េច? ខ្ញុំថាធ្វើម៉េចបើខ្ញុំអត់ចេះ! ក៏គាត់ប្រាប់ឲ្យបង្វិល ចា៎! ឲ្យបង្វិល ទៅបង្វិលៗទៅបានក្បាលមកវិញអញ្ចឹងទៅ អាហ្នឹងនិយាយតាមអាដែងខ្ញុំធ្វើ តាមតែខ្ញុំធ្វើតែឲ្យគេចវេស រឿងបញ្ហាក្នុងការជាក់ស្ដែងរបស់ខ្ញុំ ខ្ញុំអត់ចេះនិយាយតាពីះតាពាស់ទាល់តែជាក់ស្ដែង ទាល់តែពិត ខ្ញុំចូលចិត្តនិយាយពិតៗ

ដានីៈ ចុះមីង! មីងដេកយល់សប្ដិឃើញរៀនអញ្ចឹង ឬក៏រៀនផ្ទាល់ រៀនជាក់ស្ដែង?

រឿនៈ អត់ទេ! រៀនយល់សប្ដិៗ

ដានីៈ យល់សប្ដិ?

រឿនៈ ចា៎! យល់សប្ដិឃើញៗ

ដានីៈ ចុះមីងមកដល់សព្វថ្ងៃហ្នឹង០៥ ០៦នៅរស់ដែរអត់?

រឿនៈ ស្លាប់បាត់អស់ហើយយ៉ាង?

ដានីៈ ស្លាប់ឆ្នាំណាទៅ?

រឿនៈ ស្លាប់មើល គាសុនស្លាប់នៅក្នុងពេលកំពុងតែសមាហរណ្ណកម្ម កំពុងមានការច្របូកច្របល់នៅពេលដែលគេឆេះប៉ុស្ដិ៍វិទ្យុតាមុខរួចហើយនោះៗ

ដានីៈ ស្លាប់ ស្លាប់នោះយ៉ាងម៉េចគាត់ឈឺស្លាប់ ឬក៏គេយ៉ាងម៉េច?

រឿនៈ គាត់មិនឈឺស្លាប់គេ គេដឹកឡានយកទៅសម្លាប់ចោលតែហ្នង តាមុកៗ

ដានីៈ ពីណាគេអ្នកដឹកឡានយកទៅ?

រឿនៈ អត់ស្គាល់ទេ ម្ចាស់ឡាន តែបទបញ្ជាពាំតាមុកហ្នឹងឯងៗ

ដានី៖ ពីតាមុក?

រឿន៖ អើ! ចុះខាងតាមុកផ្សេង គេ គេស្រាវជ្រាវគេធ្វើនយោបាយ អាហ្នឹងមិនដឹងដែរទេណា ប៉ុន្តែគេថាកងទ័ពតាមុកអញ្ចឹងចាប់ផ្ដើមពីបង៥៦ បង៧៩អីនោះណា បងខេមរា បងអីហ្នឹង ចាប់ទៅអស់ តាធួន តា០៥ តាណា តាណាខ្លះទេ ៦នាក់ស្លាប់នោះណា ចា៎! បើតាប៉ុល ពត គាត់ស្លាប់អត់មានកំលាំងធាតុនៅខ្យល់អុកស៊ីសែនទេ គ្រាន់អត់មានពីណាសម្លាប់ទេ ចា៎! អាហ្នឹងខ្ញុំដឹង ។

ដានី៖ ចុះសុន សេន? កាលសុន សេនមិនដឹងដែរអត់?

រឿន៖ តាសុន សេន ដែលស្លាប់ហ្នឹង ដែលស្លាប់មានកូនស្រី កូនអីហ្នឹង?

ដានី៖ បាទ! ស្លាប់ម៉ាគ្រួសាគាត់?

រឿន៖ ចា៎! មួយគ្រួសាគាត់នោះ ហើយមាន...ហ៎! មានពីរគ្រួសាកាលនោះដែលស្លាប់ណា! អា កូនស្រីកូនប្រុសហ្នឹង ខាងពួកបង០៥ ។

ដានី៖ ខាងបង០៥អ្នកសម្លាប់?

រឿន៖ ចា៎! ខាងតា០៥ បង០៦អត់ហ៊ានអើពើហ្នឹងគេទេ កាលគេមកសម្លាប់តាសុន សេននោះណា ថ្នាក់បង០៦ ថ្នាក់អន្លុយឃុំ ស្រណោះតាសុន សេនតែសម្លាប់មនុស្សប្រទ្បាំមិនមែន ទេប្រឡុំទេ ។

ដានី៖ តា០៥អ្នកសម្លាប់?

រឿន៖ ដៃជើងបង០៥ហ្នឹង ។ មានតា០៥ផង!

ដានី៖ បាទ! ដៃជើងគាត់ៗ បញ្ជាមកពីណាមក?

រឿន៖ បញ្ជា បទបញ្ជាមានតែតា០៥ហើយ ព្រោះគាត់ជាមេណា៎! ហ្នឹងតាមការយល់ដឹងរបស់ខ្ញុំដែលគេនិយាយទេណា ដែលឃើញពិតគឺខ្ញុំអត់ដឹងទេ ។

ដានី៖ ប៉ុនកាលនោះមីងនៅអន្លង់វែងដែរ?

រឿន៖ ខ្ញុំនៅនោះដែរ?

ដានី៖ សព្វថ្ងៃផ្ទះមីងសព្វថ្ងៃនៅណាដែរ?

រឿន៖ ខ្ញុំរស់នៅជាមួយកូនប្ដីខ្ញុំ ។ ខ្ញុំអត់មានផ្ទះទេក្មួយ! ចា៎! ខ្ញុំរស់នៅតែជាមួយកូនទេ ។

ដានី៖ នៅណាទៅ?

រឿន៖ នៅនេះ នៅភូមិពពែល ។

ដានី៖ ភូមិពពែល? ឃុំ?

រឿន៖ ឃុំបន្ទាយជ្រៃ ។

ដានីៈ ឃុំបន្ទាយជ្រៃ?

រឿនៈ ចាំ!

ដានីៈ ស្រុកអីគេ?

រឿនៈ ឈើទាលជ្រៃ ។

ដានីៈ បាទ?

រឿនៈ ឈើទាលជ្រៃ ។

ដានីៈ ឃុំឈើទាលជ្រៃ ។ ស្រុក?

រឿនៈ ចាំ! ស្រុកឯណា...អើ! ស្រុកត្រពាំងប្រសាត ។

ដានីៈ ស្រុកត្រពាំងប្រសាត ។

រឿនៈ ចាំ!

ដានីៈ ខេត្ត?

រឿនៈ ខេត្តឧត្តរមានជ័យ ។ យ៉ាងណាៗ កុំស្រាវជ្រាវរកឈ្មោះខ្ញុំទៅវើចោល ។

ដានីៈ ដូចខ្ញុំបានពន្យល់ប្រាប់មីងកាលពីម្សិលមិញហើយហ្នឹងថ្ងៃហ្នឹងហើយ ថាពួកខ្ញុំជាអ្នកប្រវត្តិ-សាស្ត្រមីង ហើយពួកខ្ញុំមកសួរនាំមីងហ្នឹងដើម្បីយើងយកទៅសរសេរជាអត្ថបទ ទុកជាឯកសាទុកឲ្យក្មេងៗជំនាន់ក្រោយតទៅទៀត ។ ដូចជាមីងធ្លាប់បានឆ្លងកាត់ ធ្លាប់ដឹងរឿងនិយាយប្រាប់ខ្ញុំមិញហ្នឹង ពេលដែលខ្ញុំត្រលប់ទៅ អូហ៊ឺស្ស វិញពួកខ្ញុំយកទៅសរសេយកទៅចងក្រង ជាសៀវភៅនេះ ដូចជាទស្សនាវដ្តីស្វែងរកការពិតនេះដូចជាមានអត្ថបទដែលខ្ញុំចុះទៅសម្ភាសន៍តាមស្រុកតាមភូមិអញ្ចឹងមីង ។ ពួកខ្ញុំយកទៅសរសេរហើយខ្លះទៅអត់បានសរសេរទេ យើងគ្រាន់ដាក់ជា យកទៅដកល់ទុកជាឯកសា ។ បាទ! សរសេរហ្នឹងទុកឲ្យក្មេងៗជំនាន់ក្រោយអ្នកសិក្សាស្រាវជ្រាវដែលគេចង់អានគេស្រាវជ្រាវពីរបបខ្មែរក្រហមហ្នឹងគេអាចអាន គេស្រាវជ្រាវតាមរយៈឯកសា តាមរយៈសៀវភៅហ្នឹង ។

រឿនៈ រូបអីហ្នឹង?

ដានីៈ បាទ! ហ្នឹងរូបថតដែលសល់មកពីសម័យ...ឆ្នាំ៧០ ៧៥ ៧៩អីហ្នឹងមីង ។ រូបនេះឆ្នាំ៧១ គាត់ទៅថតឆ្នាំ៧១ ថតចាស់ៗណាមីង ។

រឿនៈ នរណាហ្នឹង?

ដានីៈ ហ្នឹងអ្នកគេគាត់ឈ្មោះមេង ឆេង គាត់នៅខាងស្រុក ខាង....

រឿនៈ មើលទៅឃើញហើយងងឹតៗ

ដានី៖ គាត់នៅខាងនេះ គាត់នៅភ្នំពេញ ក្រុមគ្រួសាគាត់នៅភ្នំពេញណា ។ មីងមុនប៉ុល ពតស្លាប់ មានព្រឹត្តិការណ៍កើតឡើង?

រឿន៖ មុនប៉ុល ពតស្លាប់?

ដានី៖ បាទ!

រឿន៖ មាន មានគេថាដុត ដូចថាគេបង្កជាសង្គ្រាម ជាពីរគណៈបក្ស ទីមួយគណៈបក្សខាងតាមុក ទីពីរគណៈបក្សខាងបង០៦ និងបង០៥ហ្នឹងណា ដែលកងពលមាំអន្លង់វែងរួមខេត្តស្រុកតែមួយ តែមានពរគណៈបក្ស គណៈបក្សខាងតាមុក គណៈបក្សខាងបង០៦ ។ ខ្ញុំកាលគេមហាបាតុកម្មរបស់កងទ័ពបង០៦ហ្នឹង ហ្នឹងខ្ញុំនៅម្នាក់ឯងទេណា ។ ខ្ញុំអត់រត់ទេ ខ្ញុំមិនខ្ចីរត់ បើពួកមិត្តដែលធ្លាប់ស្គាល់គ្នាហ្នឹងយកខ្ញុំទៅសម្លាប់ចោលក៏ងាប់ទៅចុះ ។ កាលតស៊ូហ្នឹងខា-ហ៊ាន អត់ងាប់ងាប់គ្នាឯងក៏ងាប់ទៅ ខ្ញុំនៅហ្នឹងគេមកស្រ អញ្ចឹងទៅ មួយណាក៏សាល់ខ្ញុំៗមាននរណាយកខ្ញុំទៅវាយចោល ។

ដានី៖ គេទាស់គ្នារឿងអី?

រឿន៖ ចាំ?

ដានី៖ គេទាស់គ្នារឿងអី?

រឿន៖ ទាស់រឿងលេខឆ្នោត បោះឆ្នោត ។ ឧទាហរណថា តាមុកហ្នឹងមិនចង់ឲ្យបង០៥ហ្នឹងជាប់លេខអញ្ចឹងណាំ! ដល់បោះអញ្ចឹងទៅបង០៦ជាប់ឈ្មោះ ជាប់លេខ ដូចថា បង០៥ហ្នឹងជាប់សន្លឹកឆ្នោតច្រើនជាងបង០៦ អញ្ចឹងហើយតាមុកហ្នឹងចង់ឲ្យបង០៦ច្រើនជាងបង០៥អញ្ចឹង ។ ដល់អញ្ចឹងហើយកើតទំនាស់គ្នា ទំនាស់គ្នាពីរឿងបញ្ហាហ្នឹងបានកើតធ្វើបង្កជាសង្គ្រាមចិត្តសាស្ត្រនៅក្នុងកងពលនីមួយៗ អញ្ចឹងហើយបានមានមហា គេធ្វើមហាបាតុ-កម្មហ្នឹង គឺបាតុកម្មទៅវែក្នុងភ្នំអ! ភ្នំដងរែកហ្នឹងកន្លែងមាត់ពើយទៅធ្វើផ្សារថៃហ្នឹង រាល់ថ្ងៃកន្លែងហ្នឹងទៅធ្វើផ្សារថៃ ទៅគេដុត ហូរ សុតនោះ ដុតដល់ហើយដុតផ្ទះតាប៉ុល ពត ដុតផ្ទះតាដុន ជឿន ចាប់កូនតាសុន សេន យកមករំលោភតាមចិត្ត យកទៅដាក់ឲ្យដេកតាមផ្លូវឡានកិន អើយ! វេទនាណាស់ណា ខ្ញុំឃើញឡើងយំ ខ្ញុំទឹកភ្នែកហ្នឹងឃើញ ។

ដានី៖ យកមករំលោភ?

រឿន៖ ចាំ! រំលោភហ្នឹង! ចាប់រំលោភ អាហ្នឹងខាងកងតា០៥ ។

ដានី៖ តា០៥?

រឿន៖ ចាំ!

ដានី៖ ចុះបើតាមមីងដឹងតា០៥គាត់មានគំនុំអីជាមួយសុន សេនអីដែរអត់?

រឿន៖ អត់! អត់មានទេ ប៉ុន្តែដូចថា ដឹងជាមានឬក៏អត់ទេ...? ខ្ញុំអត់ដឹងដែរ ។ ដូចថាមានបទបញ្ហាពីតា០៥អីអញ្ចឹងមិនដឹងបានពួកទ័ព្វហ្នឹង វាធ្វើហ្នឹង វាធ្វើហួសហើយណា៎! ដូចថាវាហួសកំរិតនោះ ។ ទីងតាមុកនោះ ទៅធ្វើឯណោះណា ។ អាហ្នឹងហើយគេថាវ៉ៃ...ទីងគោមិនវ៉ៃអាគោ ទៅវ៉ៃរទេះ វាអត់ដឹងទេ តាមការយល់ដឹងរបស់ខ្ញុំ គឺខ្ញុំថាអញ្ចឹង ។ ទីងអីតា មុកម៉េចក៏ទៅធ្វើតាមុក ទៅធ្វើអាអ្នកផ្សេងនោះវាត្រឹមទេ? វាអត់ល្អ ។ អាហ្នឹងក្នុងការយល់ដឹងរបស់ខ្ញុំ ខ្ញុំមានប៉ុណ្ណឹង ។

ដានី៖ អាហេតុដែលបោះឈ្មោះបន្តទៅជារឿងមហាបាតុកម្មដុតបំផ្លាញអីហ្នឹងបោះឆ្នោតគេធ្វើអីបង?

រឿន៖ គេបោះឆ្នោតហ្នឹងចង់ឲ្យឡើង ដូចថាឡើងជាកងពល ឬក៏ឡើងជាគណៈប្រទេះ? ហ្នឹងគេបោះហ្នឹង គេចង់ឲ្យឡើងខ្ពស់ ប៉ុន្តែគេចង់តំឡើងបង០៦ ឲ្យខ្ពស់ជាងបង០៥ព្រោះតាមុកហ្នឹងតា០៥អត់សូវត្រូវគ្នាទេ តាមការយល់ដឹងរបស់ខ្ញុំតមាឮគេនិយាយតាមុកហ្នឹងតា០៥ហ្នឹងតែងមានប៉ះពាគ្នាយោបល់ ប្រដែងយោបល់គ្នា ប្រដែងជាពាក្យសំដីជាមួយគ្នាអាប្រដែងចង់ឈ្នះចង់ចាញ់មួយចង់ទាប មួយចង់ខ្ពស់អញ្ចឹងណា ។ ចា៎! ដល់ប្រដែងគ្នាទៅប្រដែងទៅវាអត់រួច ដល់ប្រដែងទៅអត់រួចទេក៏កើតជាបំបែកពីរគណៈបក្សអញ្ចឹងទៅ ។ ខ្ញុំដឹងដែរប៉ុណ្ណឹង ។

ដានី៖ ក្រែងតា០៥ ហៅយតា០៦ហ្នឹងក្រែងជន្ទងជាមួយគ្នា?

រឿន៖ ជន្ទងគ្នា ។

ដានី៖ គាត់រាប់អានគាត់ត្រូវគ្នា....?

រឿន៖ ត្រូវគ្នា ។ ហើយចាំមើលខាងត្រូវគ្នា បង៨០អាផ្សារកណ្តាល តាមុកក៏គាត់ត្រូវ តា០៦ក៏គាត់ត្រូវ ត្រូវសងខាងតែគ្រាន់អត់មានពីណាយកគាត់ទៅវ៉ៃចោលទេ ។ ប៉ុនតាមដំណឹងដឹងថាបង០៦ បង០៥ បងខេមរាបង៧៩ តាឆ្នួន តា០៦អីហ្នឹងគេយកទៅគេថា... អាហ្នឹងខ្ញុំឮតាមពាក្យពួកមិត្តទេណា ចា៎! តែពិតមិនពិតខ្ញុំមិនដឹងទេ អាហ្នឹងគេថាពាក្យខ្យល់ គេថារណ្តៅម៉ែខ្ញុំមួយគេកាយ កាយម៉ែខ្ញុំបី គេថា ពីអាស្អីម៉ែខ្ញុំហ្នឹងនោះ អាដៃម៉ែខ្ញុំនោះកាយអាហ្នឹងបីដៃទៅបានចាក់ពួកបង០៦ទៅ អត់ទាន់មានសម្លាប់អីទេ ដល់ទៅកាយអាដីហ្នឹងកប់ កបទៅនៅរើដដុះ។ ក៏ប្រពន្ធបង០៥យាយ យាយនួនឃើញបោះប្តីអញ្ចឹង..ដល់ឃើញគេដាក់ដួយ ដាក់អញ្ចឹងក៏ឃើញនៅរើដដុះនៅក្នុងដីហ្នឹងលោតទៅតាមប្តីទៅ ផាប់ទៅដែរទៅ ។

ដានី៖ ឈ្មោះយាយអី?

រឿន៖ ឈ្មោះយាយនួន ។

ដានី៖ យាយនួន ។

រឿន៖ យាយនួន!

ដានី៖ យាយនួន

រឿន៖ យាយនួន ។ចប់ប៉ុណ្ណឹងឯង រឿងខ្ញុំដឹងប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង ។

ដានី៖ ថាបង៨០ហ្នឹងឈ្មោះអី?

រឿន៖ បង៨០ហ្នឹងខ្ញុំភ្លេចហើយនេះ...ឈ្មោះ..អឿន សំអឿនអញ្ចេះដឹង មិនដឹងសំអឿន មិនដឹងរឿនទេ? អញ្ចេះឈ្មោះស្រដៀងបង០៥ដែរ ។

ដានី៖ ចុះបង០៥ហ្នឹងគាត់ឈ្មោះអី?

រឿន៖ ឈ្មោះតារឿន ។

ដានី៖ តារឿន?

រឿន៖ ចាស៎!

ដានី៖ គាត់ឈ្មោះពេញ ឈ្មោះអីគេ?

រឿន៖ ឈ្មោះអី?

ដានី៖ បង០៥ហ្នឹងឈ្មោះពេញឈ្មោះអីគេត្រកូលគាត់ឈ្មោះអី?

រឿន៖ ដឹង! អត់ស្គាល់ផង ខ្ញុំស្គាល់តែបង០៥ ។ ខ្ញុំទើបស្គាល់មកនៅ មកនៅអូធំអន្លង់វែងហ្នឹងហើយទេ ខ្ញុំទើបហ្នឹងស្គាល់ដែរ ។ ជំនាន់នោះខ្ញុំអត់ស្គាល់ ។ ទើបគេវៃគ្នានោះឮឈ្មោះតា០៥បណ្ដោយទៅ ។ ខ្ញុំមិនទាន់បានឃើញច្បាស់ផង ឃើញតែនៅក្នុងឡាន ។

ដានី៖ តំណែងគាត់អីគេពួកបង០៥ហ្នឹង?

រឿន៖ តំណែងគាត់ហ្នឹងកងពលធំ?

ដានី៖ ប្រធានកងពលធំ?

រឿន៖ ចាស៎! ប្រធានកងពល ។

ដានី៖ កងពលធំលេខប៉ុន្មាន?

រឿន៖ ដូចលេខមួយ?

ដានី៖ អ! នៅរតនគិរី?

រឿន៖ ចាស៎!

ដានី៖ អំចាំមើលប៉ុល ពតគេសម្លាប់ឬក៏?

វឿនៈ ប៉ុល ពតគេអត់សម្លាប់ទេ គាត់ផ្តាច់ខ្យល់អុកស៊ីសែនៗ ដល់ពេលគាត់សែងអញ្ចឹងទៅ យើងខ្យល់អុកស៊ីសែនយើងមានតែនៅក្នុងកន្លែងមន្ទីរទេណា ដល់ទៅពេលដែលគេឆេះអ! គេដុតប៉ុស្តិ៍វិទ្យុទៅឆេះផ្ទះ ឆេះអីអស់ហើយណាៗ ចា៎! ដល់ឆេះផ្ទះឆេះអីអស់ទៅគាត់ហ្នឹងក៏ដាច់ខ្យល់អុកស៊ីសែនទៅមិនដាប់ តាប៉ុល ពតនោះ អត់មានគាត់ដកដង្ហើមតាមតែខ្យល់កំលាំងខ្យល់អុកស៊ីសែនទេ ដល់ទៅដល់ពេលដុតហ្នឹងវាកក៏មហាសែនវេទនាទៀត ដុតហ្នឹងដុតទាំងកងឡាន អត់មានឈើអត់មានអីទេៗ

ដានីៈ ពីណាគេអ្នកដុត?

វឿនៈ ពួកក្រុមគ្រួសាគាត់ហ្នឹងៗ

ដានីៈ ក្រុមគ្រួសាគាត់?

វឿនៈ ចា៎!

ដានីៈ បងឮគេនិយាយឬកម៉េច? បានឃើញផ្ទាល់ទេ?

វឿនៈ អត់! អត់ដែលៗ ប៉ុនណាដល់ពេលគាត់ស្លាប់ទៅកូនចៅគាត់យកទៅដុតខ្លួនឯងណា មានដុតគាត់ទាំងរស់ទេ អត់ទេៗ

ដានីៈ ចុះម៉េចបានបង្ខំដុតម្លេះ?

វឿនៈ មិនបង្ខំម៉េចបើវាកំពុងអាគេអាគុបពេញវាល ពេញកាលៗ

ដានីៈ ចុះហេតុអីមិនទុកសាកសពហ្នឹងសិនទៅអញ្ចឹង?

វឿនៈ បាតុកម្ម!

ដានីៈ គេបាតុកម្មៗ

វឿនៈ ចា៎! កាលនោះគេមិនបាតុកម្ម បាតុកម្មប៉ុល ពតៗ

ដានីៈ ចុះកាលនោះអៀង សារី ខៀវសំផនអីអត់មានលេចឮឈ្មោះអីនៅក្នុងអន្លង់វែងទេ?

វឿនៈ អត់ទេ! អត់មានលេចឮទេៗ គ្រាន់តែថា មហា គេថាមហាបាតុកម្មភ្លាមក៏បាត់តាអៀង សារី បងខៀវ សំផនអីបាត់រហូត បាត់មុនយូរទៀតៗ

ដានីៈ នួន ជា?

វឿនៈ ចា៎! នួន ជាអីៗ ទៅសម្ភោធម្តងៗ តែងតែឃើញ ដល់ពេលមកដល់ហ្នឹងអត់ឃើញ ឮពាក្យឮអីក៏មិនឮ មិនដឹងទៅខាងណា ខាងណីទេដុតទៅៗ

ដានីៈ តាប៉ុល ពតគាត់ឈឺអីបានគាត់ស្លាប់រហូតដល់...ត្រូវដាក់អុកស៊ីសែនរហូតអញ្ចឹងៗ

វឿនៈ មិនដឹងយ៉ាងម៉េច ខ្ញុំអត់សួរដឹងដែរខ្ញុំនៅឆ្ងាយៗ

ដានីៈ អំមានឮគេនិយាយថា ប៉ុល ពតត្រូវគេសម្លាប់ត្រូវគេដាក់ថ្នាំពុល?

រឿនៈ គាប៉ុល ពត?

ដានីៈ បាទ!

រឿនៈ ដូចថាពុកវាស្រពេចស្រពិលដែរតាមពុដូចថា ពុពាក្យ ពាក្យសេក ពាក្យសត្វវាមិន ដូចថាមិនសូវជាច្បាស់ល្អណា ក្មួយតែយើងមិនសុំនិយាយទេអី ព្រោះយើងមិនច្បាស់ល្អផងនោះ ។

ដានីៈ អត់ទេ! អមពុកគេនិយាយថាម៉េច? មិនមែនពាក្យសំដីអីទេ តែអីពុកគេនិយាយថាម៉េច?

រឿនៈ ខ្ញុំពុកគេនិយាយថា នៃពួកពេទ្យហ្នឹងគេចាក់ថ្នាំ ។

ដានីៈ ពួកពេទ្យ?

រឿនៈ ចាំ!

ដានីៈ ពេទ្យរបស់ពីណា?

រឿនៈ អត់ដឹង! ពុកគេថាពេទ្យអញ្ចឹងណា ។

ដានីៈ ពេទ្យខាងតាមុក ពេទ្យខាងណា?

រឿនៈ ពេទ្យហ្នឹងបើពេទ្យ ពេទ្យអាចខាងតាមុកហើយ ព្រោះពេទ្យខាងតាមុក ពេទ្យធំ ពេទ្យរដ្ឋគេធំណា ។ ពេទ្យថា គេចាក់ថ្នាំសម្លាប់ ។

ដានីៈ ប៉ុល ពតកាលនោះនៅក្បែរប៉ុស្តិ៍វិទ្យុតាមុក?

រឿនៈ ចាំ! នៅពើយភ្នំ ។

ដានីៈ នៅក្បែរហ្នឹង?

រឿនៈ ចាំ! នៅក្បែរជិតហ្នឹង ។

ដានីៈ ដល់ពេលគេដុតប៉ុស្តិ៍វិទ្យុ ដុតអីទៅពីណាគេអ្នកសែងគាត់រត់?

រឿនៈ កូនចៅរបស់គាត់ហ្នឹង កូនគាត់ហ្នឹង ។

ដានីៈ កូនគាត់បង្កើតឬកូនម៉េច?

រឿនៈ កូនបង្កើតហើយដែលនៅជុំគាត់នោះ ។ នីរសា នាអីហ្នឹង ។

ដានីៈ នីរសាគាត់អីហ្នឹង?

រឿនៈ ចាំ!

ដានីៈ តាជួន ជឿនក្រោយមកគាត់ទៅនៅខាងណាវិញ? គាត់នៅខាងបង០៦ឬនៅខាងតាមុក?

រឿនៈ តាជួន ជឿនមិនដឹងទៅនៅខាងណាទេ ក៏បាត់ ទៅថៃចូលថៃអស់ហើយណា ។ ចាំ! កាលនោះចូលថៃអស់នោះ ។

ដានីៈ ឥឡូវគាត់នៅណា?

រឿនៈ អត់ដឹងដែរ ខ្ញុំអត់ដឹង!

ដានី៖ អត់នៅអន្លង់វែងទៀតទេ?

រឿន៖ អត់! មិនដែលឮផង?

ដានី៖ អាចស្លាប់ទេ?

រឿន៖ តាដួន ជឿន?

ដានី៖ បាទ!

រឿន៖ មិនស្លាប់ទេ!

ដានី៖ គាត់មានខ្លាំង?

រឿន៖ តាដួន ជឿន?

ដានី៖ បាទ!

រឿន៖ បច្ចេកទេសថ្នាំពីកភព គុណហើយតានោះ ។

ដានី៖ តែនិយាយទ្រព្យសម្បត្តិគាត់ ។

រឿន៖ ហេ! គាត់ធូរដែរគាត់ ធូមែនទែន មិនមែនធូរលេងៗ ។

ដានី៖ ចុះមេដឹកនាំ អតីតអ្នកធ្វើធំ អ្នកធ្វើការនៅអន្លង់វែងហ្នឹង ដែលអ្នកសម័យខ្មែរក្រហមអស់ហ្នឹងដែលអ៊ំដឹងថានៅរស់ពីណាខ្លះ?

រឿន៖ នៅរស់គ្នាធំៗដូចអស់ហើយនេះ....នៅតាយៀនមួយ..។

ដានី៖ តាយៀន ធ្លាប់ធ្វើអី?

រឿន៖ តាយៀន តាយៀនគាត់ធ្វើវរៈសេនាធំ ។

ដានី៖ វរៈសេនាធំនៅខាងណា?

រឿន៖ កងវរៈ ។

ដានី៖ នៅ នៅខាងណាា?

រឿន៖ ឥឡូវហ្នឹងគាត់នៅខាងក្រចេះ ។

ដានី៖ កាលសម័យខ្មែរក្រហមគាត់នៅខាងក្រចេះវរៈសេនាធំកាន់ខាងហ្នឹង?

រឿន៖ អត់ទេ! គាត់នៅខ្មែរក្រហមតាយៀនហ្នឹង ដឹងគាត់នៅខាងណាទេ? កាលនៅកោះញែកអីដូចអត់មានសោះ តែខ្ញុំទើបនឹងដឹងថា ខ្ញុំមកនៅគង៧ហ្នឹងដឹងថាឈ្មោះតាយៀនហ្នឹងហ្នង ។

ដានី៖ អ៊ំខ្ញុំចង់សួរអ៊ំបន្តិចទៀតដែលទាក់ទងហ្នឹងរឿងបកទៅក្រោយវិញកន្លែងចិន!

រឿន៖ ចា៎!

ដានី៖ ដល់ពេលចិន កាលជនជាតិចិនមកឆ្នាំហ្នឹង អ៊ំថាចិនមកខែ៦ ខែ៧ឆ្នាំ៧៦?

រឿន៖ ខែ៧ចា៎!

ដានី៖ កាលចិនមកហ្នឹងកាលជនាន់ហ្នុងកាលជនាន់តា០៦គាត់មកនៅ?

រឿន៖ អត់មាន នៅទេ!

ដានី៖ អត់ទាន់មក? នៅទេ?

រឿន៖ ចា៎!

ដានី៖ ហ្នឹងនៅតាឈិននៅឡើយទេ គេអត់ទាន់ចាប់តាឈិនទេ?

រឿន៖ ចា៎! អ! អញ្ចេះកាលតាចិនមកហ្នឹងឆ្នាំ៧៥ហើយក្អួយ ។

ដានី៖ ៧៥?

រឿន៖ ចា៎! ដាច់ភ្នំពេញថ្មីៗ ។

ដានី៖ ដាច់ភ្នំពេញ ។ កាលនោះអ៊ំទើបទៅព់ក្រចេះទៅដែរ?

រឿន៖ ទៅពិក្រចេះទៅ ទៅនៅសុខសាន្ត ។

ដានី៖ ទៅនៅសុខសាន្ត?

រឿន៖ ចា៎! ចិនមកហ្នឹងនៅខាងសុខសាន្ត? មិនមែនទៅនៅមណ្ឌលគីរីទេ ។

ដានី៖ អ! នៅសុខសាន្តនៅឡើយទៅកាលចិនមកហ្នឹង?

រឿន៖ នៅមណ្ឌលគីរី នៅសុខសាន្ត ។

ដានី៖ បាទ! កាលចិនមកហ្នឹង កាលហ្នឹងយកតែកងវរៈ យកតែស្បែកជើង ខោអាវ?

រឿន៖ ស្បែកជើង ខោអាវ មួក....

ដានី៖ ដែលអ៊ំថាកាលនោះចិនអត់ហ៊ានដួតឃើញទឹកស្បូវក្រហមៗអត់ហ៊ានដួតទេ ។

រឿន៖ ចា៎

ដានី៖ កាលនោះកាលគេទូលចិន គេទៅដួតទឹកនៅណាទៅ?

រឿន៖ ដួតទឹកអូប្បា ។

ដានី៖ ទៅមុជទឹកនៅអូប្បារវិញ?

រឿន៖ ចា៎!

ដានី៖ កាលហ្នឹងចិនមកតែម្តងហ្នឹងទេ?

រឿន៖ ចិនមកតែម្តងទេ ។

ដានី៖ កាលហ្នឹងឃើញតាឈិនទៅទូលចិនហ្នឹងដែរអត់?

រឿន៖ ខ្ញុំអត់សូវដឹងដែរព្រោះគេនៅព្រលានហ្នឹងគឺឆ្ងាយហា ណា៎! ចា៎! ព្រលានទៅឆ្ងាយខ្ញុំអត់បានដឹង ដឹងតែថា ចិនមកដល់កន្លែងរោងបាយ ទទួលធ្វើបាយឲ្យចិនហូបហ្នឹង ដឹងថាពួកខ្ញុំធ្វើបាយឲ្យហូបនៅកន្លែងមន្ទីរពិសោធន៍ហ្នឹងឯង ។

ដានី៖ កាលហ្នឹងចិនមកប៉ុន្មាននាក់ ៦នាក់?

រឿន៖ ៦!

ដានី៖ ស្រី៣ ប្រុស៣?

រឿន៖ ចាំ! ស្រីបី....អញ្ចេះដែរស្រី៣ ប្រុស៣ តែអ្នកបកហ្នឹងម្នាក់មួយទៀត ។

ដានី៖ ស្រី២នាក់អ្នកបក?

រឿន៖ ចាំ! ស្រី២...អត់ទេ ស្រីមួយទេ ។

ដានី៖ ស្រីមួយ?

រឿន៖ ស្រីមួយទៅ ខាងណោះប្រុសមួយ ស្រីមួយអ្នកបក ចាំ!

ដានី៖ ខែរយើង២នាក់ ស្រីម្នាក់ ប្រុសម្នាក់?

រឿន៖ ចាំ! ហើយដល់កន្លែងមន្ទីរពេទ្យយើងនេះ មានយាយសៀង គាត់ចិនសុទ្ធដែរ ។

ដានី៖ យាយសៀងហ្នឹងគាត់អ្នកបកប្រែដែរ?

រឿន៖ ចាំ! គាត់ប្រធានពេទ្យ ។

ដានី៖ គាត់ប្រធានពេទ្យនៅកងពលហ្នឹងដែរ?

រឿន៖ ចាំ!

ដានី៖ ចុះអ្នកបើកយន្តហោះឈ្មោះពារ?

រឿន៖ ឈ្មោះពារ ។

ដានី៖ ពារហ្នឹងមកហូបបាយកន្លែង...មីងទេ?

រឿន៖ ចាំ!

ដានី៖ កាលនោះចិនជិះយន្តអីអឹចឹង?

រឿន៖ អត់ដឹងផង!

ដានី៖ មកតែមួយយប់មួយថ្ងៃទេអញ្ចឹង?

រឿន៖ ចាំ!

ដានី៖ តែពួកចិនមកតែម្តងហ្នឹងទេ?

រឿន៖ តែម្តង ។

ដានី៖ កាលជំនាន់នោះដូច ដូចថាមានចិនទៅវិញហើយមានអ្នកផ្សេងៗ ដូចជាខាងមជ្ឈិមគេមកដែរ អត់?

រឿន៖ ណែ! រឿងនោះខ្ញុំអត់សូវដឹងដែរ បញ្ហាអ្នកធំអ្នកតូចគេទាក់ទងព្រោះកន្លែងវាឆ្ងាយ ឆ្ងាយពីកន្លែងកងពល ខ្ញុំនិយាយដាន់ដាន ដដែលៗ

ដានី: ដល់ពេលចិនទៅរយៈពេលប៉ុន្មានទៅបានគេផ្លាស់គាឈិន?

រឿន: ហ៎! បានប្រហែលជា៣ ៤ ៥ខែដែរ បានយូរដែរ បានគេយកគាឈិនទៅបាត់ ទៅភ្នំពេញ ទៅហ្នឹង។ ខ្ញុំការរួច ខ្ញុំអីរួចបានគេយកគាឈិនទៅនោះ។ ពេលខ្ញុំទៅដល់ខ្ញុំមិនការ ចា៎! ការហើយបាន៣ ៤ខែហ្នឹងខ្ញុំមានទម្ងន់ទៅ ក៏ខ្ញុំទៅភ្នំពេញ ទៅភ្នំពេញហើយបានខ្ញុំត្រលប់មកវិញ

ដានី: ដល់ចិន យន្តហោះដែលចិនជិះទៅហ្នឹងចុះទៅព្រលានយន្តហោះហ្នឹងមីងថា ក្រុមមីងអ្នកធ្វើព្រលានយន្តហោះហ្នឹង?

រឿន: ចា៎! ពួកខ្ញុំធ្វើប្រលានហ្នឹង ពួកកងនារីធ្វើព្រលានហ្នឹង។

ដានី: កាលពិមុននៅមណ្ឌលគិរីហ្នឹងអត់មានប្រលានយន្តហោះទេ?

រឿន: អត់ទេ! មានតែព្រៃ។

ដានី: មានតែព្រៃ?

រឿន: ចា៎! ព្រៃ អូ! ព្រៃឈើធំៗ....

ដានី: ព្រលានយន្តហោះហ្នឹងនៅណា នៅ?

រឿន: នៅ....

ដានី: ក្បាលភ្នំក្រោល..?

រឿន: ចា៎! នៅខាងលិចភ្នំក្រោល។

ដានី: គេហៅព្រលានអីអាហ្នឹង?

រឿន: គេហៅភូមិព្រលានហ្នង។

ដានី: គេហៅព្រលាន?

រឿន: ចា៎!

ដានី: បាទ! កាលយន្តហោះចុះហ្នឹងពួកមីងទៅទទួលដែរ?

រឿន: យន្តហោះចុះឯណា?

ដានី: កាលចិនមក...?

រឿន: អត់បានទេ..អត់បានទៅទេ! មិនបានទៅទេ។

ដានី: ពីណាគេ?

រឿន: ពួកកងទ័ព។

ដានី: កងទ័ពទៅទទួល?

រឿន: ចា៎! ពួកកងទ័ពណែ៎! ពួកកងទ័ពតាមវរៈតាមអី ចា៎! អនុសេនាតូច អនុសេនាធំគេនាំគ្នាទៅកងទ័ពទៅទទួលទៅ ខ្ញុំមិនបានទៅទេ ខ្ញុំនៅពេទ្យ។

ដានី៖ បាទ! បាទ! ចុះចិនគេចុះមកធ្វើការនៅកន្លែងហ្នឹងគេមានចុះទៅពិនិត្យតាមព្រាំដែលណាអីដែរអត់?

រឿន៖ អត់ទេ! អត់បានទៅទេ! ពិនិត្យក្នុងមន្ទីរពេទ្យ! ពិនិត្យក្នុងមន្ទីរពេទ្យ ដូចថាមានជម្ងឺអីមួយអីចឹង ទៅពេលមានជម្ងឺអីអញ្ចឹងសួរថាមានជម្ងឺអីជម្ងឺនោះអីអញ្ចេះ ជម្ងឺនេះត្រូវប្រើអីអញ្ចឹង ប៉ុន្តែគេជំនួយថ្នាំពេទ្យណា៎!

ដានី៖ កាលនោះមីងនៅខាងសិល្បៈផង នៅខាងពេទ្យផង ខាងស្លថ្នាំផង ខាងព្យាបាលផង?

រឿន៖ ចា៎! គេទាញទៅតាណា ក៏ចេះតែទៅទៅ។

ដានី៖ ប្រធានពេទ្យឈ្មោះសៀង?

រឿន៖ យាយសៀង។ ប្រធានធំបង្អស់ឈ្មោះយាយវីន បន្ទាប់មកបានយាយនី យាយនីមកបាន បានយាយសៀង។

ដានី៖ យាយវីនណាទៅ?

រឿន៖ យាយាវីនបង០៦ហ្នឹងហើយ។

ដានី៖ កាលចិនមក...?

រឿន៖ អ! កាលចិន....និយាយពីជំនាន់ចិន?

ដានី៖ បាទ!

រឿន៖ កាលនៅជំនាន់ចិនមានយាយសៀង តាដូ។

ដានី៖ យាយសៀង តាដូ?

រឿន៖ យាយសៀង តាដូ តាសើ។ ចា៎! មាន៣នាក់។

ដានី៖ បាទ!

រឿន៖ ប្រធានធំមានតាសើ។

ដានី៖ ចុះកាលតាស្លថ្នាំតានេះ...តាស្លថ្នាំឈ្មោះតាអី តា...?

រឿន៖ តាសើ។

ដានី៖ តាសើ?

រឿន៖ ចា៎! តា តាសឹម តាសុនទៀតនោះ។

ដានី៖ កាលនោះនៅកន្លែងសុខសាន្តនៅឡើយទេ?

រឿន៖ ចា៎! នៅសុខសាន្ត។

ដានី៖ កាលចនមកហ្នឹង?

រឿន៖ ចា៎!

ដានី៖ ដល់ក្រោយមកបានផ្លាស់មកកន្លែងកោះញែក?

រឿនៈ ចា៎! ក្រោយមកផ្លាស់នៅកោះញែកឆ្នាំ៧៦ខ្ញុំមកនៅកោះញែកហើយណា៎!

ដានីៈ តាឈិន នៅនៅឡើយទេ នៅកោះញែកហ្នឹង?

រឿនៈ នៅទេ! ពូឈិនទៅនៅកោះញែកបានយូរដែរណាគ្រាន់ខ្ញុំមិនសូវចេះគិត ប៉ុន្តែយូរ បានពួកខ្ញុំបានរៀបគ្រួសាហ្នឹងបានបង០៦ បង០៦ខ្ញុំរៀបគ្រួសាហ្នឹងបាន បានប៉ុន្មានខែហ្នឹងបានខ្ញុំមានទម្ងន់ ពោះធំបានខ្ញុំទៅភ្នំពេញ ។

ដានីៈ បាទ! អញ្ចឹងកាលតា០៦មកតាឈិនក៏នៅហ្នឹងដែរ?

រឿនៈ នៅជុំគ្នាទាំងអស់គ្នាទេ ។

ដានីៈ នៅជុំគ្នាទេ?

រឿនៈ ចា៎! នៅមានរយៈទាក់ទងជាមួយគ្នា ។ តែគេស្អប់ខ្មើមពីរឿងអីមួយខ្ញុំអត់សូវដឹងទេណា? ខ្ញុំគ្រាន់តែដឹងថានៅជុំគ្នាដដែលទេគាត់នៅមន្ទីខុសគ្នា បង០៦នៅមន្ទីថ្មី ពួកពូឈិននៅមន្ទីចាស់ ។

ដានីៈ កាលដំបូង កាលតា០៦មកដំបូងហ្នឹងគាត់មានតួនាទី កាលគាត់មកដល់មណ្ឌលគីរីដំបូង?

រឿនៈ បង០៦?

ដានីៈ បាទ!

រឿនៈ គាត់ដឹងថានាទីគាត់ត្រួតក្តាប់កងពលទីពីរហ្នឹងហើយគាត់អត់មានទទួលតំណែងអីទេ ប៉ុន...ដូចថានៅលេង ដល់ជំនាន់ដាច់អាណត្តិកាលបោះឆ្នោតហ្នឹងណា៎!

ដានីៈ កាលហ្នឹង...ប៉ុន្តែពេលដែល០៦មកដំបូង តាឈិនគាត់នៅគ្រប់គ្រប់កងពលដដែល?

រឿនៈ ចា៎! នៅកងពលដដែល?

ដានីៈ បាទ!

រឿនៈ ទាល់តែគេយកពូឈិនទៅវិញទៅបានបង០៦ឡើងក្តាប់អំណាច កងពលហ្នឹងបណ្តោយ ។

ដានីៈ ឆ្នាំណាមីង មីងចាំឆ្នាំច្បាស់លាស់ដែរអត់?

រឿនៈ ឆ្នាំពូឈិនទៅហ្នឹង?

ដានីៈ បាទ!

រឿនៈ អាច៧៧អីហើយជំនាន់ខ្ញុំទៅនោះ....ខ្ញុំថា ៧៧ទៅចុះ ។

ដានីៈ ដូចថាពេលដែលគាត់ទៅហ្នឹងដូចថា មីងរៀបការអីរួចអស់ហើយ?

រឿនៈ កាលបង០៦ទៅ៧៦ហើយ កាលនៅកំពុងប្រូកប្របល់ណា៎! ៧៦ទេ មិនមែន៧៧ទេ ។

ដានីៈ កាលហ្នឹងមីងរៀនការហើយ ហើយអី?

រឿនៈ នៅទេ! បង០៦ទៅបានខ្ញុំរៀបការ ។ ខ្ញុំការខែ៦ ខែ៧ ៧៦ ។

ដានីៈ ខែ៧ ៧៦?

វឿនៈ ចាំ! ខ្ញុំការខែ៧ ៧៦ ។

ដានីៈ បង០៦អ្នករៀបការឲ្យមីង?

វឿនៈ ចាំ! បង០៦ មានតា០៦ មានតាឆេង តាឈួន មានតាខាន់ គាត់រៀបចំនៅហ្នឹង ។

ដានីៈ កាលហ្នឹងកាលរៀបការមីង ដូចថាកាលគេ គេហ្នឹង មីងស្គាល់គ្រូសាមីងមុនមកឬក៏យ៉ាងមេច ពេលការហ្នឹង?

វឿនៈ ការហ្នឹងខ្ញុំអត់បានស្គាល់ទេ ។

ដានីៈ អត់បានស្គាល់ទេ?

វឿនៈ ចាំ! មិនដែលស្គាល់ផង គេហៅទៅរៀបចំបណ្ដោយ ។

ដានីៈ គ្រូសាមីងគាត់ឈ្មោះអី?

វឿនៈ ឈ្មោះនី ។

ដានីៈ ឈ្មោះនី?

វឿនៈ ចាំ!

ដានីៈ កាលនោះគាត់ធ្វើអីទៅ?

វឿនៈ គាត់អត់មានធ្វើផង គាត់ធ្វើពេទ្យនៅហ្នឹង ។

ដានីៈ គាត់ធ្វើពេទ្យដែរ?

វឿនៈ ចាំ! គាត់ធ្វើពេទ្យជាមួយគ្នាហ្នឹង ។

ដានីៈ គាត់ធ្វើពេទ្យ គាត់មានតួនាទីអីដែរកាលនោះ?

វឿនៈ គាត់ទទួលខុសត្រូវខាង ដូចថាកង កងធំខាងផ្នែកអ្នកពិការ ។

ដានីៈ កងធំខាងផ្នែកអ្នកពិការ?

វឿនៈ ចាំ!

ដានីៈ កាលនោះគាត់ គ្រូសាមីងឈ្មោះនីងហ្នឹងគាត់ស្នើមីង ឬក៏គេអ្នកបងៗដដូចថា ០៦ តាខាន់អី កាលមីងរៀបរាប់ហ្នឹងគាត់អ្នកផ្សំផ្គុំឲ្យ?

វឿនៈ បង០៦ ។

ដានីៈ គាត់អ្នកផ្សំផ្គុំ?

វឿនៈ ចាំ!

ដានីៈ ផ្សំផ្គុំកាលនោះមីងអត់ប្រកែកទេ?

វឿនៈ ខ្ញុំអត់ហ៊ានប្រកែកផង ។

ដានីៈ អត់ប្រកែកទេ?

រឿនៈ ចាំ!

ដានីៈ ហេតុអ៊ិបានមីងអត់ហ៊ានប្រកែក?

រឿនៈ ខ្លាច!

ដានីៈ ខ្លាចមេច ខ្លាចយ៉ាងមេច?

រឿនៈ គេយកទៅដាក់នៅកន្លែងសន្តិសុខ ។

ដានីៈ ខ្លាចគេយកដាក់កន្លែងសន្តិសុខ ។

រឿនៈ ចាំ!

ដានីៈ សន្តិសុខណាមីង?

រឿនៈ សន្តិសុខកន្លែងតាឆិលនោះ ។

ដានីៈ កន្លែងតាឆិល?

រឿនៈ ចាំ! ហ្នឹងយកទៅដាក់ស្រីៗរឹងចចេះ....

ដានីៈ ចុះមីងថាពីមុហ្នឹងមានគេសម្លាប់មេច សម្លប់អ្នកដែលប្រកែក...អីអត់..?

រឿនៈ មានតើ អ្នកដូចថា រៀបចំ ដូចថា យោងគេហៅថាដូចថា បក្សរៀបចំឲ្យហើយមិនពេញចិត្ត បក្សទៀតដូចថា រស់នៅក្នុងសង្គមគ្រួសារម៉ែឪគឺមានម៉ែ ដល់ពេលរស់នៅក្នុងជួរគឺមានតែបក្ស ហ្នឹងហើយជាម៉ែជាឪរបស់យើង បើអញ្ចឹងហើយយើងមិនតាមបក្សគេត្រូវយកវិន័យហ្នឹងយក មកអនុវត្តចាំ! យកមកអនុវត្តហ្នឹងវដ្ឋហើយ ត្រូវតែទទួលផ្តន្ទាទោស ។ ធ្វើមេទីងហើយយក ទៅហើយ ។

ដានីៈ ធ្វើមេទីងហើយបានយកទៅ?

រឿនៈ ចាំ!ធ្វើមេទីងហើយគេយកទៅ ជួនកាលគេយកទៅស្លាត់ៗក៏មាន ។

ដានីៈ កាលឈ្មោះអីស្រី ដែលគេយកទៅសម្លាប់ហ្នឹង ដោយសាគាត់ប្រកែកអត់ព្រមយកអាពាហ៍ពិ-ពាហ៍គ្រួសា?

រឿនៈ ចាំ! រៀបហើយ តែអត់ចូលដំណេក ។

ដានីៈ រៀបហើយអត់ចូលដំណេក?

រឿនៈ ចាំ! រៀបហើយអត់ចូលដំណាកហ្នឹងគ្នា?

ដានីៈ ឈ្មោះអីទៅមីង?

រឿនៈ អត់ស្គាល់ទេ!

ដានីៈ អត់ស្គាល់ទេ! គាត់នៅកងពលជាមួយមីងដែរ?

រឿនៈ នៅក្រុម នៅកងពលជាមួយគ្នាហ្នឹងពួកនារី ក៦ហ្នឹងណា នារីក៦ ក៦ហ្នឹងគេហៅវរៈ៦ ។

ដានី៖ វរៈ៦?

រឿន៖ ចា៎! វរៈ៦ ។

ដានី៖ កាលនោះពេលដែលគេយកទៅហើយហ្នឹង ពេលគេប្រជុំដូចថា ថ្ងៃ១០ ថ្ងៃ២០ហ្នឹងគេលើករឿងហ្នឹងមកនិយាយដែរ?

រឿន៖ ចា៎!

ដានី៖ គេនិយាយថាមេច?

រឿន៖ គេនិយាយថាអញ្ចេះ គេថាបើសិនណាជាមិត្តទាំងអស់គ្នា រស់នៅក្នុងជួរបដិវត្តន៍ រស់នៅក្នុងជួរសង្គមបដិវត្តន៍ បើបងប្អូនមិត្តយើងទាំងអស់គ្នាទាំងយុទ្ធជន ទាំងយុទ្ធនារី ដើរតាមបក្សគឺស្រេចតែហ្នឹងបក្ស នរណាជំនះនឹងបក្សគឺមិនបាន ដូចថាបើ....មេចទេ...? គេមេចទេ គេថា បើមិនដួកចូកមិនជួយថែវ កុំយកដើងរាទឹក ។ អាហ្នឹងពាក្យហ្នឹងយើងត្រូវតែយល់ន័យហើយពីរឿងខ្លឹមសាពីរឿងបញ្ហាហ្នឹង យើងត្រូវតែយល់ហើយ យើងចាស់ៗហើយយល់ហើយពីបញ្ហាហ្នឹងម្នាក់ៗ ។ អញ្ចឹងបានថា ដូចឧទាហរណ៍ថា គេទៅអស់ហើយ យើងម្នាក់ឯងយើងតាមតែជំនះចិត្តយើងដែលមិនចង់បាន ឬក៏គ្មានមនោសញ្ចេតនាទៅលើបុរសហ្នឹងអញ្ចឹងណា...អញ្ចឹងគេមិនពេញចិត្តអញ្ចឹងទៅជួនកាលខ្វះបាញ់ខ្លួនឯងងាប់ក៏មានដែរ ។

ដានី៖ អ! ឆ្នាំណាទៅដែលគេចាប់នារីហ្នឹង? ទៅនារីដែលថាមិនព្រមចូលដំណេកហ្នឹង?

រឿន៖ ៧៧ ។

ដានី៖ ៧៧ ។ អញ្ចឹងកាលគេប្រជុំកាលជំនាន់ហ្នឹង នៅតាឈិននៅឡើយ ឬតា០៦?

រឿន៖ អេ! តា០៦ផុតហើយ ។

ដានី៖ តាឈិនផុតហើយ?

រឿន៖ ចា៎!

ដានី៖ ចូលដល់០៦ហើយ?

រឿន៖ អំណាចនៅលើតា០៦ហើយ ព្រោះពួឈិនអត់សូវមានទេ ។

ដានី៖ ចុះមីងថា មីងនិយាយថាកាលពីនេះនោះ កាលតាឈិនមីងអីទៅជិះយន្តហោះកាលមកភ្នំពេញហ្នឹងគឺមកជាមួយគ្នា?

រឿន៖ ជិះទៅ ។ ជិះទៅ ។

ដានី៖ ជិះទៅណា?

រឿន៖ ជិះទៅភ្នំពេញ ។

ដានី៖ ជិះទៅភ្នំពេញ ។ កាលនោះកាលក្នុងយន្តហោះដែលមីងជិះមានពីណាខ្លះ?

រឿនៈ   គ្នាច្រើន!

ដានីៈ   គ្នាច្រើន?

រឿនៈ   ចាំ! គ្នាច្រើនដែរ ។ ជិះមកឈប់នៅក្រចេះ ។

ដានីៈ   ជិះមកឈប់នៅក្រចេះ?

រឿនៈ   ចាំ! ដាក់សម្ភារៈដូចថា សំឡូងមី ជំឡូងជ្វាត្រសក់ទំត្រសក់ខ្ទឹអី ឪឡឹកអីវាច្រើនពេកហួសគោន ទៅវាកាយចោលទៅណា ។ ត្រលប់មកឈប់នៅក្រចេះ ជាប់ប្រហែលជាមួយម៉ោងបានទៅទៀត ។ មកភ្នំពេញ មកដល់ភ្នំពេញក៏បែកគ្នាទៅណា ។

ដានីៈ   ពេលនៅក្នុងហ្នឹង ពេលក្នុងយន្តហោះហ្នឹងមានគាឈិន មានមីង មានពីណាខ្លះទៀតទៅ?

រឿនៈ   ពួកពេទ្យគ្នាខ្ញុំ ។

ដានីៈ   ពួកពេទ្យ?

រឿនៈ   អ្នកជម្ងឺ ។

ដានីៈ   ហើយនិងអ្នកជម្ងឺ

រឿនៈ   ចាំ! អ្នកជម្ងឺ៤នាក់ ។

ដានីៈ   អ្នកជម្ងឺ៤នាក់ ។ អ្នកជម្ងឺឈឺអីខ្លះទៅ?

រឿនៈ   ឈឺគ្រុនចាញ់មួយទៅ មួយទៀតទៅរបួសទៅ មួយទៀតអាប់សែត្រគៀកអីទៅ ។

ដានីៈ   អ្នកជម្ងឺហ្នឹងគេបញ្ជូនទៅព្យាបាលនៅណាទៅ?

រឿនៈ   នៅពេទ្យ៣៩៨ ។

ដានីៈ   ពេទ្យ៣៩៨ ។ ចុះមិងថា ពេលមីងមកដល់ ដល់ពេលយន្តហោះមកឈប់នៅក្រចេះដល់ពេលយន្តហោះមានបញ្ហា ឈប់នៅក្រចេះហ្នឹងមីងថាបានហូបបាយនៅជិតជាមួយគាឈិនដែរ?

រឿនៈ   ចាំ! ហូបបាយជិតគ្នា គាត់គុផ្សេង គាត់គុផ្សេង ។ ប្រុសៗផ្សេង ស្រីៗផ្សេងអញ្ចឹងទៅ ។

ដានីៈ   ទៅបាននិយាយជាមួយគាឈិនអីដែរអត់?

រឿនៈ   គាត់គ្រាន់តែសួរថា អារឿនឯងទៅណា?

ដានីៈ   ខ្ញុំថា ខ្ញុំយកពួកអ្នកជម្ងឺទៅភ្នំពេញ ។ ចុះបងឯងទៅណា?

រឿនៈ   មិនដឹងយ៉ាងណាទេ គេហៅមករៀនៅភ្នំពេញ ប្រាប់យើងប៉ុណ្ណឹង ។

ដានីៈ   កាលនោះមីងថា គេហៅ...គាត់ថាអត់ដឹងយ៉ាងណាទេ?

រឿនៈ   ចាំ!

ដានីៈ   យន្តហោះដែលមីងជិះទៅមកក្រចេះហ្នឹង យន្តដែលមីងថាមានបញ្ហាដូចថា ដាក់ច្រើនពេកយន្តហោះហ្នឹង យន្តហោះមាក់ស្អីគេទៅ?

រឿនៈ សេ៤៨ ។

ដានីៈ សេ៤៨ ។

រឿនៈ សេ៤៨ ៣៨ទេអី? តែមានមានអត់៤៨?

ដានីៈ ខ្ញុំអត់ដឹងដែរ?

រឿនៈ សេ៣៨ ។

ដានីៈ ដល់ពេលមកឈប់នៅក្រចេះរយៈពេលប៉ុន្មាន?

រឿនៈ ប្រហែលជាមួយម៉ោងហើយ ។

ដានីៈ ដល់ឈប់នៅក្រចេះ ឈប់នៅកន្លែងណា?

រឿនៈ នៅកន្លែងព្រលានយន្តហោះ?

ដានីៈ នៅកន្លែងយន្តហោះណា? ចុះហូបបាយ ហូបបាយនៅកន្លែងព្រលានហ្នឹងដែរ?

រឿនៈ ចា៎! កន្លែងព្រលនហ្នឹងដែរ ។ កន្លែងគេអូរវេយ ។

ដានីៈ ដល់ពេលយន្តហោះជិះបន្តមកភ្នំពេញទៀតមានដែលជួបតាឈិនហ្នឹងទៀតដែរអត់?

រឿនៈ អត់!

ដានីៈ អត់ដែលជួបគាត់ទៀតទេ?

រឿនៈ អត់ អតដែលជួបរហូត ។

ដានីៈ កាលតាឈិនគាត់ជិះហ្នឹង មានគ្នាប៉ុន្មាននាទក់ទៅ?

រឿនៈ ជិះតាមកៅអីហ្នឹងច្រើន គេហៅថាយន្តហោះទទួលភ្ញៀវហ្នឹងវាធំណា! ប៉ុន្តែគេមានវិឌីអូ មានអីនៅក្នុងហ្នឹងណា! តែគេអត់ចាក់វិឌេអូគ្រាន់តែថាគេគ្រាន់តែបើកជាសំលេងដូចវិទ្យុអីអញ្ចឹង គេគ្រាន់តែបើកគេម៉េចទេខ្ញុំអត់ឃើញរូបឃើញរាងអីផង ព្ញតែកោក១ពេញហ្នឹង ។ ហើយអ្នកទទួលខុសត្រូវនៅខាងហ្នឹងគេមើលខគុនិយមហ្នឹងឈ្មោះសុខខ្លែន ។

ដានីៈ ឈ្មោះខ្លែន! មឹងថានៅក្នុងយន្តហោះដែលជិះមកហ្នឹងមានខាង អ! ខាងតា១០៥ទៅជាមួយដែរខាងតំបន់១០៥?

រឿនៈ មាន!

ដានីៈ ហ្នឹងគេហៅទៅជាមួយតាឈិនដែរ?

រឿនៈ ហ៎! ហ្នឹងគាត់ដឹងមានការអ់ទេ ដូចថាមិនបានយល់ដឹងផងកាលហ្នឹង គ្រាន់តែបានឃើញដែរ ។

ដានីៈ តា១០៥ឈ្មោះអីទៅមឹងស្គាល់ដែរអត់?

រឿនៈ ...ឈ្មោះតាអីទេចុងមាត់ចុងកនោះ....

ដានីៈ តាអីគេ....? តាឡាំង?

រឿនៈ តាឡាំ! ចា៎! មានតាឡាំងហ្នឹងមួយ....ទៅជាមួយ

ដានីៈ រួចចុះមានអ្នកមកពីភ្នំពេញមកហៅគាត់ទៅ ឬក៏មេច? គាត់ទៅខ្លួនឯងទេ?

រឿនៈ មានដូចថា មានបទបញ្ជាក្រោមទៅលើ មិនដឹងពីលើមកក្រោមអីក៏មិនដឹងទេបានគាត់ទៅនោះថាទៅរៀនទៅសូត្រនោះ...ៗ ហើយខ្លួនគាត់នោះក៏អត់ដឹងដែរ អត់ដឹងដែរ...និយាយគ្នាបានមួយមាត់អញ្ចឹងទៅក៏ទៅឡើងយន្តហោះ....ស៊ីបានមិនចង់ទាន់...ៗ អង្គុយរាយតាមកន្លែងរៀងខ្លួន ៗ

ដាន់ៈ កាលនោះមីងកាលពីមីងទៅភ្នំពេញនោះ មីងទៅរៀន មីងទៅភ្នំពេញនោះ?

រឿនៈ ទៅកាលខ្ញុំទៅនោះយកអ្នកជម្ងឺទៅ...?

ដានីៈ យកអ្នកជម្ងឺទៅ?

រឿនៈ ចា៎! ត្រូវទៅរៀនពេទ្យផង ៗ

ដានីៈ ទៅរៀនផង?

រឿនៈ ចា៎! ទៅរៀនពេទ្យផង...ៗ

ដានីៈ កាលនោះមីងមានផ្ទៃពោះផង?

រឿនៈ ចា៎! មានផ្ទៃពោះមួយខែ....

ដានីៈ មានមួយខែ ៗ

រឿនៈ អ! កាលយកពូឈិនទៅនោះ?

ដានីៈ បាទ!

រឿនៈ កាលយកពូឈិនទៅខ្ញុំអត់ទាន់មានទម្ងន់អត់ទាន់មានអីទេ..កាលខ្ញុំមកវិញទៅមួយលើកទៀត ៗ

ដានីៈ អ! អញ្ចឹង! កាលមីងទៅនោះយកអ្នកជម្ងឺទៅ?

រឿនៈ ចា៎! យកអ្នកជម្ងឺទៅទេ...

ដានីៈ ទៅហើយមកវិញ?

រឿនៈ ទៅហើយមកវិញ៣ ៤ ៥ដើងនោះខ្ញុំ! មានទៅតែមួយដើងរួចឯណា! អត់ទេ! ខ្ញុំដឹកជញ្ជូនអ្នកជម្ងឺទៅៗ....

ដានីៈ ចុះតាឈិនហ្នឹងដល់ពេលគេយកទៅពេលគេជិះយន្តហោះទៅភ្នំពេញទៅមានដែលជួបគាត់ទៀតដែរអត់?

រឿនៈ អត់!

ដានីៈ ដែលឃើញគាត់ត្រលប់មកមណ្ឌលគិរីវិញដែរអត់?

រឿនៈ អត់! អត់ឃើញ អត់ដែលឮ អត់ដែលដឹង បាត់ស្រមោល ៗ

ដានី៖ កាល កាលមីងទៅភ្នំពេញហ្នឹងដូចថាការបញ្ជូនអ្នកជម្ងឺទៅហ្នឹងទៅពេទ្យព-៩៨?

រឿន៖ ចា៎! ព-៩៨ ។

ដានី៖ កាលហ្នឹងមីងចូលទៅពេទ្យព-៩៨ដែរ?

រឿន៖ ទៅ ទៅជាមួយគ្នា ។

ដានី៖ អ្នកជម្ងឺទាំងប៉ុន្មាននាក់ហ្នឹងដែរ?

រឿន៖ ចា៎! ហើយពួកខ្ញុំទៅកន្លែងយាយរឿនទៅ ។

ដានី៖ ទៅកន្លែងយាយរឿន...?

រឿន៖ ចា៎! ទៅកន្លែងយាយរឿនកន្លែងរៀនទ្រឹស្តីពេទ្យ ។

ដានី៖ កាលនោះមីងយកអ្នកជម្ងឺទៅត្រលប់មកវិញ ឬក៏ទៅយកអ្នកជម្ងឺទៅហើយរៀននៅនោះ?

រឿន៖ រៀននៅនោះសិន រៀនប្រហែលបានមួយខែគេសម្រាកអ្នកជម្ងឺច្រើនពេកកាលនោះគេថា អ្នកជម្ងឺច្រើនហើយម្យ៉ាងទៀតគេមានវ៉ៃនៅព្រំដែនឯណាទេ គេយកអ្នកជម្ងឺមកច្រើនពេកគេឲ្យពួកខ្ញុំនៅព្យាបាលនៅហ្នឹងសិនណា៎! រៀនគ្មានបានចប់ចុងចប់ដើមទេកាលនោះណា តិចៗទទួលអ្នកជម្ងឺទៅ ព្រោះពួកខ្ញុំនេះទៅទទួលអ្នកជម្ងឺជំនួសពួកពេទ្យព-៩៨ហ្នឹង... ។

ដានី៖ ចុះមីងស្នាក់នៅព-៩៨រយៈពេលប៉ុន្មានបាន...រយៈពេលប៉ុន្មានបានត្រលប់មកវិញ?

រឿន៖ ប្រហែលជា៣ខែហើយណា....

ដានី៖ ជាប់៣ខែ?

រឿន៖ ចា៎!

ដាន់៖ រៀនជាមួយយាយរឿនហ្នឹង?

រឿន៖ ចា៎! រៀនបុគ្គលិកយាយរឿន យាយសៀងយើងហ្នឹងណា!

ដានី៖ ចុះប្រធានពេទ្យគ្រប់គ្រងពេទ្យព-៩៨ឈ្មោះអីទៅ?

រឿន៖ អត់ទេ! អត់ស្គាល់ទេខ្ញុំ! ព្រោះប្រធានហ្នឹងគាត់អត់បានទៅបង្រៀន ។ ខ្ញុំស្គាល់តែយាយរឿនមានបទបញ្ជាឲ្យពួកមណ្ឌលគិរីហ្នឹងរើសមិត្តនារី៣ ៤ ៥នាក់ដែលមានប្រាជ្ញាទៅរៀនទ្រឹស្តីនៅមន្ទីរពេទ្យហ្នឹងឲ្យបានជ្រៅបន្តិចព្រោះនៅមណ្ឌលគិរីមាន ដូចថាមានជម្ងឺគ្រុនចាញ់ហ្នឹងវាច្រើន ។

ដានី៖ អញ្ចឹងអ្នកជម្ងឺកងទ័ពនៅមណ្ឌលគិរីហ្នឹងភាគច្រើនកើតជម្ងឺគ្រុនចាញ់?

រឿន៖ អូ! គ្រុនចាញ់អាខ្លះរាគរូសអាខ្លះអីទៅ ។

ដានី៖ ក្រៅពីជម្ងឺគ្រុនចាញ់មានជម្ងឺអីដែរអត់?

រឿន៖ អត់មានទេ!

ដានី៖ អញ្ចឹងពេលមីងរៀនពេទ្យចប់រយៈពេល៣ខែហ្នឹងមីងត្រលប់មកមណ្ឌលគិរីវិញ?

រឿនៈ ចាំ! មកមណ្ឌលគិរីវិញ?

ដានីៈ រួចយ៉ាងម៉េចទៀតទៅ?

រឿនៈ ដល់ត្រលប់មកវិញហើយដូចថាគេជ្រើសរើសផ្នែកនារីចេញពីសិល្បៈហើយណានៅអ្នកមុននោះណា! ដល់បង០៦ចូលមកខ្ញុំចេញផុតហើយពីសិល្បៈ ។ ចាំ! គេហៅពូឈិនទៅនោះខ្ញុំចេញផុតហើយពីសិល្បៈនោះ ។ ទៅនោះ...ចាប់ផ្ដើមធ្វើស្រែធ្វើចម្ការទៅ ខ្ញុំមានបានធ្វើស្រែធ្វើចម្ការនិងគេទេ ។

ដានីៈ ចុះកាលនោះពេលណាមីងមានផ្ទៃពោះ ហើយមីង....?

រឿនៈ ខ្ញុំមកពីភ្នំពេញហ្នឹងមកហើយ ។ ខ្ញុំមកពីភ្នំពេញអញ្ចេះណាក្មួយ ចាំមើលណាក្មួយ ។ កូនទីមួយបានតែ២ខែទេ របូតចេញ ចាំ! ដល់កូនមួយទៅបានខ្ញុំទៅឆ្លងទន្លេនៅភ្នំពេញ ចាំ! ទាំងអស់វាកូនមួយ២ខែ កូនមួយហ្នឹងបានត្រឹមត្រូវកើតមកបាន៩ខែក៏ស្លាប់ទៅវិញទៅ ។

ដានីៈ ចុះកូនដែលឆ្លងទន្លេនៅភ្នំពេញនៅឆ្នាំណាទៅ?

រឿនៈ ឆ្នាំ៧៩ ៧៨ ។

ដានីៈ ៧៨ហើយ?

រឿនៈ ចាំ! ៧៨ ។

ដានីៈ បាទ! កាលមីងមកឆ្លងទន្លេនៅភ្នំពេញមីងមកឆ្លងទន្លេនៅកន្លែងណាទៅ?

រឿនៈ ពេទ្យព-១ ។

ដានីៈ ពេទ្យព-១?

រឿនៈ ចាំ!

ដានីៈ នៅកន្លែងណាពេទ្យព-១ហ្នឹង?

រឿនៈ ភ្លេចហើយនោះមិនសូចចំនាំបានដែរដល់ពេទ្យព-១ ....ដូចថាពេទ្យព-១ហ្នឹងពេទ្យកាល់ម៉ែតពីដើម ។

ដានីៈ អ! អញ្ចឹង!

រឿនៈ ចាំ!

ដានីៈ កាលនោះមីងស្នាក់នៅពេទ្យ មីងឆ្លងទន្លេរយៈពេលប៉ុន្មានដែរ?

រឿនៈ ហឺ! ឆ្លងទន្លេបានតែមួយយប់មួយថ្ងៃជិះយន្តហោះមកវិញ ។

ដានីៈ មីងមកតែម្នាក់ឯងទេ?

រឿនៈ ចាំ! ម្នាក់ឯង...ជាមួយពេទ្យ ពួកពេទ្យយើងពីហ្នឹងទៅ ។

ដានីៈ ចុះមីងកាល ដូចថាកាលនោះគេចាប់តាឈិនហ្នឹងបាត់រហូតទៅ ។ ចុះតាសយ តាយៀនអី យ៉ាងម៉េចដែរ?

រឿនៈ អត់ដឹងដែរ! តាំងពីគេហៅហ្នឹងទៅបាត់ជ្រាប មិនដឹងទៅខាងណាខាងណី ។ មិនដឹងគាត់រត់ចេញទៅខាងណាខាងណី ។

ដានីៈ ចុះក្រោយមក០៦មានដែលប្រកាសនិយាយប្រាប់អី ពីតាឈិន តាសយ តាយៀនហ្នឹងយ៉ាងម៉េចដែរ?

រឿនៈ អត់មាន! អត់មានឮ!

ដានីៈ អត់មានឮទេ?

រឿនៈ ចា៎! គ្រាន់តែឮតាមពួកមិត្តហ្នឹងថា តាឈិនហ្នឹងក្បត់អីអញ្ចឹងទៅ រឿងហ្នឹងអត់មានឮ ។

ដានីៈ គេមានប្រជុំពេលប្រជុំថ្ងៃ១០ ថ្ងៃ២០អីមាននិយាយអីទេ?

រឿនៈ អត់មាននិយាយទេ និយាយពីរឿងជម្រុញស្មារតីធ្វើការងារតែប៉ុណ្ណឹង ។

ដានីៈ បាទ! បាទ! ចុះប្រពន្ធតាឈិន តាសយ យាយយ៉ាតអីយ៉ាងមេចដែរ?

រឿនៈ ពួកខាងហ្នឹងដូចថា គេបញ្ជូនមកខាងតំបន់ណា ។

ដានីៈ បញ្ជូនមកខាងតំបន់?

រឿនៈ ចា៎! ខាងតំបន់ ខាងសន្តិសុខតំបន់កាលហ្នឹង ។

ដានីៈ ខាងបញ្ជូនមកខាងសន្តិសុខតំបន់វិញ?

រឿនៈ ចា៎! អញ្ចេះបញ្ជូនមកខាងតាឆិល ដល់បញ្ជូនមកខាងតាឆិលទៅ ក៏តាឆិល តាឈួនហ្នឹងបញ្ជូនទៅខាងតំបន់បន្តគ្នាទៀតទៅណាមិនដឹងទៅខាងណា៎! ចា៎! បន្តគ្នាអត់សូវដឹងដែររឿងហ្នឹង ។

ដានីៈ ប៉ុន្តែមីងដឹងថា ប្រពន្ធគាត់ហ្នឹងត្រូវបានគេបញ្ជូនទៅខាងសន្តិសុខតំបន់?

រឿនៈ ចា៎!

ដានីៈ ពីណាគេប្រាប់មីងថាគេបញ្ជូនគាត់ទៅសន្តិសុខតំបន់? ប្រពន្ធតាឈិន តាសយអីហ្នឹងតាអីហ្នឹង?

រឿនៈ ពួកមិត្តដែលនៅរស់នៅជាមួយគ្នាហ្នឹងណានៅលិចនោះណា...ភ្លេចអស់ហើយ ។

ដានីៈ ចុះប្រពន្ធតាសយមីងស្គាល់ឈ្មោះគាត់ដែរអត់?

រឿនៈ ស្គាល់យាយយ៉ាត ។

ដានីៈ ប្រពន្ធតាឈន?

រឿនៈ អ! ប្រពន្ធតាឈិនឈ្មោះយាយយ៉ាត ។

ដានីៈ ចុះប្រពន្ធតាសយ..?

រឿនៈ ប្រពន្ធតាសយខ្ញុំភ្លេចហើយនេះ...! ឈ្មោះអីខ្ញុំភ្លេចអស់ហើយ?

ដានី៖ តាយៀន?

រឿន៖ តាយៀនអីក្មេចអស់ហើយ?

ដានី៖ កាលគេបញ្ជូនប្រពន្ធមានបញ្ជូនកូន...?

រឿន៖ អ! ប្រពន្ធតាយៀនឈ្មោះយាយប៉ុក ។

ដានី៖ យាយប៉ុក?

រឿន៖ ចា៎! រកនឹកឃើញហើយយាយប៉ុកសិល្បៈ សក់ក្រញាញ់ហ្នឹង ។

ដានី៖ ចុះប្រពន្ធគាត់មានកូនចៅអីទៅជាមួយដែរអត់?

រឿន៖ មានទាំងពីរ ។

ដានី៖ ចុះកូនគាត់យ៉ាងមេចដែរ?

រឿន៖ កូនតាឈិនហ្នឹងអា ឈ្មោះអីទេអាហ្នឹងភ្លេចបាត់ហើយ គ្មានអីទេ គ្រាន់ថាវាប្រហើនបន្តិចកូនតាឈិនហ្នឹង ធំហើយអាយុពេញ១០ឆ្នាំ ។

ដានី៖ ចុះគេបានទាំងកូនទាំងប្រពន្ធអីទៅបាត់ទាំងអស់ហើយ ឬក៏បញ្ជូនតែប្រពន្ធទេ?

រឿន៖ បញ្ជូនទាំងប្រពន្ធទាំងកូនអីទៅបាត់ទាំងអស់ មិនដឹងទៅណា? ទាំងនីរសាទាំងអីទៅអស់រលីងទៅ

ដានី៖ អញ្ចឹងមីងនិយាយមិញគេបញ្ជូនប្រពន្ធកូនតាឈិន តាសយ តាយៀនអីហ្នឹងទៅកន្លែងតាឆិល?

រឿន៖ ចា៎! កាលនោះគេបញ្ជូនទៅសុខសាន្ត ។

ដានី៖ គេបញ្ជូនទៅសុខសាន្ត?

រឿន៖ ចា៎! សុខសាន្តដឹងថាកន្លែងតាឆិលហើយ អ! ប្រពន្ធសយ ដូចថាប្រពន្ធតាសយដំបូងថាអត់ចង់ទៅទេ ចង់នៅតាហ្នឹង ទោះបីយ៉ាងណាក៏ដោយគឺរស់នៅហ្នឹងហើយអត់ទៅទេ យាយប៉ុកហ្នឹងណា ថាមិនទៅដាច់ខាត គាត់មិនទៅទេ ។ ដល់ពេលអញ្ចឹងទៅគេថា អត់ទេ ត្រូវតែទៅតាមមានបទបញ្ជា ត្រូវតែទៅទៅកសាងខ្លួននៅការដ្ឋានសុខសាន្តគេនិយាយអញ្ចេះ ។ កន្លែងហ្នឹងគេហៅការដ្ឋាន ។

ដានី៖ ការដ្ឋានសុខសាន្ត?

រឿន៖ ចា៎!

ដានី៖ គេបញ្ជូនទៅកន្លែងតាឈិលហ្នឹង?

រឿន៖ ចា៎!

ដានី៖ តាឆិលហ្នឹងគាត់ប្រធានសន្តិសុខនៅសុខសាន្តហ្នឹងប្រធានសន្តិសុខរបស់តំបន់ ឬប្រធានសន្តិសុខរបស់កងពល?

រឿន៖ កងពលទីពីរ ។

ដានី៖ ប្រធានសន្តិសុខរបស់កងពលទីពីរ?

វឿន៖ចាំ!

ដានី៖ អញ្ចឹង! ដល់ពេលក្រោយមកគេបញ្ជូនគាត់ទៅតំបន់ទៀត ឬក៏បញ្ជូនគាត់ត្រឹមនៅសុខសាន្តហ្នឹងទេប្រពន្ធតាឈិនអីហ្នឹង?

វឿន៖ ទេដល់រួចអីអញ្ចឹងហើយគេបញ្ជូនទៅតំបន់ទៀតហ្នឹង ។ គេបញ្ជូនទៅតំបន់កបាត់មាត់ បាត់សំលេងជាមួយបងរី ជាមួយមិត្តនឿនអី ។ ដល់មកក្រោយនេះក៏ឃើញគាត់មកផ្ទះនេះ ។

ដានី៖ ឃើញពីណា?

វឿន៖ យាយមេន យាយវឿន បងរីអីនោះ ។

ដានី៖ ចុះនៅកន្លែង...អ្នកដែលជាប់នៅកន្លែងសន្តិសុខតំបន់ហ្នឹងបើតាមមីងចាំដូចថាច្រើនតែខុសអីទៅ?កន្លែងសន្តិសុខរបស់តាឆិល របស់កងពលហ្នឹង ។

វឿន៖ ទីមួយដូចថាអត់ត្រូវគ្នាពីរឿងបញ្ហាគ្រួសាហ្នឹងក៏ថាបាន មួយទៀតអ្នកខ្ជិលធ្វើការទំនុនស្មុក់ដូចថាគ្នាគ្រូនហើយនៅតែជំរុញគ្នាឲ្យទៅទៀតដល់គ្នាមិនទៅថាគ្នាខ្ជិល អញ្ចឹងហើយបញ្ជូនទៅសន្តិសុខចាំ! ទៅកន្លែងមន្ទីឃុំឃាំង ។

ដានី៖ ចុះនៅកន្លែងសន្តិសុខហ្នឹងភាគច្រើនជាប់តែនារីបុរស ៗ អត់មានជាប់នៅហ្នឹងទេ?

វឿន៖ អត់ទេ! អត់សូវមានទេ បុរសនៅសមរភូមិមុខ មាននរណាមកជាប់អី ។

ដានី៖ អត់មានទេ អត់សូវមានទេ!

វឿន៖ ចាំ!

ដានី៖ មីងមានដឹងថា ប្រពន្ធតាឈិន គាសយអីយ៉ាងម៉េចដែរ?

វឿន៖ អត់ដឹង!

ដានី៖ អត់ដឹងទេ?

វឿន៖ ចាំ!

ដានី៖ អ្នកដែលជាប់នៅកន្លែងសន្តិសុខតាឆិលហ្នឹងគេភាគច្រើនបានរួចចេញមកវិញឬក៏បាត់ទៅហ្នង?

វឿន៖ កាល៧៩ហ្នឹង....តាំងពិជាប់មករហូតដល់៧៩ហ្នឹងគេធ្វើស្រូវធ្វើអង្ករ ធ្វើគោកអីបានច្រើនវាស៊ីចុកបានសំបូរសប្បាយអីអញ្ចឹងទៅក៏ឆ្នាំ៧៩ អត់បែកគ្នាទៅក៏វាតាណាត់តាណែងទាំងអស់គ្នាទៅណា ។ មិនដឹងខ្វះទៅខាងណា មិនដឹងខ្វះទៅខាងណាអីអញ្ចឹងទៅណា៎! វាមិនទៀតនៅ....

ដានី៖ ចុះតាឆិលហ្នឹង...ក្រោយមកយ៉ាងម៉េចទៀតទៅតាឆិលហ្នឹង? តាឆិលដែលថាប្រធានសន្តិសុខ?

វឿន៖ មានយ៉ាងម៉េចទេ មកតាមយើងទាំងអស់គ្នាទៅណា ។

ដានី៖ គាត់នៅរស់ទេអញ្ចឹង?

រឿនៈ ចាំ! គាត់នៅរស់នៅអន្លង់វែង ។

ដានីៈ គាត់នៅអន្លង់វែង?

រឿនៈ ចាំ!

ដានីៈ ផ្ទះគាត់នៅកន្លែងណាទៅតាឆិលហ្នឹង?

រឿនៈ ផ្ទះគាត់នៅអន្លង់វែងនៅភូមិទឹកជុំ ។

ដានីៈ ភូមិទឹកជុំ?

រឿនៈ ចាំ!

ដានីៈ ឃុំអីដែរនៅភូមិទឹកជុំហ្នឹង?

រឿនៈ អូ! ភូមិទឹកជុំហ្នឹង ឃុំឃ្លាំងកណ្តាល ។

ដានីៈ ឃុំឃ្លាំងកណ្តាល?

រឿនៈ ចាំ! ខ្ញុំដាក់មុនខុសហើយ ។

ដានីៈ ឃុំឃ្លាំងកណ្តាល?

រឿនៈ ចាំ!

ដានីៈ ស្រុកអីគេនៅនោះ?

រឿនៈ ស្រុកអន្លង់វែង

ដានីៈ ស្រុកអន្លង់វែ?

រឿនៈ ចាំ!

ដានីៈ ខេត្តឧត្តរមានជ័យ?

រឿនៈ ចាំ! ខេត្តឧត្តរមានជ័យ ។

ដានីៈ តាឆិលគាត់នៅឈ្មោះតាឆិលដដែលទេ?

រឿនៈ នៅដដែលតាឆិល ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអីគេ?

រឿនៈ ឈ្មោះយាយស្រី ។

ដានីៈ តាសយ តាយឿនគេចាប់អស់ទៅតា០៦គាត់ឡើង?

រឿនៈ ឡើងកងពល ។

ដានីៈ ឡើងកងពល ។ ចះឡើងកងពល ខាងបន្ទាប់ៗមកទៀតមានគេបញ្ជូនមកទៀតដែរឬក៏អត់ទេ?

រឿនៈ អត់មាន អត់មានផង ។

ដានី: ចុះគេចាប់សយ តាយៀនទៅដូចថា តាឈិនគាត់ឡើងប្រធានកងពល? ចុះអនុបន្ទាប់ៗមកទៀតពីណាទៅ?

រឿន: វា...គាត់ទៅស្រេចហើយ ដូចថា បង៨០ តាឈួប តាខាន់ តា៧៩ តា៧៩គេហៅតានឿន

ដានី: ចុះតាៗ បង០៦ហ្នឹងគាត់ប្រធានកងពល៩២០ហ្នឹង?

រឿន: ចាំ! ៩២០ ។

ដានី: បាទ! ចុះអនុគាត់ឈ្មោះតាអី?

រឿន: អនុគាត់មានពីណា មានតែតា៨០ ។

ដានី: តា៨០?

រឿន: មានតា៧៩ ។

ដានី: តា៧៩ ។ ចុះយន?

រឿន: តាយនហ្នឹងផ្សេង ខាងគាត់ផ្សេងទេ ។

ដានី: ចុះប្រពន្ធតា០៦ឈ្មោះអីទៅ?

រឿន: យាយវីន ។

ដានី: យាយវីនហ្នឹងគាត់ទៅពេលដែលតា០៦គាត់ផ្លាស់ទៅ គាត់ទៅជាមួយហ្នឹងយាយវីនហ្នឹង?

រឿន: ចាំ! ទៅជាមួយ ។

ដានី: យាយវីនគាត់ធ្វើអីដែរ ។

រឿន: យាយវីនគាត់វរៈសេនាធំហ្នឹង ។ វរៈសេនាធំខាងផ្នែកនារី ។

ដានី: ផ្នែកនារី ។ នៅក្នុងកងពលហ្នឹងដែរ?

រឿន: ជាមួយគ្នា ។

ដានី: បាទ! ស្គាល់យាយវីនហ្នឹងដែរអត់?

រឿន: កាលដែលទៅនោះសាល់ ពីមុនអត់ដែលស្គាល់ទេ ។

ដានី: ពីមុនមកអត់ដែលស្គាល់ទេ ។

រឿន: ចាំ!

ដានី: យាយវីនហ្នឹងអ្នកនៅស្រុកណាដែរ?

រឿន: អ្នកនៅកំពង់ឆ្នាំង ។

ដានី: អ្នកនៅកំពង់ឆ្នាំង ។ សព្វថ្ងៃគាត់នៅទេ យាយវីនហ្នឹង?

រឿន: នៅតើ ។

ដានី: គាត់នៅណាទៅ?

រឿនៈ មិនដឹងគាត់នៅមាល័យ មិនដឹងគាត់នៅទំនប់ដាច់ ព្រោះកូនគាត់នៅទំនប់ដាច់ឈ្មោះអាវុធ ។

ដានីៈ កូនគាត់នៅទំនប់ដាច់ឈ្មោះវុធ?

រឿនៈ ចាំ!

ដានីៈ ទំនប់ដាច់ហ្នឹងនៅភូមិទំនប់ដាច់ហ្នឹង?

រឿនៈ ចាំ! នៅក្នុងភូមិទំនប់ដាច់នោះ ។ ប្ដីឈ្មោះអាវុធ ប្រពន្ធឈ្មោះអាវណ័ ។

ដានីៈ ប្រពន្ធឈ្មោះវណ័?

រឿនៈ ចាំ! កូនគា០៥ ។

ដានីៈ វណ័ប្រពន្ធហ្នឹងកូនគា០៥?

រឿនៈ ចាំ!

ដានីៈ ទំនប់ដាច់នៅក្នុងឃុំអីដែរ?

រឿនៈ អត់ដឹង ដាក់ទំនប់ដាច់អញ្ចឹងហ្មង ។

ដានីៈ ទំនប់ដាច់នៅក្បែរអន្លង់វែងហ្នឹងដែរ?

រឿនៈ អត់ទេ! នៅឆ្ងាយទៀត ហួសព្រាំងប្រសាទទៀត ។

ដានីៈ ហួសត្រពាំងប្រសាទទៅ?

រឿនៈ ចាំ! ហួសត្រពាំងប្រសាទទៅឆ្ងាយ ។

ដានីៈ ទៅដល់កន្លែងត្រពាំងប្រសាតទៅដល់កន្លែងហ្នឹង ទៅសួរគេរកអាទំនប់ដាច់គេស្គាល់ហើយណ៎!

រឿនៈ ចាំ! ផ្លូវរហូតទៅ ។

ដានីៈ បាទ! ទំនប់ដាច់ភូមិហ្នឹងឬកយ៉ាងម៉េច?

រឿនៈ ភូមិ ។

ដានីៈ ភូមិគេហ្មង?

រឿនៈ ចាំ! ឥ

ដានីៈ អញ្ចឹងខ្ញុំចង់សួរបន្តិចទៀតចុះដើម្បីបញ្ចប់មីង ទាក់ទងនឹងដូចថាមីងធ្លាប់រស់នៅ ចូលរួមសម័យខ្មែរក្រហមតាំងពីឆ្នាំ៧១?

រឿនៈ ៧១ ។

ដានីៈ បាទ! ៧១រហូតដល់ឆ្នាំ៩០ដាងហ្នឹង បាទ! ដោយសាមីងធ្លាប់រស់នៅជាមួយខាងខ្មែរក្រហមហ្នឹងមីងយល់ឃើញថាការរស់នៅជាមួយខ្មែរក្រហម របបខ្មែរក្រហមពី៧៥ ដល់៧៩ហ្នឹងមីងយល់ថាការរស់នៅហ្នឹងដូចថាយ៉ាងម៉េចដែរ?

រឿនៈ   រស់នៅតាមនៅក្នុងការលំបាកបំផុតណា ស៊ីបាយ អត់មានបាយ អត់មានអំបិលស៊ី ស៊ីតែក្លូច បាយក៏គ្មានអីកគ្មានស៊ីតែក្លូចនោះណា ពុលដងអីដង១ណាឈឺដង ច្របូកច្របល់ ។ អញ្ចឹងបាន ថាខ្ញុំតស៊ូ មិនខំសួរចង់បានអ៊ីមួយ គ្រាន់តែចង់ឲ្យឃើញថា ស្រនុកចិត្តទៅមុខទៅទៀត មិន ស្រនុកចិត្ត ចេញពីស្រនុកមកបាតដៃទរទេអញ្ចឹងទឹងណា ។ សូម្បីលុយគោលុយក្របីខោវអាវ គ្មានឃើញបានអាវត្រឹមតែថា និយាយខោវអាវឲ្យ ហើយគិតថាគួរអរគុណដែរណា ចុះពីលើ មូតូអរគុណ ។

ដានីៈ   ដូចថាកាលមីងរស់នៅជាមួយគាត់ដូចថាអត់បានអីទេ ពេលនៅជាមួយខ្មែរក្រហម?

រឿនៈ   គាមតែគេ រហូតដល់ប្ដីប្រពន្ធព្រាត់គ្នាទៀត រស់នៅព្រាត់កូនព្រាត់ចៅព្រាត់ប្ដីព្រាត់ប្រពន្ធទៀត ដូចរឿងបុនដាចារអញ្ចឹងហើយ ។ ចា! រកទិសរកដៅអត់ឃើញទេ ។

ដានីៈ   ស្ដាយក្រោយអំ ដែលចូលបំរើខ្មែរក្រហម?

រឿនៈ   អត់ស្ដាយអីទេ គ្រាន់តែថា វាមកដំណើរអញ្ចឹងហើយវាបានដាចប់ទៅចុះ ចា៎! ដូចថាវាសនា របស់យើងត្រូវមានការលំបាកត្រូវមានកម្មអញ្ចឹង ត្រូវតែកម្មមួយរយៈអញ្ចឹង បានចេញមក វិញ បានវាគ្មីស្វាងអញ្ចឹង ។ ចេញមកក្រៅក្មីស្វាងហើយសុខមានសិទ្ធិសេរីភាពដើរហើរ មាន សិទ្ធិសេរីភាពនិយាយស្ដី ដូចថាវាចេញពីគុករួចទៅហើយអានេះ ។ នៅជាមួយតាមុក ដូចនៅ ក្នុងគុកអញ្ចឹង ។ បើនិយាយខុសចាប់យកទៅបាញ់ចោលក៏បាន គ្មានបញ្ហា ចាប់ដូចឆ្កែដូចឆ្មា ។

ដានីៈ   ចុះមីងមកដល់សព្វថ្ងៃមីងដែលឮពីពត៌មានស្ដីពីការបង្កើតសាលាក្ដីដើម្បីកាត់ទោសមេដឹកនាំជាន់ ខ្ពស់ខ្មែរក្រហម មិនដែលឮដែរអត់មកដល់សព្វថ្ងៃហ្នឹង?

រឿនៈ   អត់វិទ្យុ អត់មានវិទ្យុឲ្យស្ដាប់ ។

ដានីៈ   ដែលដឹងដែរអត់?

រឿនៈ   អត់! ឮតែថា កាត់ក្ដីកាត់ទោសកាត់អីតាមុក...អ្នកដឹងឃើញចេះតែចង់ស្ដាប់ហើយ ។

ដានីៈ   ចង់ស្ដាប់ដែរ?

រឿនៈ   ចា៎! ចង់ស្ដាប់តាមុកទៅយ៉ាងណាទៅវិញ ។

ដានីៈ   ចុះមីងនៅក្នុងចិត្តមីងមីងដូចថាចង់ឲ្យគេបង្កើតជាសាលាក្ដីដើម្បីកាត់ទោសពួកមេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហមឬក៏អត់ដែរនៅក្នុងចិត្តមីង?

រឿនៈ   នៅក្នុងចិត្តខ្ញុំចង់តែឲ្យគេកាត់ក្ដីឲ្យដាច់ៗស្រនុកដឹងរឿងអញ្ចេះ ។

ដានីៈ   ចង់ដឹងរឿងអីទៅ?

រឿនៈ   ចង់ដឹងរឿងគេសម្លាប់យ៉ាងម៉េចៗនោះ យ៉ាងណាទៅវិញ ។ អាហ្នឹងអីចឹងបានថាស្រេចតាម តុលាការ បើថា តុលាការគេត្រូវថាចងកាត់ទោសខ្មែរក្រហម បើលោករដ្ឋមន្ត្រីតូចធំណា បើ

ឬក៏សម្តេចហ៊ុន សែនលោកចង់កាត់ក្តី និងកាត់ទោសខ្ញុំក៏ចង់ស្តាប់ដែររឿងដំណើរហ្នឹង ។ មិនប្រឆាំង ឬក៏មិនបញ្ចុះឲ្យគេទេណា ជាអាជ្ញាកណ្តាល គេធ្វើមេចធ្វើទៅ ។

ដានី: មីងមានប្រសាសន៍មិញ មីងចង់ដឹងតែតាមុក ចុះអ្នកផ្សេងទៀតមីងអត់ចង់ដឹងទេ?

រឿន: ចង់ដឹងទាំងអស់ ព្រោះណាសម័យតស៊ូហ្នឹង គឺចង់ដឹងទាំងអស់មាប្រវត្តិតស៊ូហ្នឹងនរណាមេចៗ បើថាប្រវត្តិខ្លួនខ្ញុំ នោះខ្ញុំដឹងសព្វគ្រប់អស់ហើយ ។

ដានី: ដូចថាចំពោះមីងវិញ មីងគិតថា ការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហ្នឹងវាមានប្រយោជន៍អីខ្លះដលមីងដល់ប្រជាជនយើងនៅទូទាំងប្រទេសហ្នឹងណាមីង? តាមចិត្តមីងមីងគិតថាវាមានប្រយោជន៍អីខ្លះទៅ?

រឿន: កាត់ក្តីមេខ្មែរក្រហមហ្នឹង?

ដានី: បាទ!

រឿន: ខ្ញុំដូចអត់ចេះឆ្លើយ...អត់ចេះតែហ្នងទៅ ក្នុងការយល់ដឹងរបស់ខ្ញុំដូចថា....មកសួរចំនុចហ្នឹងដូចអត់ដឹង ។

ដានី: ចុះមីងចំពោះពាក្យថាយុត្តិធម៌មីងយល់ថា ពាក្យហ្នឹងមីងយល់ថាម៉េច?

រឿន: យុត្តិធ៌ម បានន័យពាក្យយុត្តិធម៌ ការដឹងខុសដឹងត្រូវអញ្ចឹង? ធ្វើដើម្បីដឹងខុសដឹងត្រូវអញ្ចឹង? ចង់បានខុស និងត្រូវអញ្ចឹង?

ដានី: ពាក្យយុត្តិធម៌ថាពាក្យហ្នឹងថាដឹងខុសដឹងត្រូវ ដើម្បីឲ្យយើងដឹងខុសដឹងត្រូវ ។

រឿន: អាហ្នឹងយោបល់ខ្ញុំថាអញ្ចឹង ចុះក្មួយថាម៉េចវិញចុះ?

ដានី: អត់ទេ! ដូចថាមីងគិតថាពាក្យហ្នឹងយល់ថា ពាក្យហ្នឹងដឹងថា ខុស ដើម្បីឲ្យយើងចង់ដឹងថាពាក្យហ្នឹងដើម្បីចង់ដឹងថាពាក្យហ្នឹង ដើម្បីចង់ដឹងថារឿងហ្នឹងខុស ឬត្រូវអីអញ្ចឹង?

រឿន: ខុសពីតាមុក ឬក៏សម្តេចលោកខុស ។ ឬក៏សម្តេចលោកខុស ឬក៏សម្តេចលោកត្រូវ ។ ចង់ដឹងថា តាមុកបង្កើតជាខ្មែរក្រហមនេះ ធ្វើត្រូវឬខុសអីញ្ចឹងណា? ឬក៏ខាត ឬក៏ចំណេញ? ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ។ ខ្ញុំឆ្លើយថា និងការពួកសំនួរយុត្តិធម៌នេះ អយុត្តិធម៌នេះខ្ញុំរឿងក្តីរបស់ខ្ញុំ ឬក្នុងការយល់ដឹងរបស់ខ្ញុំគឺឆ្លើយប៉ុណ្ណឹង ។ ហើយក្មួយឆ្លើយម៉េចដែរ ឆ្លើយប្រាប់ផង ។

ដានី: មីងចង់សួរខ្ញុំថាយុត្តិធម៌មនិងមានន័យថាម៉េច?

រឿន: ចាំ!

ដានី: យុត្តិធម៌ ចំពោះខ្ញុំ ខ្ញុំយល់ថា យុត្តិធម៌គឺជាការត្រឹមត្រូវ យុត្តិធម៌ហ្នឹងត្រឹមត្រូវមិនលំអៀងទៅខាងណា ដើម្បីឲ្យប្រជាជនហ្នឹងរស់នៅស្មើភាពដូចថា ធ្វើឲ្យបានស្មើភាពតាមច្បាប់តាម

ទំលាប់អីអញ្ចឹងណា នរណាធ្វើខុសគេបញ្ជាក់ថាខុស នរណាធ្វើត្រូវបញ្ជាក់ថាអ្នកហ្នឹងត្រូវអីអញ្ចឹង!

រឿនៈ អញ្ចឹងខ្ញុំឆ្លើយមិញពាក្យយុត្តិធម៌ហ្នឹងចង់ដឹងខុស និងត្រូវខ្ញុំឆ្លើយមិញណា ។

ដានីៈ ខ្ញុំដូចអស់សំនួរអីត្រូវសួរមីងទៀតហើយ អញ្ចឹងដូចថាមីងមានអ៊ីចង់បញ្ជាក់បន្ថែមនូវអ្វីដែលពួកខ្ញុំមិនបានសួរនាំមីង ទាក់ទងហ្នឹងរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមហ្នឹងទៀតដែរអត់?

រឿនៈ មើលទៅដូចឆ្លើយហើយ បើតាមសំនួរឆ្លើយខ្ញុំនយាយកាត់ៗច្រើនណាស់គឺ៣ ៤ ១០ថ្ងៃក៏ឆ្លើយមិនអស់ដែរ ប៉ុន្តែខ្ញុំយក យកមួយថ្នាក់ៗយកនិយាយជាសង្ខេបៗ បើខ្ញុំនិយាយឲ្យអស់សម្ភាសន៍ឆ្នាំទៅតាំងពីម៉ោង៨ហ្វូតដល់ម៉ោង៦ល្ងាចនោះ ។

ដានីៈ កាលមីងសម្ភាសន៍ សម្ភាសន៍ជាមួយពីណាគេទៅ?

រឿនៈ បារាំង!

ដានីៈ ជាមួយជនជាតិបារាំង?

រឿនៈ ចា៎! បារាំងសុទ្ធតែអត់ចេះខ្មែរទេមានតែលោកគ្រូភាន់ទេចេះខ្មែរ ។

ដានីៈ មានតែពីណាគេ?

រឿនៈ គ្រូដាន ។

ដានីៈ គ្រូភាន់ ។ មានបារាំងអ្នកសម្ភាសន៍មីង មានខ្មែរអ្នកបកប្រែ?

រឿនៈ ចា៎! ខ្មែរមានគ្រូដានម្នាក់ បារាំងកាម៉ារ៉ាបី ខាងនេះមួយ ខាងនោះមួយ ខាងនោះមួយមានអាប្រដាប់គេយកមកបាំងហោប៉ៅអាវអញ្ចេះ កាម៉ារ៉ាគេនៅពីមុខប៉ុណ្ណេះ យើងនិយាយអញ្ចឹងឃើញនៅក្នុងហ្នឹង?

ដានីៈ គេសួរមីងពីរឿងអីទៅ?

រឿនៈ សួរប្រវត្តិតស៊ូរបស់ខ្ញុំកាលនៅពីក្មេងរហូតដល់ចាស់នោះ ។

ដានីៈ បាទ! អញ្ចឹងខ្ញុំអរគុណមីងច្រើនដែលចំណាយពេលវេលាដូចថា ប្រហែលជា៣ម៉ោងជាង បាទយូរដែរ ។ ខ្ញុំអរគុណមីងច្រើន ។

រឿនៈ ចា៎!

ដានីៈ មិញខ្ញុំសួរមីងថាធ្លាប់ស្តាយក្រោយចំពោះការចូលបំរើបដិវត្តន៍ហ្នឹងអត់? ខ្ញុំចង់បានចំលើយ?

រឿនៈ ខ្ញុំគិតថា ក្នុងការតស៊ូរយៈ៣៥ឆ្នាំណា គ្រាន់តែខ្ញុំតស៊ូ៣៥ ។ ក្នុងការតស៊ូក្នុងសង្គ្រាមរយៈ៣៥ឆ្នាំហ្នឹងយើងថាស្តាយ ក៏យើងមិនថាស្តាយណា៎! ក្នុងការតស៊ូអានេះជាផលក្ខរបស់ខ្ញុំវាទៅអញ្ចឹងគ្មាននរណាដឹកនាំក៏ទៅដែរ ។ ខ្ញុំឆ្លើយអញ្ចឹង ។

ដានីៈ ចុះមីងគិតថាអាហ្នឹងជាកម្មទេអញ្ចឹងមីង?

រឿនៈ ខ្ញុំគិតថា នេះជាកម្មរបស់ខ្ញុំដែលអត់បាននៅជុំម៉ែជុំឪបងប្អូនរកតែឃ្លាតឆ្ងាយ ។

ដានីៈ មីងខឹងជាមួយមេដឹកនាំនៅសម័យខ្មែរក្រហមហ្នឹងទេមីង? មេដឹកនាំធំៗមីងខឹងទេដែលបង្កឲ្យមីងលំបាកវេទនា?

រឿនៈ បេះតែខឹងហើយគេស៊ីបរបូណយើងអត់ គេមានបាយស៊ី គេមានឡានជិះគេមានត្រីសាច់គេត្រឹមត្រូវហើយយើងស៊ីអំបិលស៊ីប្រហុក ប្រហុកក៏គ្មានបាន អំបិលក៏គ្មានដែរ ។

ដានីៈ មីងខឹងពីណាខ្លះមីង?

រឿនៈ ខ្ញុំបើនិយាយឲ្យខ្ញុំខឹង...ខ្ញុំខឹងមេដឹកនាំធំៗនោះនរណាធំជាងគេ ។

ដានីៈ នរណាខ្លះមីងស្គាល់ទេ នរណាខ្លះដែលមីងថាធំជាងគេ?

រឿនៈ ធំជាងគេគឺបង០៦ ។

ដានីៈ ០៦ ។ មីងខឹងបង០៦?

រឿនៈ ខ្ញុំក៏ខឹងដែរបង០៦នោះ ។ ខ្ញុំខឹងទីមួយក្នុងការរស់នៅដូចថា មានចែកក្រណាត់ចែកអីអញ្ចឹងអត់ត្រឹមត្រូវណាក្មួយ ។ ចាំ! ចែកក្រណាត់ចែកអីអញ្ចឹង គេឯងបានក្រណាត់ល្អៗដល់ទៅខ្ញុំយកក្រណាត់សមកទុកផាប់ហ្នឹង ល្អជាអី ។ រួចយើងដើរយើងត្រូវការក្រណាត់ខ្មៅក្រណាត់ខៀវដល់អញ្ចឹងខ្ញុំខឹងបង៧៩ ខឹង...ខឹងពីរឿងចែកសម្ភារៈអញ្ចឹងណា ។ ចែកយើងអត់ឯកភាពគ្នា ។

ដានីៈ កាលចែកហ្នឹងចែកនៅណា ចែកនៅអន្លង់វែងហើយ ឬចែកនៅក្នុងសម័យខ្មែរក្រហម?

រឿនៈ ចែកនៅកែបសីមា ។

ដានីៈ កែបសីមា?

រឿនៈ នៅមណ្ឌលគីរីនោះ ។

ដានីៈ នៅមណ្ឌលគីរីនោះមីង?

រឿនៈ ចិនយកមកចែកឲ្យធ្វើមិត្តនោះ ។

ដានីៈ កាលនោះចែកអត់ស្មើគ្នាទេ?

រឿនៈ អត់ទេ ចែកអត់ស្មើគ្នាទេ នរណាបានល្អ ។ ប្រពន្ធមេៗបានល្អទៅ អត់ប្រពន្ធមេៗបានអាក្រក់ទៅណា បានស បានអី ពណ៌លឿងពណ៌អីកាត់ខោម៉េចកើតអាអញ្ចឹងនោះ ។

ដានីៈ ចុះក្រៅពីបង៧៩ ក្រៅបង០៦ហ្នឹងមីងខឹងពីណាទៀតដែលមីងចាត់ទុកថា មេដឹកនាំធំៗដែលមីងស្គាល់ហ្នឹង?

រឿនៈ ដូចថាមេដឹកនាំធំខ្ញុំខឹងថារឿងបញ្ហាអត់អំបិល អត់អីទៅសុំមេអត់បានស្អប់តាមុកហ្នឹងហើយ ។

ដានីៈ ស្អប់តាមុក ។

រឿនៈ ខ្ញុំខឹងហ្នឹងហើយ ។

ដានី៖ មឹងចូលទៅជួបគាត់ផ្ទាល់ហ្នឹងអី?

រឿន៖ ជួបតាហ្នឹងណា ជួបគាត់ហ្នឹងហ្នឹងណា។

ដានី៖ សុំគាត់អត់ឲ្យ?

រឿន៖ ចាំ! សុំគាត់អត់ឲ្យទេ ខ្ញុំដើរចម្ងាយពីហ្នឹងទៅផ្លូវអញ្ចឹងណាបានគាត់ហៅមកវិញៗមកយកលុយវិញ បានគាត់ឲ្យលុយទៅវិញ គាត់ធ្វើឲ្យយើងខឹងទៅណា។

ដានី៖ ឲ្យប៉ុន្មានទៅ?

រឿន៖ ឲ្យកាលនោះប៉ុន្មានទេ ឲ្យ២០០ដុល្លា។

ដានី៖ ២០០ដុល្លា?

រឿន៖ ឲ្យទិញបាយ ទិញអង្ករទិញ....

ដានី៖ នៅអន្លង់វែងហ្នឹង?

រឿន៖ អត់ទេ! នៅក្នុងព្រៃកែបសីមា។

ដានី៖ ព្រៃកែបសីមាហ្នឹងតាមុកនៅហ្នឹងដែរ?

រឿន៖ នៅកាលហ្នឹងយើងមិនចុះទៅព្រៃស្អាកក្លួយ ចេញពីកេបសីមាទៅយើងមិនចុះនៅព្រៃស្អាកនៅកំពង់ប្រសាទហ្នឹង រួចសុំគាត់នៅព្រៃស្អាកហ្នឹង គាត់ដាច់ជើងហើយណា។ ពេលគាត់ដាច់ជើងហើយ គាត់ដើរឡើងទៅលើភ្នំអត់រួចទេ។ ក្នុងចិត្តខឹងតាមុកម្តងហ្នឹងហើយ។

ដានី៖ មេចបានគាត់ដាច់ជើង?

រឿន៖ គាត់ជាន់មីន។

ដានី៖ ជាន់នៅណា?

រឿន៖ អត់ដឹងទេ! ខ្ញុំអត់សូវដឹងទើបតែស្គាល់តាមុកដែរហ្នឹងព្រោះខ្ញុំនៅមណ្ឌលគិរីមិនសូវស្គាល់ប្រវត្តិគាត់ទេ ខ្ញុំគ្រាន់តែឃើញគាត់ជើងកំបុត់អញ្ចឹងហ្នង។ ចាំ! គាត់ខូចជើងដើរបាំងខ្វែកៗ។

ដានី៖ ចុះក្រៅពីតាមុកមានពីណាគេទៀត?

រឿន៖ ក្រៅពីតមុកដែលនៅ?

ដានី៖ បាទ!

រឿន៖ នៅខាងតាមុកខ្ញុំអត់សូវស្គាល់ទេ។

ដានី៖ ដែលមឹងស្អប់ មឹងខឹងនោះណា?

រឿន៖ ខ្ញុំខឹងតែបង៧៩ បង០៦ហ្នឹងណា! ងាប់អស់ហើយ។

ដានី៖ ចុះមេដឹកនាំធំៗប៉ុល ពត បន្ទាប់ប៉ុលពតមកទៀតមឹងខឹងទេ?

រឿនៈ អត់ទេ! ខ្ញុំអត់ដែលស្គាល់ទេ អត់ដែលរស់នៅជាមួយផង គាប៉ុល ពតខ្ញុំមិនខឹង ខ្ញុំខឹងតែវរៈ-សេនាតូច ចរៈសេនាធំអញ្ចឹងទៅណា កន្លែងខ្ញុំរស់នៅដូចថា បែកអ៊ីមួយវាអត់មានឯកភាពគ្នាណា ។ វាអត់មានស្មើភាព គេថាសាមគ្គីរើសបុគ្គលនោះណា ។

ដានី: រើសបុគ្គល?

រឿនៈ ចា៎! បុគ្គលណាដេលគេពេញចិត្តគេឲ្យល្អទៅ បុគ្គលណាដែលមានការបន្ទាប់តាមដំណើរទៅ ។

ដានី: ចុះមីងថាគាមុកឲ្យលុយ២០០ដុល្លានៅកាលនោះមីងនៅក្នុងព្រៃ?

រឿនៈ ចា៎! ខ្ញុំនៅព្រៃស្អាក ។

ដានី: ព្រៃស្អាក ។ គេឲ្យលុយ២០០ដុល្លាទៅចាយនៅណាបើមីងនៅក្នុងព្រៃ?

រឿនៈ ខ្ញុំទៅចាយនៅខាងគោកស្រុក ។ យើងដូចថាទាហ៊ានចេញយើងចូលអញ្ចឹងទៅណា ។ ពេលយប់ពេលអីអញ្ចឹងទៅណា ។

ដានី: លួចចូល?

រឿនៈ ចា៎! លួចចូល ។

ដានី: ឆ្នាំណាទៅ?

រឿនៈ មិនដឹងឆ្នាំណាទេ...ឆ្នាំ៨៥...

ដានី: នៅឆ្នាំ៨៥ ។

រឿនៈ ចា!

ដានី: មីងរស់នៅដូចថា មីងធ្លាប់ចូលបំរើខ្មែរក្រហមអីអញ្ចឹង ហើយដោយសារបបហ្នឹងវាធ្វើបាបប្រជាជន ធ្វើបាបមនុស្សធ្វើបាបអីអញ្ចឹងណា ដល់ពេលមីងផុតរបបហ្នឹងមក មីងមករស់នៅអីអញ្ចឹងអ្នកជិតខាងរបស់មីងមានគិតយ៉ាងមេចចំពោះមីងដែរដោយសាមីងធ្លាប់ធ្វើបំរើឲ្យខ្មែរ-ក្រហមអីអញ្ចឹងណា? រាប់អានមីងធម្មាតា?

រឿនៈ ធម្មតា ។

ដានី: តែគេដឹងថាមីងធ្លាប់ចូលធ្វើខ្មែរក្រហមដែរ?

រឿនៈ ដឹង ។ ដឹងទាំងអស់នរណាក៏ដឹងដែរ ។

ដានី: ប៉ុន្តែគេម៉េច...?

រឿនៈ ធម្មតាគ្មានអីទេ....ធម្មតា ។

ដានី: គេនិយាយរកមីង?

រឿនៈ ធម្មតាអត់អីទេ,

ដានី៖ តែមីងគិត ខ្លួនឯងគិតថា នៅក្នុងចិត្តគេ គេគិតយ៉ាងម៉េចទៅចំពោះមីង គិតធម្មតា គេខឹងមីង ស្អប់មីងយ៉ាងមេចដែរ?

រឿន៖ វាដូចថាអត់មាននរណាស្អប់ទេខ្ញុំ ព្រោះដើរតែជួយសង្គ្រោះគេ ៗ បើនិយាយពីអាអ្នកស្អប់ ១០០មានតែមួយទេតែប៉ុណ្ណឹង ។

ដានី៖ អ! មានអ្នកស្អប់ដែរ ។

រឿន៖ ១០០មានតែមួយអីអញ្ចឹងណា កំណត់ដូចថា មកសុំអីយើងអញ្ចឹងអញ្ចឹង ដូចថាយើងថាអត់មានហើយខ្ញុំ មនុស្សខ្ញុំចូលចិត្តនិយាយការពិត មនុស្សខ្ញុំច្រើននិយាយពាក្យសច្ចៈ តែខ្ញុំថាអត់មានគឺអត់មានហើយ តែខ្ញុំថាមានគឺខ្ញុំទូលាយអញ្ចឹង ។ ចា៎! ដូចសព្វថ្ងៃអញ្ចឹង ។

ដានី៖ មីងថាមីងខឹងខ្មែរក្រហមបង០៦ បង៧៩ តាមុកអីអញ្ចឹង តើធ្វើមេចឲ្យមីងបាត់ខឹង?

រឿន៖ តាំងពីគាត់ឲ្យលុយខ្ញុំមកខ្ញុំឈប់ខឹង ។

ដានី៖ អ! ឲ្យលុយមកឈប់ខឹង ។

រឿន៖ ចុះពីកងទ័ពអត់លុយទិញអង្ករ អត់លុយទិញអង្ករមួយថ្ងៃមិនអាណិតគ្នា អាខ្លះកូនខ្ញុំអត់អង្ករស៊ី នោះណាប្តីទៅសមរភូមិបាត់អស់យើងមានអីស៊ី ។

ដានី៖ ចុះមីងឈប់ខឹងគាត់រហូតមកដល់ឥឡូវ?

រឿន៖ ខ្ញុំមិនដែលខឹងអីទេ ឥឡូវក៏ដោយស្អីក៏ដោយ ខ្ញុំខឹងតាំងពីកាលនោះមួយពេល ខឹងហ្នឹងខ្ញុំ ។

ដានី៖ អញ្ចឹងឥឡូវមីងចង់ឲ្យគេកាត់ទោសគាត់ទៀតទេ?

រឿន៖ ស្រេចតែរដ្ឋាភិបាលធ្វើម៉េចក៏ធ្វើទៅ តែអារម្មណ៍របស់ខ្ញុំ ខ្ញុំនិយាយអញ្ចឹង ។ បើថាម៉េចសម្យ ក៏សម្យ ។

ដានី៖ បើតាមចិត្តមីងផ្ទាល់រដ្ឋាភិបាលគេធ្វើម៉េចគេដឹងតែធ្វើហើយតែចិត្តមីងផ្ទាល់មីងចង់ឲ្យកាត់អត់? ដូចថាតាមុកអីអញ្ចឹង ។

រឿន៖ មិនដឹងឆ្លើយថាម៉េច? អញ្ចឹងបើថាឆ្លើយមិនឲ្យកាត់ទោសទៅខ្លាចមានទោស ។

ដានី៖ អត់ទេមីងនិយាយអត់មានទោសអីសោះ ស្រុកឥឡូវគេនិយាយគ្រប់គ្នា....

រឿន៖ អត់ទេដូចថា ពាក្យសោ្ភកលោកនិយាយដែរតាំងពីដើមមក មុនស្រដីត្រូវរិះគិត ក្រែងពាក្យមិនពិតវាមិនសម្យ ។

ដានី៖ ខ្ញុំដូចជាអស់ហើយមីង! តែដូចពីដើមអញ្ចឹងខ្ញុំបានសុំឲ្យមីងធ្វើបទបន្ទិច...បទសិល្បៈមីងនោះ សុំបន្តិចឲ្យចង់ចាំទុកណាមីង កុំឲ្យភ្លេច....

រឿន៖ មិនដឹងច្រៀងយ៉ាងម៉េចទេ ខ្ញុំច្រៀងមិនកើតទេ ចាស់ហើយ....

ដានី៖ ចាស់ហើយសំលេងកាន់តែផ្អែមជាងមុន...

រឿនៈ មិនទេអត់ទេ....

ដានីៈ ខ្ញុំសុំមីងបន្តិចមីងចាំប៉ុណ្ណាមីងច្រៀងប៉ុណ្ណឹងទៅ.....សុំផ្ញើបន្តិចទៅមីងបើមិនអញ្ចឹងទេវាបាត់បង់ ឥឡូវមីងច្រៀងទៅខ្ញុំថតទុកអញ្ចឹង ទុករហូត១០ ២០ ៣០ឆ្នាំទៀតនៅសល់ទុករហូត ។

រឿនៈ បារាំង មកម្តងឲ្យទាំងពីរដង បារាំងខ្មែរមកម្តងទៀតឲ្យម្តងទៀត ។

ដានីៈ អ! មីងធ្លាប់ច្រៀងពីមុនដែរអញ្ចឹង? ឥឡូវម្តងទៀតទៅមីង ។

រឿនៈ មើលទៅយើងក្មេងការទៅបានលុយ មកច្រៀងមុខក្មួយបានតែពោតស៊ី.....

ដាន់ៈ សុំតិចទៅមីង....អាចកូនចៅមីងអីបានស្តាប់ទៀតនោះ....មីងចាមបទអីច្រៀងបទហ្នឹងទៅ ។

រឿនៈ និយាយរឿងបទវាគគោកនោះ ប៉ុនមិនដឹងធ្វើម៉េចទេ ដូចថាវាមិនចាំអស់ណា...

ដានីៈ ឥឡូវច្រៀងអត់កើតនិយាយក៏បានដែរណា?

រឿនៈ ទម្រង់បទហ្នឹង?

ដានីៈ បាទ!

រឿនៈ ម៉េចទេនិយាយៗអញ្ចឹង....

ដានីៈ អត់ទេមីងចាំប៉ុណ្ណាថាប៉ុណ្ណឹងទៅ...ច្រៀងសាកមើលមើលមីងបារាំងឲ្យច្រៀងកើតបារាំងឲ្យលុយ មីងច្រៀងកើត.....

រឿនៈ បទហ្នឹងមិនដឹងជាលំនាំបទអីទេ?

ដានីៈ មីងចាំចំណងជើងទេ?

រឿនៈ ចំណងជើង....លំនាំបទយើងឥឡូវមិនដឹងជាបទអីទេ ដូចខុសសំនៀងបទយើងណា...ចា៎! វាខុស ដូចនីរសាអគ្គអាចអីមិនដឹងជាលំនាំបទអីទេ....

ដានីៈ នីរសាអគ្គអាច...?

រឿនៈ មិនដឹងជាលំនាំបទអី,

ដានីៈ ចុះកាលបារាំងឲ្យច្រៀងមីងច្រៀងបទអី?

រឿនៈ ពួកពេទ្យបដិវត្តន៍ ។

ដានីៈ ពួកពេទ្យបដិវត្តន៍ ។ មើលសុំអាហ្នឹងបន្តិចមើល....

រឿនៈ មិនដឹងច្រៀងម៉េចទេ...

ដានីៈ ចុះមីងនៅរដូវប្រាំងដូចថាគ្រាន់យើងដូរចំរៀងអីដូចថា នីរសាអគ្គអាចអីតទៅទៀតអី..?

រឿនៈ ដូចថានីរសាអគ្គអាចម៉េចទេ?

ដានីៈ ចុះពេទ្យបដិវត្តជន៍?

រឿនៈ ពេទ្យបដិវត្តន៍...ពួកយើងជាពេទ្យបដិវត្តន៍ យើងខំប្រឹងអត់ធ្មត់ តាមមាគ៌ាមហាជន..ពេទ្យយើង ជាពេទ្យប្រជាជន ស៊ូទ្រាំអត់ធន់ការលំបាកវេទនា.....ប៉ុណ្ណឹង ។

ដានីៈ អីទៀតមីង...កន្លែងស្រែក...

រឿនៈ សាច់មួយឈាមមួយហ្នឹងគ្នា...ៗបម្រើមាគ៌ាអស់ពីចិត្តពីថ្លើម គិតយ៉ាងម៉េចទេ? រាប់រៀង អញ្ចឹងវាអត់សូវចេះ ចេះតែច្រៀងតាហ្នឹងទៅចេះតែទៅហើយ ។

ដានីៈ ច្រៀងហ្នឹងទៅអញ្ចឹងហើយ...!

រឿនៈ បានប៉ុណ្ណឹងៗ បានហើយ ។

ដានីៈ ចុះខាងនីរសារអន្តអាចវិញ?

រឿនៈ នីរសារអន្តអាច...នីរសារអន្តអាចមិនចេះខ្លួចអ៉ មេ៉ចទេ....ទាស់យប់ថ្ងៃ..មេ៉ចទេ? រាប់រៀប អញ្ចឹងទៅមិនរួច វាភ្លេចយូរហើយមកណា ។

ដានីៈ ចុះបទអីទៀតមីងធ្លាប់?

រឿនៈ មានបទក្មេងៗបទចាស់ៗវាមិនសូវមាន ។

ដានីៈ បាទ! បទក្មេងក៏បាន?

រឿនៈ បទក្មេង ពួកយើងខ្ញុំក្រុមកុមារឈានមុខ មេ៉ចទៀតប៉ុណ្ណឹង...ខ្ញុំអត់សូវចាំបទក្មេងៗ ច្រើនតែ ពួកក្មេងៗកុមារយើងយកទៅបង្ហាត់បង្រៀនអីអញ្ចឹងទៅ...យូរទៅវាចេះតែភ្លេចទៅណា យូរ ហើយមានយកចិត្តទុកដាក់អី...យកចិត្តទុកដាក់តែអាចំរៀងយើងពីសង្គមប៉ុណ្ណឹងឯង ចំរៀង យើងពិសង្គមចេះតែនឹកឃើញចំរៀង...ខ្ញុំចាំដាងគេពេទ្យបដិវត្តន៍ហ្នឹងចាំមិនចប់ផងទេឥឡូវនោះ ពីមុនអាស្អីក៏ចេះដែរ របាំងទ្រុឌរបាំអីសិល្បៈអីលេងល្ខោនលេងអី មាចប់របស់ខ្ញុំនោះ ម៉ាឆាក ជីវិតនេះចេះទាំងអស់ស្អីក៏ដោយ អត់ចេះតែស្នូងស្រែ ភ្ជួរដីទេអត់ចេះ ។

ដានីៈ បាទ!អញ្ចឹងខ្ញុំអរគុណមីងច្រើន!

រឿនៈ ចា៎!

## ចម្រៀងរបស់សមមិត្តនារី ជិន សាមុិ
## បទចម្រៀងខ្មែរក្រហម
## ១២ ខែកុម្ភៈ ឆ្នាំ២០០៦

បទ បំពេរកង់ទ័ព

អាសូរមិត្តណាស់អើយ មិត្តតស៊ូ ឈាមមិត្តអើយបានហូរអើយ ជោគធរណីអើយ
មិត្តហ៊ានលះបង់ហ៊ឺ..... និងបូជជីវិ មិត្តមានអើយនាទី បម្រើប្រជាជនអើយ ។
សូមមិត្តសម្រាក់ទៅអើយ... ឲ្យសុខសាន្ត មិត្តញាតិគ្រប់ប្រាណអើយ ជួយជាបន្ទុន់អើយ...
បំបាត់ចុកចាប់ហ៊ឺ...... ឈឺរោយស្រពន់ មិត្តអើយយប់យន់ រាល់ពេលរាល់រាត្រី... ។
ហាអើយ...អើយ... គ្រប់ពេលអើយវេលា រាល់ពេលរាត្រី ។

បទ ពេទ្យបដិវត្តន៍

ពួកយើងនេះជារពេទ្យបដិវត្តន៍ យើងខំប្រឹងអនុវត្តតាមមាគ៌ាមហាជន

ពេទ្យយើងជាពេទ្យប្រជាជនៗ    បម្រើអត់ធន់តាមមាគ៌ាមហាជន ។
ពួកយើងជាវណ្ណៈក្រីក្រ    នេះគឺជាសរសរបដិវត្តន៍កម្ពុជា
រងទុកលំបាកវេទនាៗ    បម្រើមាគ៌ា.....(អ! ភ្លេចបាត់ទៅហើយ)

...................

សិល្បៈយើងខ្ញុំអើយ  អើយប្ដេជ្ញាបូជាខ្លួនៗ    រឹងបឹងខ្ជាប់ខ្ជួនអនុវត្តមាគ៌ា....(ភ្លេចបាត់ហើយ)
បានហើយអរគុណ ។

ដានីៈ មីងបទចម្រៀងអស់ហ្នឹងមានដឹងនរណាអ្នកតែឲ្យដែរ?

រឿនៈ ដឹង!

ដានីៈ អត់ដឹងទេ! ចុះនរណាអ្នកបង្ហាត់ឲ្យច្រៀងហ្នឹង?

រឿនៈ ពួកខាងសិល្បៈគេហ្នុង ។

ដានីៈ នរណាគេពួកខាងសិល្បៈហ្នឹង?

រឿនៈ មេគេធំៗណា៎!

ដានីៈ បាទ! អរគុណមីងអរគុណច្រើន!

**ចប់**